អ្នកម្តាយមួយរូបបង្កើតសាលាបណ្តុះបណ្តាលកុមារអូទីសឹម ដោយខ្លួនឯង ក្រោយសាលាជាច្រើនបដិសេធទទួលយកកូនមើលថែ <ទំព័រ៖១២-១៣

វិបត្តិកូវីដ ពិធីបុណ្យហែស្លឹកឆ្នាំនេះប្រារព្ធដោយភាពស្ងប់ស្ងាត់ <ទំព័រ៖២១



កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ កុម្ភៈ | ឆ្នាំ ២០២១ | លេខទី ១៣៦

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

February, 2021 | #136



# អធិដ្ឋានសម្រាប់វិញ្ញាណក្ខន្ធ លោកអភិបាល អុីវ រ៉ាមូស

“ ”
លោកបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជាអស់ពីកម្លាំងកាយចិត្ត លោកមានធម៌មេត្តាករុណា និងគិតពីប្រយោជន៍ព្រះសហគមន៍ និងអ្នកដទៃជានិច្ច

*+ លោកអភិបាលទេព ច័ន្ទពិសិដ្ឋ*
*អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង*

“ ”
ព្រះជាម្ចាស់ បានប្រទានលោកអភិបាល អុីវ រ៉ាមូស ជាព្រះអំណោយសម្រាប់ជីវិតព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា

*+ អូលីវីយេ ជ្មឹតហាស្លេរ*
*អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ*

“ ”
វត្តមានលោកតា អុីវ រ៉ាមូស សំខាន់ណាស់សម្រាប់ប្រវត្តិសាស្ត្រព្រះសហគមន៍យើង ហើយលោកទៅគ្រប់ទីកន្លែងដើម្បីជួបគ្រីស្តបរិស័ទ្ធខ្មែរក្នុងពិភពលោក

*+ លោកអភិបាល ប្រ៊ុយណូ កូសម៍*
*អភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម*



# បុណ្យចម្លងជិតមកដល់ហើយ តើបងប្អូនបានត្រៀមខ្លួនអ្វីខ្លះ សម្រាប់ពេលវេលាដ៏ពិសិដ្ឋនេះ?

បងប្អូនជាទីស្រឡាញ់ បុណ្យចម្លងជិតមកដល់ហើយ នៅថ្ងៃអាទិត្យនេះព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម! តាមជំនឿកាតូលិក យើងដឹងច្បាស់ថាព្រះយេស៊ូបានដឹងមុនថា ការយាងចូលក្រុងយេរូសាឡឹមរបស់ព្រះអង្គគឺមានក្រុមអ្នកប្រាជ្ញ អ្នកនយោបាយនឹងចាប់ព្រះអង្គ និងធ្វើគត់ផង។

បងប្អូន ក្នុងសប្តាហ៍ពិសិដ្ឋ ជាពិសេសនៅត្រៃទិវា ព្រះសហគមន៍នឹងរំឭកយ៉ាងពិសេស អំពីព្រឹត្តិការណ៍នៃទុក្ខលំបាករបស់ព្រះយេស៊ូ ចាប់ពីថ្ងៃព្រហស្បតិ៍ពិសិដ្ឋដែលជាទិវានៃការជប់លៀងចុងក្រោយរបស់ព្រះយេស៊ូ ជាយប់ដែលក្រុមអ្នកមានអំណាច អ្នកប្រាជ្ញ អ្នកនយោបាយបានចាប់ព្រះអង្គ យកទៅសួរចម្លើយ ធ្វើទារុណ្ណកម្ម និងកាត់ក្តី។ ថ្ងៃសុក្រពិសិដ្ឋ ជាថ្ងៃដែលវិនិច្ឆ័យចុងក្រោយ ដែលឆ្កាងព្រះយេស៊ូលើឈើឆ្កាង ហើយព្រះអង្គសោយទិវង្គត។ ថ្ងៃសៅរ៍ពិសិដ្ឋ ពេលរាត្រី ដែលព្រះជាម្ចាស់បានប្រោសយេស៊ូ ឱ្យរស់ឡើងវិញ។

ព្រឹត្តិការណ៍នេះសំខាន់ណាស់សម្រាប់គ្រីស្តបរិស័ទគ្រប់រូប ដែលមួយឆ្នាំមានតែម្តង ដើម្បីចូលក្នុងការសង្គ្រោះរបស់ព្រះជាម្ចាស់ ដោយសារព្រះជន្មផ្ទាល់របស់ព្រះអង្គ។ ព្រះសហគមន៍ជាសកល បានប្រារព្ធត្រៃទិវាយ៉ាងយកចិត្តទុកដាក់បំផុត និងឱឡារិកយ៉ាងក្រៃលែង។

ប៉ុន្តែអ្វីៗត្រូវប្រែប្រួលច្រើន ដោយសារស្ថានភាពនៃមេរោគឆ្លង កូវីដ១៩ ដែលមិនអនុញ្ញាតឱ្យយើងជួបជុំគ្នាក្រុមធំក្នុងព្រះវិហារបានឡើយ។

**តើមេរោគកូវីដ១៩ ពិតជាមារដែលរារាំងមិនឱ្យយើងទាំងអស់គ្នា លើកតម្កើងព្រះជាម្ចាស់មែនទេ?**

ចម្លើយ គឺមិនមែនទេ! គ្មានអ្វីដែលរារាំង មិនឱ្យយើងប្រារព្ធបុណ្យ និងចូលរួមក្នុងទុក្ខលំបាកនិងការសង្គ្រោះរបស់ព្រះជាម្ចាស់ចំពោះប្រជារាស្ត្ររបស់ព្រះអង្គឡើយ។ ព្រះសហគមន៍រកគ្រប់មធ្យោបាយ ដែលជាព្រះអំណោយទានរបស់ព្រះអង្គ ប្រើជាផ្លូវជួបជុំលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ នោះគឺតាមបណ្តាញសង្គម ហ្វេសប៊ុក យូធូប និងកម្មវិធីផ្សេងៗទៀត។

សំខាន់តើបងប្អូនត្រៀមចិត្តគំនិតហើយឬនៅ? ទោះបីតាមបណ្តាញផ្សព្វផ្សាយទាំងនោះព្រះសហគមន៍មិនអនុញ្ញាតឱ្យទទួលអគ្គសញ្ញាលើកលែងទោស និងព្រះកាយព្រះគ្រីស្តក៏ដោយ តែជាមធ្យោបាយមួយដែលយើងជាអាចជួបជុំ រួមចិត្តគំនិតទទួលព្រះពរក្នុងពេលពេលបូជាចារ្យ ឬលោកអភិបាលព្រះសហគមន៍កំពុងប្រារព្ធពិធី។ យើងចូលរួមដោយចិត្តជ្រះថ្លា និងមានជំនឿយ៉ាងពិតប្រាកដ។ យើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់រួមគ្នា ពិធីកាច់នំប៉័ងរួមគ្នាក្នុងចិត្តគំនិតតែមួយ និងជំនឿតែមួយ។



តើបងប្អូនបានប្រែចិត្តគំនិតយ៉ាងណាខ្លះក្នុងរដូវអប់រំពិសេស ឬ ៤០ថ្ងៃនេះ? ច្បាស់ណាស់ បងប្អូនគ្រីស្តបរិស័ទពិតជាចាំជានិច្ច នូវចំណុចសំខាន់ទាំងបីដែលត្រូវប្រព្រឹត្ត គឺអធិដ្ឋាន តមអាហារ និងចែកទាន។ តើពាក្យទាំងបីនេះ ចូលក្នុងចិត្តនិងការរស់នៅរបស់បងប្អូនយ៉ាងដូចម្តេចខ្លះ? តើសំដៅលើតែសម្ភារឬយ៉ាងណា? ស្របពេលនេះ យើងកំពុងភ័យខ្លាចនៃជំងឺកូវីដ១៩ ដូចក្រុមសាវ័កដែលរត់ចោលព្រះអម្ចាស់យេស៊ូ នៅសួនច្បារកេសេម៉ានី ពេលដែលទាហានមកចាប់ព្រះយេស៊ូ។ តើយើងបានខ្លាចកូវីដ១៩ដោយភ្លេចព្រះយេស៊ូ ឬរត់ចោលព្រះយេស៊ូ ដូចក្រុមសាវ័កដែរ ឬយ៉ាងណា?

តើបងប្អូនចែកទានអ្វីខ្លះក្នុងរយៈពេលកន្លមកនេះ? នោះគ្រាន់តែសំដៅតែលើសម្ភារប៉ុណ្ណោះមែនទេ? តើបងប្អូនបានកែប្រែរបៀបរស់នៅរបស់បងប្អូនដែរឬទេ? បានសម្រុះសម្រួលគ្នាជាមួយបងប្អូនរបស់យើងហើយឬនៅ? បានលើកលែងទោសឱ្យគេដែរឬទេ? ឈប់អង្គុយច្រណែន មើលបំណាំ ឈប់ចាប់កំហុស របស់បងប្អូនយើងហើយឬនៅ? បើនៅទេ សូមចាប់ផ្តើមផ្សះផ្សាគ្នាក្នុងសប្តាហ៍ពិសិដ្ឋនេះ។

ក្នុងសារលិខិតសម្រាប់រដូវអប់រំពិសេស (រដូវ៤០ថ្ងៃ) សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ មានប្រសាសន៍ថា រដូវអប់រំពិសេស(៤០ថ្ងៃ)នេះ ជាពេលប្រមើលមើលឡើងវិញអំពី ជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់របស់យើងម្នាក់។ លោកថា «ជំនឿ» ណែនាំឱ្យយើងទទួលយកសេចក្តីពិត ហើយថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ និងចំពោះបងប្អូនទាំងឡាយ។ «សេចក្តីសង្ឃឹម» ជាទឹកដែលផ្តល់ជីវិត ដែលនាំឱ្យយើងអាចបន្តដំណើរទៅមុខទៀត។ «សេចក្តីស្រឡាញ់» តាមគន្លងនៃមាគ៌ារបស់ព្រះយេស៊ូ គឺយកចិត្តទុកដាក់ និងមានមេត្តាករុណា ចំពោះបងប្អូនទាំងអស់។ សេចក្តីស្រឡាញ់ជាចំណុចសំខាន់បំផុតក្នុងជំនឿ និងសេចក្តីសង្ឃឹមរបស់យើង។

បងប្អូនរួមជំនឿជាទីស្រឡាញ់ក្នុងរយៈពេលនេះសំខាន់ណាស់សម្រាប់ជំនឿរបស់យើង។ ដូច្នេះ រដូវ៤០ថ្ងៃជាពេលត្រូវប្រមើលមើលឡើងវិញអំពីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់ និងចំពោះបងប្អូនឯទៀតៗ។ ក្នុងយុទ្ធនាការប្រយុទ្ធនឹងកូវីដ១៩ យើងមិនអាចទៅព្រះវិហារបាន ប៉ុន្តែកុំយកវាជារនាំងរារាំងទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់។ អ្វីសំខាន់នោះ សូមចូលរួមពិធីនានាតាមបណ្តាញសង្គមរបស់ព្រះសហគមន៍។ សូមរក្សាខ្លួនជានិច្ច ឱ្យឆ្ងាយពីកូវីដ១៩ និង យកចិត្តទុកដាក់ ការពារខ្លួន និងមិនចម្លងទៅបងប្អូនរបស់យើងក្នុងសហគមន៍។ កុំភ្លេច ៣ការពារ និង៣កុំ។ សេចក្តីស្រឡាញ់ ជាចំណុចសំខាន់បំផុតក្នុងជំនឿ និងសេចក្តីសង្ឃឹមរបស់យើង៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

**ចាងហ្វាង : លោក លី សុវណ្ណា**
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.វ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# ជនបរទេសណាដែលល្មើស គេចវេស និងមិនចូលរួមសហការក្នុងការធ្វើចត្តាឡីស័កនឹងត្រូវបណ្តេញចេញពីកម្ពុជា

*អត្ថបទ៖ អមរិទ្ធ ដានុត*

សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែនបាន យល់ព្រមលើសំណើនៃការបណ្តេញចេញពីប្រទេសកម្ពុជានិងហាមចូលប្រទេសសារជាថ្មីនូវជនបរទេសណាដែលល្មើស គេចវេស និងមិនចូលរួមសហការក្នុងការធ្វើចត្តាឡីស័ក។

ចំណារ «យល់ព្រម»នៅថ្ងៃចន្ទ ទី២២ ខែកុម្ភៈ ឆ្នាំ២០២១ របស់សម្តេចតេជោហ៊ុន សែន ត្រូវបានធ្វើឡើងតាមការស្នើសុំគោលការណ៍ ពីលោកឧត្តមសេនីយ៍ឯក ឌី វិជ្ជា អគ្គស្នងការរងនរគបាលជាតិ និងជាអនុគណៈកម្មការស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យថាមានផ្ទុកជំងឺកូវីដ១៩ ។

លោកឧត្តមសេនីយ៍ឯក ឌី វិជ្ជា បាន ផ្ញើលិខិតស្នើសុំគោលការណ៍អនុវត្តន៍ច្បាប់ចំពោះបុគ្គលមិនអនុវត្តន៍តាមវិធានការរបស់ក្រសួងសុខាភិបាលចំពោះការធ្វើចត្តាឡីស័កបុគ្គលគេចវេសមិនព្រមចូលព្យាបាល ឬមិនសហការផ្តល់ការសម្ភាសន៍ និងទីតាំងដែលមិនសហការផ្តល់ព័ត៌មានការស្រាវជ្រាវ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ បន្ថែមលើអនុក្រឹត្យលេខ២៧ អនក្រ.បក។

លោកឧត្តមសេនីយ៍ឯក ឌី វិជ្ជា បាន លើកឡើងក្នុងលិខិតនេះថា កន្លងមកក្នុងព្រឹត្តិការណ៍៣វិច្ឆិកា, ២៨វិច្ឆិកា និង២០ កុម្ភៈ អនុគណៈកម្មការស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យថា មានផ្ទុកជំងឺកូវីដ១៩ តែងតែជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនក្នុងប្រតិបត្តិការរបស់ខ្លួន។

លោកបន្តថា ក្នុងនោះមានបញ្ហាបុគ្គលជាប់ពាក់ព័ន្ធនឹងជំងឺកូវីដ១៩ មិនព្រមសហការផ្តល់ការសម្ភាសន៍ ផ្តាច់ទំនាក់ទំនង និងករណីរត់គេចមិនព្រមធ្វើចត្តាឡីស័កជាដើម ដែលធ្វើឱ្យកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងតាមដានបុគ្គលផ្ទុកជំងឺកូវីដ១៩ ដែលធ្វើឱ្យប្រតិបត្តិការមានភាពយឺតយ៉ាវ និងខ្វះចន្លោះ។

លោកឧត្តមសេនីយ៍ឯក ឌី វិជ្ជា បានឱ្យដឹងថា ៖ «ខ្ញុំសូមស្នើសម្តេចអគ្គមហាសេនាបតីតេជោ អនុវត្តន៍នូវវិធានការចំនួន៣ចំណុចគឺ ចំពោះជនបរទេស បណ្តេញចេញពីប្រទេសកម្ពុជា និងហាមចូលប្រទេសជាថ្មី, ចាត់វិធានការតាមផ្លូវច្បាប់ ចំពោះជនជាតិខ្មែរ និងសម្រាប់ម្ចាស់ទីតាំង សូមដកហូតអាជ្ញាប័ណ្ណ និងបិទអាជីវកម្មក្នុងទីតាំង»។

យោងតាមចំណារលើលិខិតស្នើនេះគឺត្រូវបានសម្តេចតេជោ ហ៊ុន សែន យល់ព្រមឱ្យមានការអនុវត្តន៍វិធានការច្បាប់នេះ៕





*លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការក្រសួងយុត្តិធម៌។ **រូបភាព៖ ក្រសួងមហាផ្ទៃ***

## ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ជាថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥

*អត្ថបទ៖ អមរិទ្ធ ដានុត*

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានកំណត់យកថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ ជាកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ ។

យោងតាមសេចក្តីសម្រេចស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ដែលសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន ចុះហត្ថលេខាចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ បានលើកឡើងបញ្ជាក់ពីថ្ងៃនៃការការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ នេះ។

គួររំលឹកផងដែរថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ បានធ្វើឡើងកាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ដោយមានគណបក្សនយោបាយចូលរួមចំនួន១២ ប៉ុន្តែមានតែគណបក្សប្រជាជនកម្ពុជា និងអតីតគណបក្សសង្គ្រោះជាតិប៉ុណ្ណោះ ដែលទទួលបានអាសនៈច្រើនជាងគេ។ គណបក្សប្រជាជនកម្ពុជា ទទួលបានចំនួន ៦ ៥០៣ អាសនៈ និងអតីតគណបក្សសង្គ្រោះជាតិទទួលបានចំនួន ៥ ០០៧ អាសនៈ ក្នុងចំណោមអាសនៈសរុបនៅទូទាំងប្រទេសចំនួន ១១ ៥៧២ អាសនៈ។

សម្តេចបានបញ្ជាក់ក្នុងសេចក្តីសម្រេចនេះថា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ៕

# នាយករដ្ឋមន្ត្រីកម្ពុជា ៖«គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ជាឃាតករលាក់មុខបំផ្លាញជីវិតប្រជាជន»

*អត្ថបទ៖ ផល សុផានិត*

សង្គ្រាមកន្លងមកនៅកម្ពុជា បានបន្សល់ទុកនូវគ្រាប់មីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលបណ្តាលឱ្យប្រជាពលរដ្ឋរាប់ម៉ឺននាក់ រងរបួស ធ្លាក់ខ្លួនពិការ និងស្លាប់បាត់បង់ជីវិត ព្រមទាំងបង្កនូវសោកនាដកម្មដ៏ឈឺចាប់ និងរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិថែមទៀតផង។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងក្នុងសារលិខិតក្នុងឱកាសប្រារព្ធខួបលើកទី២២ នៃទិវាយល់ដឹងអំពីមីន២៤កុម្ភៈ ឆ្នាំ២០២១ ថា «គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ជាឃាតករលាក់មុខបំផ្លាញជីវិតប្រជាជន»។

សម្តេចតេជោ ហ៊ុន សែន លើកឡើងថា គិតចាប់តាំងពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០២០ រយៈពេល២៨ ឆ្នាំកន្លងមកនេះ ផ្ទៃដីទំហំ២.១៣៨ គីឡូម៉ែត្រក្រឡា ត្រូវបានបោសសម្អាតសម្រាប់យកទៅប្រើប្រាស់ និងបង្កបង្កើនផលក្នុងនោះវិស័យកសិកម្ម៥៨ភាគរយ ហេដ្ឋារចនាសម្ព័ន្ធ១២ ភាគរយ និងផ្សេង៣៨ភាគរយ រួមមាន ការសាងសង់លំនៅឋាន ភូមិករ សាលា រៀន មណ្ឌលសុខភាពជាដើមដោយមានប្រជាពលរដ្ឋទទួលផលចំនួន៦.៣៥៧. ៨៥៣ នាក់។

សម្តេចបានបន្តថា មីនប្រឆាំងមនុស្ស ចំនួន ១.០៩៥.៧៥០ គ្រាប់ មីនប្រឆាំងរថក្រោះចំនួន២៥.៤៨៨គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមរាប់បញ្ចូលទាំងគ្រាប់បែកចង្កោមចំនួន ២.៨៨៥.២៩៤ គ្រាប់ត្រូវ បានរកឃើញនិងបំផ្លាញចោល។ ចំនួនជនរងគ្រោះបានថយចុះពី ៤.៣២០នាក់ក្នុងឆ្នាំ ១៩៩៦ មកត្រឹម៦៥ នាក់ ក្នុងឆ្នាំ២០២០ កន្លងទៅនេះ។

សម្តេចនាយករដ្ឋមន្ត្រីថ្លែងថា៖ «ក្នុងនាមជាអ្នកស្រឡាញ់សន្តិភាព រាជរដ្ឋាភិបាលកម្ពុជា ក៏តែងតែយកចិត្តទុកដាក់គិតគូរ និងបានរួមចំណែកយ៉ាងសកម្ម ក្នុងការជួយសម្រាលទុក្ខលំបាករបស់បណ្តាប្រទេស ដែលរងផលប៉ះពាល់ដូចគ្នា តាមរយៈការបញ្ជូនកងកម្លាំងរក្សាសន្តិភាពចូលរួមបំពេញបេសកកម្ម ក្នុងក្របខ័ណ្ឌប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ»។

ក្នុងនោះមាននៅប្រទេសចំនួន ៩ រួមមាន៖ ប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង លីបង់ ស៊ីប ស៊ីរី យេម៉ែន ឆាត ម៉ាលី និងអាហ្វ្រិកកណ្តាល សរុបចំនួន ៧.១២៣ នាក់។

សម្តេចតេជោគូសបញ្ជាក់ថា ថ្វីបើវិស័យសកម្មភាពមីន បាន និងកំពុងទទួលផលដ៏ធំ ធេងយ៉ាងណាក៏ដោយ កម្ពុជាត្រូវការបោសសម្អាតផ្ទៃដីដែលមានមីនចំនួន ៨៣៥ គីឡូម៉ែត្រក្រឡា និងសំណល់ជាតិផ្ទុះពីសង្គ្រាម រួមទាំងគ្រាប់បែកចង្កោមចំនួន ១.៣១៦ គីឡូម៉ែត្រក្រឡាបន្ថែមទៀត ដើម្បីសម្រេចបាននូវចក្ខុវិស័យតាមផែនការយុទ្ធសាស្ត្រជាតិ «កម្ពុជាមួយគ្មាន មីនឆ្នាំ២០២៥ »។

សម្តេចតេជោហ៊ុន សែន ក៏បានអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំប្រដាប់អាវុធគ្រប់ប្រភេទ ប្រតិបត្តិករជាតិ និងអន្តរជាតិត្រូវចូលរួមឱ្យបានខ្លាំងក្លាថែមទៀត ក្នុងការផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារមីនគ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដល់ប្រជាពលរដ្ឋសិស្សានុសិស្ស កុមារា កុមារី និងយុវជនក្រៅសាលា នៅតាមសហគមន៍ដែលរងផលប៉ះពាល់ និងអំពាវនាវដល់ប្រទេសម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍បន្តគាំទ្រដល់សកម្មភាពបោសសម្អាតមីនគ្រាប់បែកចង្កោមនិងសំណល់ជាតិផ្ទុះពីសង្គ្រាម អប់រំកាត់បន្ថយគ្រោះថ្នាក់ និងសង្គ្រោះជនពិការ ដោយសារគ្រឿងផ្ទុះទាំងនេះ៕

# មួយភាគបីនៃប្រភេទ ត្រីទឹកសាប

## ដែលពិភពលោកមិនសូវផ្ដោតការយកចិត្តទុកដាក់កំពុង ទទួលរងការឈានទៅរកការផុតពូជ




ត្រីគល់រាំងដែលជាត្រីកម្រស្ថិតក្នុងចំណាត់ថ្នាក់ជិតផុតពូជ ថតក្នុងផ្ស

*អត្ថបទ៖ អមរិន្ទ ដានុត*

យោងតាមរបាយការណ៍ស្ដីអំពីប្រភេទត្រីទឹកសាបនៅលើពិភពលោក (World's Forgotten Fish) ដែល ចេញផ្សាយដោយអង្គការអភិរក្សចំនួន១៦នៅលើសកលលោកបានឱ្យដឹងថា ត្រីទឹកសាបជាច្រើនប្រភេទនៅលើពិភពលោកមានសារសំខាន់សម្រាប់សុខភាព សន្តិសុខស្បៀង និងជីវភាពរបស់មនុស្សរាប់លាននាក់ ប៉ុន្តែត្រីទាំងនេះបាននិងកំពុងរងការគម្រាមកំហែងកាន់តែខ្លាំងឡើង ហើយមួយភាគបីនៃប្រភេទត្រីទាំងនេះកំពុងទទួលរងការផុតពូជ។

របាយការណ៍នេះបានពណ៌នាលម្អិតពីប្រភេទត្រីទឹកសាបដ៏អស្ចារ្យជាច្រើនប្រភេទ រួមទាំងប្រភេទត្រីដែលទើប តែស្រាវជ្រាវរកឃើញថ្មីៗ សរុបប្រមាណជា ១៨.០៧៥ ប្រភេទ ដែលជាចំនួនច្រើនជាងពាក់កណ្ដាលនៃប្រភេទត្រីទាំងអស់ក្នុងពិភពលោក ហើយស្មើនឹង មួយភាគបួននៃប្រភេទសត្វឆ្អឹងកងទាំងអស់នៅលើភពផែនដីនេះ។

ទន្លេមេគង្គដែលជាទីជម្រករបស់ត្រីទឹកសាបចំនួនជាង ១.១០០ ប្រភេទ គឺជាទន្លេមួយ ដែលមានផលិតភាពធនធានត្រីទឹកសាបច្រើនជាងគេបំផុតក្នុងចំណោមទន្លេផ្សេងទៀតលើពិភពលោក។

ជីវៈចម្រុះទឹកសាបកំពុងទទួលរងការធ្លាក់ចុះទ្វេដងនៃអត្រាធ្លាក់ចុះនៃជីវៈចម្រុះសមុទ្រនិងព្រៃឈើ។ ជាក់ស្ដែង ត្រីទឹកសាបចំនួន ៨០ ប្រភេទត្រូវបានចាត់ជាប្រភេទផុតពូជ ក្នុងបញ្ជីក្រហមនៃប្រភេទសត្វទទួលរងគ្រោះ របស់សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ក្នុងនោះរួមមានទាំងត្រីទឹកសាបចំនួន ១៦ ប្រភេទដែលបានកត់ត្រាជាប្រភេទផុតពូជក្នុងឆ្នាំ២០២០ផងដែរ។ ទន្ទឹមនឹងនេះ ចំនួនត្រីទឹកសាបដែលជាប្រភេទត្រី បន្លាស់ទី បានធ្លាក់ចុះ ៧៦ ភាគរយចាប់តាំងពីឆ្នាំ១៩៧០ ហើយពពួកត្រីមេពូជបានធ្លាក់ចុះ ៩៤ ភាគរយ។

លោក ស្ទួត អរ (Stuart Orr) នាយកកម្មវិធីធនធានទឹកសាបអន្តរជាតិនៃអង្គការ WWF បានឱ្យដឹងថា ទន្លេ បឹង និងតំបន់ដីសើមនានានៅក្នុងពិភពលោក ជាកន្លែងដែលទទួលរងការខូចខាតធនធានធម្មជាតិធ្ងន់ធ្ងរជាងគេទាំងអស់ ហើយសញ្ញាយ៉ាងច្បាស់បំផុតនៃការខូចខាតធនធានធម្មជាតិទាំងនេះ គឺការធ្លាក់ចុះចំនួនត្រីទឹកសាបយ៉ាងឆាប់រហ័ស។ ការធ្លាក់ចុះនេះជាការប្រកាសអាសន្នសម្រាប់ធនធានទឹកសាប ដែលទាំងអស់គ្នាត្រូវតែយកចិត្តទុកដាក់ឱ្យខ្លាំងបំផុត។

លោក ស្ទួត អរ មានប្រសាសន៍ថា ៖ «អ្វីដែលពួកយើងត្រូវការឥឡូវនេះ គឺការទទួលស្គាល់នូវគុណតម្លៃរបស់ ត្រីទឹកសាប និងធនធានជលផលទឹកសាប ដើម្បីឱ្យរដ្ឋាភិបាលកំណត់ការអនុវត្តគោលដៅនិងដំណោះស្រាយថ្មីៗ ក៏ដូចជាការកំណត់អាទិភាពក្នុងកិច្ចការពារ និងការស្ដារប្រព័ន្ធអេកូឡូស៊ីទឹកសាបឡើងវិញ។ យើងទាំងអស់គ្នាត្រូវការភាពជាដៃគូនិងភាពច្នៃប្រឌិត តាមរយៈចំណាត់ការសកម្មភាពរួម ដោយមានការចូលរួមពីរដ្ឋាភិបាល វិស័យធុរកិច្ច អ្នកវិនិយោគ សង្គមស៊ីវិល និងសហគមន៍»។

យោងតាមការវាយតម្លៃបឋមស្ដីអំពីការជួញដូរត្រីនិងនេសាទខុសច្បាប់ឆ្នាំ២០២០ របស់អង្គការ WWFកម្ពុជា បានបង្ហាញថា ត្រីគល់រាំង ត្រីត្រសក់ក្រហម ត្រីក្របី ត្រីខ្លា ត្រីត្រចៀកដំរី និងត្រីបបែលទឹកសាប ក្នុង ចំណោមត្រី ៣៥ ប្រភេទ ផ្សេងទៀតត្រូវបានគេជួញដូរ និងលក់តាមទីផ្សារក្នុងប្រទេសកម្ពុជា ក៏ដូចជានាំចេញ ទៅលក់នៅប្រទេសជិតខាង។ ត្រីគល់រាំង និងត្រីត្រសក់ក្រហម ត្រូវបានចាត់ថ្នាក់ជាប្រភេទទទួល រងគ្រោះជិតផុតពូជបំផុតទាំងនៅលើសកលលោក និងនៅក្នុងប្រទេសកម្ពុជា ចំណែកឯត្រីក្របី ត្រីខ្លា និងត្រី

> " ត្រីទឹកសាបទាំងនេះមានសារសំខាន់ណាស់សម្រាប់សហគមន៍មូលដ្ឋាន ប៉ុន្តែត្រីទាំងនេះមិនសូវទទួលបានការផ្ដោតការយកចិត្តទុកដាក់ "




*រូបភាពត្រីគល់រាំង (Giant barb) ថតក្នុងឆ្នាំ២០២០ **រូបភាព៖ WWF Cambodia***




*ត្រីត្រសក់ក្រហម (Probarbus labeaminor) ថតក្នុងឆ្នាំ២០២០។ **រូបភាព៖ WWF Cambodia***




*ារត្រីមួយកន្លែងដើមឆ្នាំ២០២១។ រូបភាព៖ **WWF Cambodia***

ត្រចៀកដំរីត្រូវបានចាត់ថ្នាក់ជាប្រភេទរងគ្រោះជិតផុតពូជក្នុងប្រទេសកម្ពុជា។

លោក សេង ទៀក នាយកអង្គការ WWF មានប្រសាសន៍ថា៖ «ត្រីទឹកសាបទាំងនេះមានសារសំខាន់ណាស់សម្រាប់សហគមន៍មូលដ្ឋាន ប៉ុន្តែត្រីទាំងនេះមិនសូវទទួលបានការផ្តោតការយកចិត្តទុកដាក់»។ លោកថា ត្រីទាំងនេះ មានសារសំខាន់ចាំបាច់សម្រាប់សុខភាពមនុស្ស និងប្រព័ន្ធអេកូឡូស៊ីទឹកសាបទាំងមូល ដែលមនុស្ស និងជីវិតនៅលើផែនដីទាំងអស់ពឹងអាស្រ័យ។ សារសំខាន់ទាំងអស់នេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវផ្តោត ការយកចិត្តទុកដាក់និង ដល់ចងចាំជានិច្ច។

របាយការណ៍ បានគូសបញ្ជាក់អំពីកគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះប្រព័ន្ធអេកូឡូស៊ីទឹកសាប និងត្រីទឹក សាប រួមមានការនេសាទហួសកម្រិត និងការប្រើប្រាស់មធ្យោបាយនេសាទបែបបំផ្លិចបំផ្លាញ ការបំផ្លាញទីជម្រក ទំនប់វារីអគ្គីសនីកាត់ដងទន្លេ ការប្រើប្រាស់បរិមាណទឹកហួសកម្រិតសម្រាប់ការស្រោច ស្រព និងការបំពុលដែលមានប្រភពចេញពីការប្រើប្រាស់ទឹកតាមគេហដ្ឋាន ការប្រើប្រាស់ទឹកសម្រាប់វិស័យ កសិកម្ម និងឧស្សាហកម្ម។

សេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពន្យារការសាងសង់ទំនប់វារីអគ្គីសីយៈពេល ១០ឆ្នាំ កាត់ទន្លេមេគង្គ បានទទួលការកោតសរសើរជាច្រើន។ ការដាក់បញ្ចូលត្រីទឹកសាបទៅក្នុងសេចក្តី សម្រេចចិត្តនានាក្នុងផែនការអភិវឌ្ឍ គឺជាគំរូនៃការគ្រប់គ្រងដ៏ប្រសើរបំផុត៖ កត្តានេះត្រូវតែក្លាយជាគោលការណ៍សម្រាប់ការគ្រប់គ្រង។

លោក សេង ទៀក ថា ការសម្រេចចិត្តដ៏ត្រឹមត្រូវរបស់ប្រទេសកម្ពុជាគឺជាគំរូមួយសម្រាប់ប្រទេសដទៃទៀត ក្នុងការទទួលស្គាល់ថាទន្លេដែលមានលំហូរតាមធម្មជាតិ ផ្តល់នូវសារៈប្រយោជន៍ដែលមិនអាចកាត់ថ្លៃបានដល់មនុស្ស និងប្រភេទសត្វជាច្រើនដែលពឹងអាស្រ័យលើវា៕







*ត្រីខ្លា (ដែលមានឈ្មោះបច្ចេកទេស Coins undecimradiatus) ថតឆ្នាំ២០២០។ រូបភាព៖ **WWF Cambodia***



*ពង និងអណ្តើកហ្លួង (មានឈ្មោះវិទ្យាសាស្ត្រថា Batagur affinis)។ **រូបភាព៖ អង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា (WCS)***

# មេអណ្តើកហ្លួង ក្នុងមជ្ឈមណ្ឌលអភិរក្សសត្វល្មូន បានពងជាលើកដំបូងចំនួន៧១ពង

*អត្ថបទ៖ អមរិន្ទ ដានុត*

មេអណ្តើកហ្លួងចិញ្ចឹមចំនួន ៥ក្បាល បានពងនៅលើឆ្នេរខ្សាច់សិប្បនិម្មិតក្នុងមជ្ឈមណ្ឌលអភិរក្សសត្វល្មូនខេត្តកោះកុង ដោយទទួលបានពងសរុបមានចំនួន ៧១ពង។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា (WCS) នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ នេះ។

យោងតាមអង្គការនេះបានឱ្យដឹងថា កាលពីសប្តាហ៍កន្លងទៅ យោងតាមរូបភាពទទួលបានពីម៉ាស៊ីនថតសត្វស្វ័យប្រវត្តិបានបញ្ជាក់ថាពងអណ្តើកហ្លួងទាំងអស់នោះ គឺជាពងរបស់មេអណ្តើកហ្លួង ៥ក្បាលដែលក្រុមការងារបានយកទៅចិញ្ចឹមថែទាំនៅក្នុងមជ្ឈមណ្ឌលនោះកាលពីជាង ១០ ឆ្នាំមុន ដោយក្នុងនោះមាន ៤ក្បាលត្រូវបានក្រុមការងារយកពីតាមឆ្នេរខ្សាច់ក្នុងប្រព័ន្ធព្រែកស្រែអំបិលក្រោយញាស់ភ្លាម និង មួយក្បាលទៀតត្រូវបានពលរដ្ឋនៅខេត្តកោះកុងយកមកប្រគល់ឱ្យកាលពីឆ្នាំ ២០១៧។

លោក សោម ស៊ីថា ប្រធានគម្រោងអភិរក្សប្រចាំតំបន់កោះកុងនិងមេគង្គនៃអង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា (WCS) បានថ្លែងថា នេះជាលើកទីមួយហើយដែលអណ្តើកហ្លួងចិញ្ចឹមនៅក្នុងមជ្ឈមណ្ឌលនេះបានពង ក្រោយពេលដែលមេអណ្តើកហ្លួងទាំងនេះត្រូវបានយកមកចិញ្ចឹមថែទាំតាំងពីឆ្នាំ ២០០៦ មក។

លោកថា៖ «ក្រុមការងារនឹងពិភាក្សាគ្នាថាតើត្រូវសាងសង់សម្បុកសិប្បនិមិត្តដើម្បីភ្ញាស់ពងទាំងនេះ ឬមួយក៏ទុកវាឱ្យញាស់ក្នុងសភាពដើម»។

អ្នកជំនាញផ្នែកឧរង្គសត្វនិងថលជលិក នៃអង្គការ WCS ប្រចាំតំបន់អាស៊ីអាគ្នេយ៍លោក ស្ទីវីន ផ្លាត (Steven G. Platt) បានមានប្រសាសន៍ថា នេះគឺជារឿងដ៏រំភើបនិងដ៏សំខាន់មួយដែលមិនគួរឱ្យជឿថាប្រភេទសត្វអណ្តើកដ៏កម្រប្រភេទនេះអាចពងនៅទីនេះ។

លោកថា៖ «ការបង្កកំណើតរបស់សត្វអណ្តើកហ្លួងដែលយើងយកមកចិញ្ចឹមគឺជាគោលដៅអភិរក្សមួយសម្រាប់ស្តារប្រភេទអណ្តើកហ្លួងដែលជិតផុតនេះឡើងវិញនៅក្នុងប្រទេសកម្ពុជា»។

លោក ស្ទីវីន ផ្លាត (Steven G. Platt)





*អ្នកជំនាញកំពុងធ្វើការកាយសំបុករបស់មេអណ្តើកហ្លួង ៥ក្បាលដែលក្រុមការងារបានយកទៅចិញ្ចឹមថែទាំនៅក្នុងមជ្ឈមណ្ឌលអភិរក្សសត្វល្មូន និងរូបភាពថតដោយម៉ាស៊ីនថតសត្វស្វ័យ។* ***រូបភាព៖ អង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា***

រំពឹងថាគម្រោងនេះនឹងអាចជំរុញការបង្កាត់ប្រភេទអណ្តើកនេះបានចំនួនច្រើននៅក្នុងមជ្ឈមណ្ឌលនេះ និងអាចយកវាទៅលែងចូលក្នុងទីជម្រកធម្មជាតិរបស់វាវិញបាន។

**«ការបង្កកំណើតរបស់សត្វអណ្តើកហ្លួងដែលយើងយកមកចិញ្ចឹមគឺជាគោលដៅអភិរក្សមួយសម្រាប់ស្តារប្រភេទអណ្តើកហ្លួងដែលជិតផុតនេះឡើងវិញនៅក្នុងប្រទេសកម្ពុជា»**

ចំណែក លោកស្រីបណ្ឌិត សុនចា លូហ្ស៍ (Dr Sonja Luz) អនុប្រធានផ្នែកអភិរក្ស ស្រាវជ្រាវ និងពេទ្យសត្វនៃឧទ្យានសត្វព្រៃប្រទេសសឹង្ហបុរី (WRS) បានលើកឡើងផងដែរថា ឧទ្យានសត្វព្រៃប្រទេសសឹង្ហបុរី (WRS) មានក្តីរំភើបដោយបានចូលរួមចំណែកក្នុងគោលដៅដ៏សំខាន់មួយទៀតដើម្បីអភិរក្សប្រភេទអណ្តើកដ៏កម្រនេះ។

លោកស្រីថា ឆ្នាំ២០២១ គឺជាការចាប់ផ្តើមដ៏អស្ចារ្យមួយសម្រាប់អណ្តើកហ្លួង បន្ទាប់ពីបានលែងប្រភេទអណ្តើកនេះចំនួន១០ក្បាលចូលទៅក្នុងទីជម្រកធម្មជាតិវិញកាលពីចុងខែមករា កន្លងទៅ។

លោកស្រីបណ្ឌិត សុនចា លូហ្ស៍ (Dr Sonja Luz) បានមានប្រសាសន៍ថា៖ «នេះជាការលើកទឹកចិត្តមួយសម្រាប់ពួកយើង ដោយឃើញដៃគូរបស់យើងសម្រេចការងារបានលទ្ធផលល្អ ទោះបីជាស្ថិតក្នុងស្ថានភាពនៃការគំរាមកំហែងដោយជំងឺរាតត្បាតនៅលើពិភពលោកក្តី ហើយយើងខ្ញុំរីករាយនិងអបអរសាទរសមិទ្ធិផលទាំងនេះទាំងអស់គ្នា»។

លោកស្រីបន្តថា នេះគឺជាសក្ខីភាពនៃការលះបង់របស់ដៃគូពាក់ព័ន្ធនានាក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងអភិរក្សដើម្បីការពារប្រភេទអណ្តើកហ្លួងនេះ។

ប្រធាននាយកដ្ឋានអភិរក្សជលផលលោក អ៊ុក វិបុល បានឱ្យដឹងថា៖ «យើងមានមោទនភាពណាស់ដែលទទួលលទ្ធផលដ៏អស្ចារ្យនេះ»។

លោកបន្តថា រដ្ឋបាលជលផលសូមធ្វើការលើកទឹកចិត្តនិងគាំទ្រពេញទំហឹង និងបន្តកិច្ចការស្រាវជ្រាវនេះទៀតដើម្បីសម្រេចគោលដៅក្នុងពេលអនាគត ហើយលោកសង្ឃឹមថា អណ្តើកហ្លួងដែលជាប្រភេទជិតផុតពូជនេះនឹងមានវត្តមានរស់នៅយូរអង្វែងសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។

អង្គការ WCS បាននិងកំពុងសហការជាមួយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាប់តាំងពីឆ្នាំ ២០០០ ដើម្បីអភិរក្សប្រភេទអណ្តើកហ្លួងនេះ (មានឈ្មោះវិទ្យាសាស្រ្តថា Batagur affinis) នៅកម្ពុជា។

បន្ទាប់ពីបានរកឃើញវត្តមានប្រភេទនេះសាជាថ្មីក្នុងឆ្នាំ ២០០០ នៅតាមប្រព័ន្ធព្រែកស្រែអំបិលភាគនិរតីនៃប្រទេសកម្ពុជា អង្គការ WCS សហការជាមួយរដ្ឋបាលជលផលបានបង្កើតកម្មវិធីការពារសម្បុកដោយបានជ្រើសរើសអតីតអ្នកដើរប្រមូលពងអណ្តើកឱ្យធ្វើជាអ្នកការពារសម្បុកអណ្តើក។

ក្នុងឆ្នាំ ២០០៦ អង្គការ WCS បានសាងសង់មណ្ឌលសម្រាប់ចិញ្ចឹមថែទាំអណ្តើកមួយស្ថិតនៅក្នុងស្រុកស្រែអំបិល ខេត្តកោះកុង ដើម្បីរក្សាទុកកូនអណ្តើកដែលប្រមូលបានពីតាមឆ្នេរខ្សាច់។ ក្រោយមកក្នុងឆ្នាំ ២០១៦ មណ្ឌលនេះត្រូវបានប្តូរទីតាំងទៅស្រុកមណ្ឌលសីមា ខេត្តកោះកុង ចម្ងាយប្រមាណ ១៥គ.ម ពីក្រុងខេមរៈភូមិន្ទវិញ។

រៀងរាល់ឆ្នាំ កូនអណ្តើកដែលញាស់នៅលើឆ្នេរខ្សាច់តាមប្រព័ន្ធព្រែកស្រែអំបិល ត្រូវបានក្រុមការពារសម្បុកប្រមូលបញ្ជូនទៅកាន់មជ្ឈមណ្ឌលអភិរក្សសត្វល្មូនខេត្តកោះកុងដើម្បីចិញ្ចឹមថែទាំរហូតដល់ធំពេញវ័យទើបយកវាទៅលែងចូលក្នុងទីជម្រកធម្មជាតិរបស់វាវិញ។ ឧទ្យានសត្វព្រៃប្រទេសសឹង្ហបុរី ជាម្ចាស់ជំនួយដ៏សំខាន់មួយក្នុងចំណោមម្ចាស់ជំនួយជាច្រើនដែលបាន ផ្តល់មូលនិធិគាំទ្រដល់គម្រោងនេះ។

បច្ចុប្បន្ន មជ្ឈមណ្ឌលអភិរក្សសត្វល្មូនកោះកុងមានអណ្តើកហ្លួងចំនួន ១៩២ក្បាល។ អណ្តើកហ្លួងជំទង់ចំនួន ៩៦ក្បាល ត្រូវបានលែងចូលទៅក្នុងទីជម្រកធម្មជាតិវិញចាប់តាំងពីឆ្នាំ ២០១៥មក ហើយក្រុមការងារគ្រោងនឹងលែង ៥០ក្បាលទៀតនៅចុងឆ្នាំ ២០២១ខាងមុខនេះ។ អណ្តើកស្ទើរជំទង់និងជំទង់នៅក្នុងមជ្ឈមណ្ឌលនេះ ត្រូវបានចិញ្ចឹមថែទាំនៅក្នុងស្រះបង្កកំណើតចំនួន ៤។ ចំណែកឯអណ្តើកតូចៗ ត្រូវបានដាក់ចិញ្ចឹមនៅក្នុងអាងធំធ្វើពីប្លាស្ទិក មុននឹងផ្ទេរចូលទៅក្នុងស្រះបង្កកំណើត៕







*អណ្តើកហ្លួង (មានឈ្មោះវិទ្យាសាស្រ្តថា Batagur affinis)។* ***រូបភាព៖ អង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា (WCS)***

# ២ខែដំបូង កម្ពុជាបានចំណូលជិត៦៥លាន ដុល្លារ ពីការនាំចេញអង្ករជាង៧ម៉ឺនតោន



*ស្រូវ និងអង្ករផ្ទុកក្នុងរោងម៉ាស៊ីនកិនស្រូវនាពេលកន្លងមក។ រូបភាពៈ សហការី*

*អត្ថបទ៖ ផល សុផានិត*

រយៈពេល២ខែដំបូងឆ្នាំ២០២១ កម្ពុជានាំចេញអង្ករសរុបបានចំនួន៧៦,២២២តោន ដែលមានការធ្លាក់ចុះ ៤៤.១៦% បើធៀបរយៈពេលដូចគ្នា ឆ្នាំ២០២០។

ការធ្លាក់ចុះបរិមាណនាំចេញនេះ ដោយសារបញ្ហាខ្វះកុងតឺន័រដឹក និងតម្លៃដឹកជញ្ជូនតាមផ្លូវសមុទ្រនៅបន្តកើតឡើងខ្ពស់ រហូតដល់ជិត ៥០០% នៃតម្លៃដឹកជញ្ជូនឆ្នាំ ២០១៩។

សហព័ន្ធស្រូវអង្ករកម្ពុជាបញ្ជាក់ថា ការនាំចេញអង្ករជាង៧ម៉ឺនតោន នៅរយៈពេលខែឆ្នាំ២០២១នេះ កម្ពុជាទទួលបានចំណូលជិត៦៥លានដុល្លារអាមេរិក។

ចំពោះទិសដៅទីផ្សារនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល២ខែ ដើមឆ្នាំ២០២១នេះ ប្រទេសចិន ដែលរួមទាំងហុងកុង និងម៉ាកាវ ផងដែរនោះ នៅតែជាទីផ្សារធំជាងគេ នៃការនាំចេញអង្កររបស់កម្ពុជា ដែលមានចំណែកដល់ទៅ ៤៩.៣៧% គិតជាបរិមាណគឺមានចំនួន ៣៧,៦៣០ តោន។

រីឯទីផ្សារធំទី២ គឺជាទីផ្សារសហភាពអឺរ៉ុប ដែលរួមមាន១៨ប្រទេស មានចំណែក២៤.៩១% គិតជាបរិមាណមានចំនួន ១៨,៩៩៦ តោន ក្នុងនោះ ទីផ្សារធំក្នុងសហភាពអឺរ៉ុប គឺប្រទេសបារាំង ដែលមានចំនួន ៨,៨៥០ តោន។

ចំណែកទីផ្សារបន្ទាប់ ដែលមានចំណែក ៨% គឺជាទីផ្សារអាស៊ាន រួមមានម៉ាឡេស៊ី និងសង្ហបុរី ដែលមានចំនួន ៦,២២៩ តោន និងចំណែក ១៨% ទៀត គឺជាទីផ្សារប្រទេសផ្សេងៗ គិតជាបរិមាណគឺមាន ១៣,៣៦៧ តោន ក្នុងនោះរួមមានហ្គាបុងអូស្ត្រាលីអង់គ្លេសនិង ញូហ្សេឡេនជាដើម។

ប្រភេទអង្ករនាំចេញ ក្នុងរយៈពេល២ខែ ដើមឆ្នាំ២០២១នេះ ចំណែកធំជាងគេ គឺ៨៥.៧៧% ជាប្រភេទអង្ករក្រអូបគ្រប់ប្រភេទរួមមាន ផ្ការំដួល, ម្លិះ, សែនក្រអូបជាដើមនោះ ដែលគិតជាបរិមាណមានចំនួន ៦៥,៣៧៤តោន។ អង្ករសត្រូវបាននាំចេញ ១០,១១៦ តោន និងអង្ករចំហុយមាន៧៣២តោន៕

## មួយខែដំបូងឆ្នាំនេះ កម្ពុជាទទួលចំណូល ជិត ៨៥លានដុល្លារ ពីការនាំកៅស៊ូចេញ



*អត្ថបទ៖ ផល សុផានិត*

ក្នុងមួយខែដំបូងដើមឆ្នាំ២០២១នេះ កម្ពុជានាំចេញកៅស៊ូចំនួនសរុប ៥២ ៧១១ តោន និងទទួលបានចំណូលសរុប ចំនួន៨៥ លានដុល្លារអាមេរិកក្នុងថវិការជាតិ។

យោងរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញផ្សាយនៅល្ងាចថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១ បានឱ្យដឹងថា តម្លៃជ័រកៅស៊ូជាមធ្យមមានតម្លៃ ១,៦០៣ដុល្លារ ក្នុង១តោន។ ដូច្នេះចំណូលបានពីការនាំចេញជ័រកៅស៊ូ ក្នុងខែមករា ឆ្នាំ ២០២១នេះ មានចំនួន ៨៤,៤៩៥,៧៣៣ ដុល្លារអាមេរិក។

បច្ចុប្បន្នកម្ពុជាមានផ្ទៃដីផលិតផលជ័រកៅស៊ូចំនួន ៤០៤,១៥៩ហិចតា ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៩២,៤៩៧ហិចតា ស្មើនឹង៧២ភាគរយ និងផ្ទៃដីថែទាំមានចំនួន ១១១,៦៦៣ហិចតា ស្មើនឹង២៨ភាគរយ។

សូមបញ្ជាក់ផងដែរថា ឆ្នាំ២០២០ កម្ពុជាបាននាំចេញជ័រកៅស៊ូជាង ៣៥ម៉ឺនតោន ទទួលបានចំណូលជាង ៤៨២លានដុល្លារ។ ជ័រកៅស៊ូកម្ពុជា បាននាំចេញទៅកាន់ប្រទេសចិន វៀតណាម សឹង្ហបុរី និងម៉ាឡេស៊ី៕

# ការនាំចេញអង្ករនឹងមិនកើនឡើងឡើយនៅត្រីមាសដំបូងដើមឆ្នាំនេះ

*អត្ថបទ៖ អរិយបុត្រ*

លោក សុង សារ៉ន ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានមានប្រសាសន៍ថា ការនាំចេញអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិក្នុងត្រីមាសទី១នៃឆ្នាំនេះនឹងមិនអាចកើនឡើងបានទេ។

លោកបានមានប្រសាសន៍ថា កាលពីខែមករាប្រទេសកម្ពុជាបាននាំចេញអង្ករទៅកាន់ប្រទេសចំនួន ២៨ ដែលមានបរិមាណសរុបចំនួន ៣៤.២៧៣ តោនមានតម្លៃប្រមាណជា ៣០,៧៦ លានដុល្លារពោលគឺថយចុះ ៣២,០៧ ភាគរយខណៈការនាំចេញនៅខែកុម្ភៈនិងខែមីនានឹងបន្តធ្លាក់ចុះ។

លោកបានថ្លែងបញ្ជាក់ថា៖ «ការនាំចេញអង្កររបស់យើងនៅក្នុងខែមករា និងកុម្ភៈ បានធ្លាក់ចុះរួចហើយ ដោយឡែកក្នុងមីនានឹងមានការធ្លាក់ចុះបន្ថែមទៀតដោយសារតែបញ្ហាដឹកជញ្ជូន។ ការដឹកជញ្ជូនគឺជាបញ្ហាប្រឈមចម្បងនៃការធ្លាក់ចុះរបស់យើង»។

យោងតាមការព្យាករណ៍របស់លោក សុង សារ៉ន បានឲ្យដឹងថា ទីផ្សារអង្ករនៅប្រទេសចិនក្នុងត្រីមាសទី ១ នេះនៅតែមានភាពវិជ្ជមាន ប៉ុន្តែអឺរ៉ុបគឺអាចធ្លាក់ចុះខ្លាំង ដោយសារតែវិបត្តិនៃការដឹកជញ្ជូន។

លោកបានបន្តថា នេះមិនមែនជាវិបត្តិក្នុងស្រុកទេ ប៉ុន្តែជាវិបត្តិដឹកជញ្ជូនទូទាំងពិភពលោក ដោយសារតែការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ ដូច្នេះវាជាបញ្ហាប្រឈមចម្បងនៃអង្ករកម្ពុជា។

> “ការនាំចេញអង្កររបស់យើងនៅក្នុងខែមករា និងកុម្ភៈ បានធ្លាក់ចុះរួចហើយ ដោយឡែកក្នុងមីនានឹងមានការធ្លាក់ចុះបន្ថែមទៀតដោយសារតែបញ្ហាដឹកជញ្ជូន”

នៅក្នុងរយៈពេល២ខែដំបូង នៃដើមឆ្នាំ ២០២១ នេះ កម្ពុជា បានសម្រេចនូវការនាំចេញអង្កររបស់ខ្លួន ក្នុងរង្វង់ទឹកប្រាក់ ៦៤,៥៣ លានដុល្លារសហរដ្ឋអាមេរិក និងក្នុងបរិមាណ ៧៦.២២២ តោន ពោលគឺថយចុះ ៤៤.១៦% បើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០២០។

ការថយចុះនេះគឺបណ្ដាលមកពីមូលហេតុចំបងដោយសារកង្វះកុងតឺន័រ និងតម្លៃដឹកជញ្ជូន តាមផ្លូវសមុទ្រនៅបន្តខ្ពស់ រហូតដល់ជិត៥០០% នៃតម្លៃដឹកជញ្ជូនឆ្នាំ ២០១៩។

លោក សុង សារ៉ន បានគូសបញ្ជាក់ថា៖ «យើងមានការបញ្ជាទិញ ប៉ុន្តែយើងមិនអាចរកអ្នកដឹកជញ្ជូនឲ្យគេបាន យើងប្រឈមនឹងកង្វះកុងតឺន័រ»។

លោក សុង សារ៉ន ក៏បានសម្តែងការព្រួយបារម្ភចំពោះការព្យាករណ៍មួយចំនួនស្តីពីការដឹកជញ្ជូននៅលើពិភពលោក ដែលអាចនឹងបន្តជះឥទ្ធិពលបន្តដល់ការនាំចេញអង្កកម្ពុជារហូត ដល់ត្រីមាសទី ២ នៃឆ្នាំនេះ។

ជាមួយនឹងស្ថានភាពបែបនេះ សហព័ន្ធស្រូវអង្ករកម្ពុជាក៏បានបើកកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិការលើកកម្ពស់ទីផ្សារនិងការនាំចេញរបស់ខ្លួនដើម្បីពិភាក្សាអំពីបញ្ហាប្រឈមផ្នែកទីផ្សារជាពិសេសដើម្បីស្វែងរកដំណោះស្រាយ និងយន្តការដើម្បីជំរុញការនាំចេញទៅកាន់ប្រទេសចិន។

កាលពីឆ្នាំ២០២០ ប្រទេសកម្ពុជាបានបង្កបង្កើនផលស្រូវលើផ្ទៃដីសរុបចំនួន ៣.៤០៤.១៣១ ហិកតាដែលអាចប្រមូលបានទិន្នផលសរុបចំនួន ១០.៩៣៥.៦១៨ តោន។ ជាមួយនឹងបរិមាណទាំងនេះប្រទេសកម្ពុជាបាននាំចេញអង្ករសរុបចំនួន ៦៩០.៨២៩ តោន ជាមួយនឹងតម្លៃប្រមាណជាជាង ៥៤០ លានដុល្លារទៅកាន់ទីផ្សារអន្តរជាតិនិងលក់ស្រូវ ប្រមាណជា២.៨៩៣.៧៥០ តោន បានប្រមាណជាជាង ៧២៥ លានដុល្លារទៅកាន់ប្រទេសជិតខាង៕

# បទល្មើសចំនួន៣ ដែលមានសកម្មភាពបំផ្លាញធនធានធម្មជាតិទ្រង់ទ្រាយតូចៗបន្តមាន

*អត្ថបទ៖ ផល សុផានិត*

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន បានបង្ហាញនូវបទល្មើសចំនួន៣ ដែលបន្តយាយីដល់ធនធានធម្មជាតិ គឺការលួចទន្ទ្រានកាន់កាប់ដីព្រៃដោយខុសច្បាប់ ការលួចកាប់ឈើ និងការបរបាញ់សត្វព្រៃក្នុងលក្ខណៈទ្រង់ទ្រាយតូចៗដែលនៅតែបន្តកើតមាននៅក្នុងតំបន់ការពារធនធានធម្មជាតិ ខណៈបទល្មើសធំៗត្រូវបានបង្ក្រាបទាំងស្រុង។



*លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន។ រូបភាព៖ សហការី*

ការបង្ហាញពីបទល្មើសបំផ្លាញធនធានធម្មជាតិក្នុងទម្រង់ទ្រង់ទ្រាយតូចៗបែបនេះរបស់លោក នេត្រ ភក្ត្រា បានធ្វើនៅក្នុងឱកាសដែលលោកបានផ្ដល់បទសម្ភាសដល់ក្រុមអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ នាឱកាសដឹកនាំយុវជនជាង៣០០នាក់ បោះជំរុំរយៈពេល ២ថ្ងៃ នាថ្ងៃទី១៤ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ នៅទីស្នាក់ការគម្ពោតគយ ក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ខេត្តក្រចេះ។

លោក នេត្រ ភក្ត្រា បានគូសបញ្ជាក់ថា ការចុះបង្ក្រាបរបស់គណៈការជាតិបង្ក្រាបនិងទប់ស្កាត់ធនធានជាតិ ដែលដឹកនាំដោយលោក សៅ សុខា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសគឺបានបង្ក្រាបនូវបទល្មើសបំផ្លាញធនធានធម្មជាតិទ្រង់ទ្រាយធំៗ លែងមានទៀតហើយនូវម៉ាស៊ីនអារឈើនៅកណ្ដាលព្រៃ ឬការកាប់បំផ្លាញព្រៃឈើធ្វើអាជីវកម្មខ្នាតធំ ប៉ុន្តែនៅមានបទល្មើសទ្រង់ទ្រាយតូច ដែលមានគោយន្តមានម៉ូតូ និងអត់មានរូបភាពប្រជាពលរដ្ឋឈើលើស្មាដែលសមត្ថកិច្ចចាប់បាននៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃទេ។

អ្នកនាំពាក្យក្រសួងបរិស្ថានរូបនេះ បានបង្ហាញយ៉ាងដូច្នេះថា៖ «ស្ថានភាពនេះដែលកើតឡើងដោយសារ មូលហេតុសំខាន់ដែលពាក់ព័ន្ធនឹងជីវភាពរបស់ប្រជាពលរដ្ឋ ដែលនៅជុំវិញតំបន់ការពារធនធានធម្មជាតិ, ឈ្មួញមួយចំនួនបានញុះញង់ឱ្យប្រជាពលរដ្ឋរស់នៅជុំវិញតំបន់ការធនធានធម្មជាតិ ចូលកាប់ឈើលក់ឱ្យខ្លួន និងពាក់ព័ន្ធនឹងតម្រូវការនៅក្នុងស្រុក មានន័យថាប្រជាពលរដ្ឋចង់បានគ្រឿងសង្ហារឹមដែលធ្វើពីឈើប្រណិត និងឈើប្រភេទឈើធម្មជាតិ»។

ជុំវិញបទល្មើសកាប់បំផ្លាញព្រៃឈើ និងការបំផ្លាញធនធានធម្មជាតិពីសំណាក់ជនខិលខូចនេះដែរ អ្នកនាំពាក្យវ័យក្មេងនិងសកម្មរូបនេះបានបញ្ជាក់ថា ជនល្មើសបានប្រើប្រាស់វិធីសាស្ត្រកាន់តែទំនើបជាងមុន ខណៈមន្ត្រីឧទ្យានុរក្ស នៃក្រសួងបរិស្ថាន អាជ្ញាធរពាក់ព័ន្ធ និងសហគមន៍ដែលរស់នៅជុំវិញតំបន់ការពារធនធានធម្មជាតិបានប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ ដើម្បីទប់ស្កាត់បទល្មើសបំផ្លាញធនធានធម្មជាតិទ្រង់ទ្រាយតូចនេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ រហូតឈានទៅលុបបំបាត់ទាំងស្រុងក្នុងពេលខាងមុខ។

បើតាមលោក នេត្រ ភក្ត្រា បានឱ្យដឹងថា ចំពោះការប្រើប្រាស់នូវឧបករណ៍ទំនើបដែលជនល្មើសប្រើប្រាស់ ដើម្បីធ្វើសកម្មភាពបំផ្លាញព្រៃឈើ និងផ្ដល់ដំណឹងដល់បក្ខពួកខ្លួននៅពេលឃើញមន្ត្រីឧទ្យាននុរក្ស ចុះទៅបង្ក្រាប គឺជនល្មើសទាំងនោះបានប្រើប្រាស់នូវឧបករណ៍អាយកូមជាដើម។ ដោយឡែកចំពោះបទល្មើសវិញ គឺប្រជាពលរដ្ឋដែលរស់នៅតំបន់ការពារធនធានធម្មជាតិ ពួកគាត់មិនទាន់ស៊ាំនឹងការប្រែប្រួលជីវភាព ដូច្នេះហើយវាជាផ្នែកមួយដែលធ្វើឱ្យប្រជាពលរដ្ឋទាំងនោះនៅតែបន្តចូលព្រៃកាប់ឈើ និងបរបាញ់សត្វព្រៃផងដែរ។

ទន្ទឹមនឹងនេះដែរ មន្ត្រីជាន់ខ្ពស់ក្រសួងបរិស្ថានរូបនេះ បានបញ្ជាក់ថា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនេះ ក្រសួងបរិស្ថាន អាជ្ញាធរខេត្ត និងអង្គការជាដៃគូរបានបង្កើតឱ្យមានមុខរបរថ្មី ការពង្រឹងតួនាទីរបស់សហគមន៍នៅជុំវិញតំបន់ការពារធនធានធម្មជាតិឱ្យពួកគាត់បានយល់ពីផលប៉ះពាល់ដែលកើតចេញពីការកាប់បំផ្លាញព្រៃឈើ និងការបរបាញ់សត្វព្រៃ។

លោក នេត្រ ភក្ត្រា បានបន្តថា សម្រាប់ក្រុមឈ្មួញផ្ដល់ថវិកាដល់ប្រជាពលរដ្ឋឱ្យចូលទៅកាប់ព្រៃឈើធម្មជាតិនេះ គឺបណ្ដាលមកពីមានតម្រូវការទីផ្សារក្នុងស្រុក ខណៈការនាំឈើចេញទៅក្រៅប្រទេស គឺមិនមាននោះទេ ដូច្នេះ តម្រូវការឈើធម្មជាតិនៅក្នុងស្រុកបានក្លាយជាបញ្ហាប្រឈមមួយដែលដាក់សម្ពាធទៅលើធនធានធម្មជាតិជាដើម។

ក្នុងការអនុវត្តច្បាប់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ នៅឆ្នាំ២០២០កន្លងទៅនេះ មន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាន និងសហគមន៍ តំបន់ការពារធម្មជាតិ បានចុះល្បាតចំនួន ១,៧២៨លើក បង្ក្រាបបទល្មើសបានចំនួន ១,០១៩ករណី ក្នុងនោះបានបញ្ជូនសំណុំរឿងទៅ តុលាការចំនួន ៤៧ករណី រឹបអូសរណាយន្តបានចំនួន ៤៨១គ្រឿង គោយន្តកន្ត្រៃចំនួន ១១៦គ្រឿង រឹបអូសម៉ូតូចំនួន ៤៧គ្រឿង ដោះអន្ទាក់ចេញពីតំបន់ព្រៃឡង់បានចំនួន ២,៦៣០អន្ទាក់ ដកហូតកាំភ្លើងកែច្នៃចំនួន ១១៧ដើម ដកហូតឈើបានចំនួន ២៧៥ម៉ែត្រគូប ពិន័យអន្តរការណ៍ចំនួន ៦៩ករណី និងធ្វើកិច្ចសន្យានិងអប់រំចំនួន ៣៧៩ករណី៕

# យានយន្តជិត៨៦ ម៉ឺនគ្រឿងចុះបញ្ជីក្នុងឆ្នាំ២០២០

*អត្ថបទ៖ ផល សុផានិត*

ក្រសួងសាធារណការ និងដឹកជញ្ជូន បានបញ្ជាក់ថា នៅឆ្នាំ២០២០ មានយានយន្តចំនួន ៤៥៦,៥៧៤គ្រឿង ក្នុងនោះមានរថយន្តធុនស្រាល ចំនួន៧០,៦៣១គ្រឿង, រថយន្តធុនធ្ងន់ចំនួន១៥,៣៤២គ្រឿង និងម៉ូតូចំនួន៣៧០,៦០១គ្រឿង បានមកចុះបញ្ជីយានយន្ត (ធ្វើផ្លាកលេខ)។

តាមរបាយការណ៍របស់ក្រសួងសាធារណការនិងដឹកជញ្ជូនបានឱ្យដឹងថា បើគិតពីឆ្នាំ២០១៦-២០២០ មានយានយន្តសរុបចំនួន២,៦៥០,១០៧គ្រឿង បានចុះបញ្ជីក្នុងនោះមានរថយន្តធុនស្រាលចំនួន ៣១៨,៣៤៥គ្រឿង, រថយន្តធុនធ្ងន់ចំនួន៧១,៤៦៩ គ្រឿង និងម៉ូតូចំនួន២,២៦០,២៩៣គ្រឿង។

ដោយឡែកការចេញប័ណ្ណបើកបរយានយន្តនៅក្នុងឆ្នាំ២០២០ សរុបចំនួន២៤២,៣០២គ្រឿង ក្នុងនោះមានរថយន្ត ចំនួន១៥៤,៩៦៨គ្រឿង និងម៉ូតូចំនួន១៤,២៦១គ្រឿង។ ចំពោះការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះនៅឆ្នាំ២០២០ ក្រសួងសាធារណការបានធ្វើការត្រួតពិនិត្យ សរុបចំនួន៣៩៧,៧៤៦គ្រឿង។



*យានយន្តគ្រប់ប្រភេទកំពុងធ្វើចរាចរលើផងវិថីក្រម៉ូនស។ រូបភាព៖ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភ្នំពេញ*

កាលពីខែកុម្ភៈ ឆ្នាំ២០២១ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានចេញអនុក្រឹត្យសម្រេចកែសម្រួលអត្រាអាករពិសេសលើមុខទំនិញរថយន្តមួយចំនួន។ ការកែសម្រួលបញ្ចុះអត្រាអាករពិសេស លើមុខទំនិញរថយន្តមួយចំនួននេះនឹងត្រូវចាប់ផ្ដើមអនុវត្តចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១តទៅ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រំពឹងថា ការកែសម្រួលបញ្ចុះអត្រាអាករពិសេសនេះ អាចនឹងទាក់ទាញតម្រូវការប្រើប្រាស់រថយន្តកើនឡើងលើសឆ្នាំ២០២០ ដែលនាំឲ្យចំណូលពន្ធអាករកើនឡើងផងដែរ៕

# ក្រុមសង្គមស៊ីវិលស្នើសុំឱ្យរាជរដ្ឋាភិបាលនិរាករណ៍អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ



*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រុមសង្គមស៊ីវិលជាង៦០ស្ថាប័ន មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលប្រកាសឱ្យប្រើកាលពីថ្ងៃចន្ទ ទី១៦ ខែកុម្ភៈកន្លងមកនេះ និងស្នើសុំឱ្យរាជរដ្ឋាភិបាលនិរាកណ៍អនុក្រឹត្យនេះឱ្យបានឆាប់រហ័ស។

នៅពេលដែលត្រូវបានអាជ្ញាធរដ្ឋអនុវត្តអនុក្រឹត្យនេះ នឹងរឹតត្បិតទៅលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិសេរីភាពក្នុង ការបញ្ចេញមតិ សិទ្ធិក្នុងការទទួលបានព័ត៌មាន សិទ្ធិលើឯកជនភាព ភាពប្រកួតប្រជែងនៃក្រុមហ៊ុនផ្តល់ សេវាអ៊ីនធឺណិតនៅកម្ពុជា ដែលនេះអាចនឹងប៉ះពាល់យ៉ាងខ្លាំងដល់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។ នេះបើតាមការលើកឡើងរបស់ក្រុមសង្គមស៊ីវិលទាំងនេះក្នុងសេចក្តីថ្លែងការណ៍រួម។

ប្រភពដដែលបានឱ្យដឹងថា មាត្រាមួយចំនួននៃអនុក្រឹត្យនេះមានខ្លឹមសារទូលំទូលាយនិងមិនសូវច្បាស់លាស់ និងមានលក្ខណៈរឹតត្បិតយ៉ាងខ្លាំងដល់សិទ្ធិសេរីភាព ជាមូលដ្ឋានរបស់ពលរដ្ឋដែលប្រើប្រាស់អ៊ីនធឺណិត និងភាពប្រកួតប្រជែងនៃប្រតិបត្តិករទូរគមនាគមន៍ នៅកម្ពុជា ។

មាត្រាមួយចំនួនទៀតក្នុងអនុក្រឹត្យនេះបានដាក់កំហិតតួនាទីដល់ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិឱ្យសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជា និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ក្នុងការចាត់វិធានការទប់ស្កាត់ និងកាត់ផ្តាច់ចោលរាល់ការតភ្ជាប់បណ្តាញទាំងឡាយដែលប៉ះពាល់ដល់ចំណូលជាតិ សុវត្ថិភាព របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម សីលធម៌ វប្បធម៌ប្រពៃណី និងទំនៀមទម្លាប់សង្គម។

ក្រៅពីនេះ វាក៏នឹងផ្តល់អំណាចឱ្យអាជ្ញាធរមានសមត្ថកិច្ច ងាយស្រួលក្នុងការចាត់វិធានការរឹតត្បិតលើការទទួលបានព័ត៌មាននៅលើបណ្តាញអ៊ីនធឺណិតឬបិទគេហទំព័រឬបណ្តាញសង្គមណាដែលអាជ្ញាធររដ្ឋយល់ថាមានគំនិតផ្ទុយ ឬរិះគន់រាជរដ្ឋាភិបាល ទោះជាគេហទំព័រ ឬបណ្តាញសង្គមទាំងនោះ បានផ្តល់ព័ត៌មានដែលសាធារណៈមតិយល់ថាជាព័ត៌មាន ឯករាជ្យក៏ដោយ។

ក្រុមសង្គមស៊ីវិលទាំងនេះបានពិនិត្យឃើញថាការបង្កើតអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិនឹងជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ច ជាពិសេសលើភាពប្រកួតប្រជែងតាមប្រព័ន្ធអេឡិចត្រូនិកដែលកំពុងរីកចម្រើននៅកម្ពុជា។

សេចក្តីថ្លែងការណ៍នេះបានបញ្ជាក់ថា ៖ «យើងខ្ញុំទទូចឱ្យរាជរដ្ឋាភិបាលនិរាកណ៍អនុក្រឹត្យនេះឱ្យបានឆាប់រហ័ស ដើម្បីធានាថា សេរី ភាពមូលដ្ឋាន និងធានាប្រសិទ្ធភាពនៃការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋខ្មែរ និងបានជាប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ នឹងត្រូវបានគោរពដោយស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា»។

ជាការឆ្លើយតប ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានការលើកឡើងដោយចោទរាជរដ្ឋាភិបាលមានគោលបំណងចាប់យកទិន្នន័យស្តាប់ការសន្ទនារបស់អ្នកប្រើប្រាស់រឹតត្បិតសេរីភាពនៃការបញ្ចេញមតិនិងយកតាមគំរូរបស់ប្រទេសចិន គឺជាការចោទគ្មានមូលដ្ឋាន មានចរិតនយោបាយផ្ទុយនឹងការពិត ហើយខុសពីគោលបំណងដែលបានចែងក្នុងអនុក្រឹត្យនេះ។

ក្រសួងបានបញ្ជាក់ថា ៖ «ច្រកទ្វារអ៊ីនធឺណិតជាតិត្រូវបានបង្កើតឡើងស្ទើរគ្រប់ប្រទេសទាំងអស់ មិនមែនមានតែការគ្រោងរៀបចំបង្កើតនៅកម្ពុជានោះទេ ហើយការរៀបចំអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបានធ្វើឡើងដោយបើកចំហ និងមានការពិគ្រោះយោបល់ ជាមួយនឹងអ្នកជំនាញក្នុងវិស័យទូរគមនាគមន៍ ប្រតិបត្តិករឯកជន និងស្ថាប័នពាក់ព័ន្ធជាច្រើនលើក»។

ការរៀបចំបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិនេះមានគោលបំណងបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលជាតិ ដោយផ្អែកលើគោលការណ៍ប្រកួតប្រជែងស្មើភាពនិងស្មោះត្រង់ និងតម្លាភាពរវាងរដ្ឋនិងប្រតិបត្តិករ ព្រមទាំងជួយទប់ស្កាត់នូវការលួចតភ្ជាប់បណ្តាញឆ្លងដែនខុសច្បាប់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ការគំរាមកំហែងតាមអ៊ីធឺណិត រូបភាពអាសអាភាស និងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញជាដើម។

ក្រសួងដដែលបានសង្កត់ធ្ងន់ថា ៖ «មិនមានបទប្បញ្ញត្តិណាមួយក្នុងអនុក្រឹត្យនេះចែងអំពីការចាប់យកទិន្នន័យអ្នកប្រើប្រាស់និងការរឹតត្បិតសេរីភាពនៃការបញ្ចេញមត្តិឡើយ»។

ទន្ទឹមនឹងនេះ ក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍គ្រោងនឹងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យឯកជន (Personal Data Protection Law) បន្ទាប់ពីសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (Cybersecurity Law)ត្រូវបានបញ្ចប់ក្នុងពេលឆាប់ៗខាងមុខនេះ៕

# សេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវផ្សេងទៀតត្រូវបានអនុម័ត

*អត្ថបទ៖ អរិយបុត្រ*

សម័យប្រជុំរដ្ឋសភាវិសាមញ្ញនីតិកាលទី៦ ក្រោមអធិបតីភាព សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នៅព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ បានពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

ក្រោយពីបានដំណើរការកិច្ចប្រជុំតាមនីតិវិធីអង្គប្រជុំរដ្ឋសភាបានអនុម័តខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់នេះដែលមាន៦ ជំពូក និង១៨ មាត្រា។ សេចក្តីព្រាងច្បាប់នេះនឹងក្លាយជាយន្តការច្បាប់មួយដ៏សំខាន់ក្នុងការកំណត់អំពីវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលត្រូវអនុវត្តន៍ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ក្នុងពេលបច្ចុប្បន្ននិងពេលអនាគត សំដៅការពារអាយុជីវិតប្រជាពលរដ្ឋលើកកម្ពស់សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង។

រដ្ឋសភាបានថ្លែងកោតសរសើរយ៉ាងក្រៃលែងចំពោះរាជរដ្ឋាភិបាលដែលបានខិតខំដាក់ចេញវិធានការនានានាពេលកន្លងមកដោយបានទប់ស្កាត់ឆ្លើយតបចំពោះការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ធានាបាននូវកិច្ចការពារសុខុមាល ភាពប្រជាពលរដ្ឋ បញ្ហាសង្គម និងសេដ្ឋកិច្ចប្រទេសជាតិ។

សេចក្តីព្រាងច្បាប់ថ្មីដែលកើតចេញជារូបរាងនេះជាសក្ខីភាពកាន់តែច្បាស់បង្ហាញពីកិច្ចខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាលចំពោះអាយុជីវិត និងសុខុមាលភាពប្រជាពលរដ្ឋនៅទូទាំងប្រទេស។

ទាក់ទិននឹងសេចក្តីព្រាងច្បាប់នេះ លោកស្រី ឡោក ខេង ប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីនៃរដ្ឋសភា បានមានប្រសាសន៍ថា សេចក្តីព្រាងច្បាប់ ដែលទើបអនុម័តដោយរដ្ឋសភានាព្រឹកថ្ងៃទី៥ ខែមីនា បានកំណត់ថា បើបុគ្គលណាអ្នកគេចវេះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងចត្តាឡីស័កត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី២លានរៀលទៅ១០លានរៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ១៩ ដល់អ្នកដទៃ។

ដោយឡែក ចំពោះបុគ្គលណាអ្នកគេចវេះពីការព្យាបាលឬគេចចេញពីទីកន្លែងព្យាបាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ ឆ្នាំ ទៅ៥ ឆ្នាំ និងពិន័យជាប្រាក់ពី៥លានរៀល ទៅ២០ លានរៀល និងត្រូវដាក់ពន្ធនាគារពី៥ឆ្នាំ ទៅ១០ ឆ្នាំ កាលបើអំពើខាងលើនេះ បានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ១៩ ដល់អ្នកដទៃ។

លោកម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានប្រសាសន៍ថា ច្បាប់នេះមិនត្រឹមតែជាការចាំបាច់ក្នុងការបង្កើតឱ្យមានមូលដ្ឋានគតិយុត្តមួយរឹងមាំ និងគ្រប់ជ្រុងជ្រោយបន្ថែមទៀតដើម្បីបម្រើដល់ការប្រយុទ្ធ ទប់ស្កាត់ និងបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ដែលកម្ពុជានិងពិភពលោកកំពុងឆ្លងកាត់ប៉ុណ្ណោះទេ ប៉ុន្តែច្បាប់នេះក៏បង្កើតបានជាមូលដ្ឋានមួយដ៏សំខាន់ ដើម្បីបង្កើនភាពម្ចាស់ការត្រៀមលក្ខណៈទុកជាមុន ក្នុងការប្រយុទ្ធទប់ស្កាត់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀតនូវការឆ្លងរាលដាលនៃជំងឺផ្សេងទៀត ដែលមានកម្រិតនៃការឆ្លងរាលដាលកាចសាហាវ ឆាប់រហ័ស និងមានកម្រិតគ្រោះថ្នាក់ធ្ងន់ធ្ងរប៉ះពាល់ដល់អាយុជីវិតប្រជាពលរដ្ឋនិងសុខភាពសាធារណៈ ដែលអាចកើតមានជាយថាហេតុនាពេលអនាគត។

សេចក្តីព្រាងច្បាប់នេះបានត្រូវគណៈរដ្ឋមន្ត្រីអនុម័តកាលពីចុងខែកុម្ភៈ កន្លងទៅ ក្រោយពេលដែលប្រទេសកម្ពុជាបានផ្ទុះករណីឆ្លងជំងឺកូវីដ១៩ ជាសហគមន៍លើកទី៣ ដែលត្រូវបានសន្មត់ហៅថា «ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ»៕

# យុវជនមីយ៉ាន់ម៉ាកំពុងតែក្លាយជាចលករដ៏សំខាន់ នៅក្នុងដំណើរនៃការតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យ

*អត្ថបទ៖ អរិយបុត្រ*

កម្លាំងយុវជននៅក្នុងប្រទេសមីយ៉ាន់ម៉ា ត្រូវបានគេអះអាងថា ជាកម្លាំងស្នូលនៃចលនាតវ៉ាប្រឆាំងនឹងរបបយោធានិយមនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដែលបានឡើងកាន់អំណាចដោយរដ្ឋប្រហារ កាលពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២១ កន្លងមក។

យុវជនមីយ៉ាន់ម៉ា ជាពិសេសនិស្សិតនៅសាកលវិទ្យាល័យបានកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរនយោបាយនិងសង្គមនៅមីយ៉ាន់ម៉ា ខណៈប្រទេសនេះ កំពុងតែស្ថិតនៅក្រោមការគ្រប់គ្រងដោយយោធា។

យុវជននៅក្នុងប្រទេសមីយ៉ាន់ម៉ា ដែលគេសន្មត់កំណត់យកពីក្នុងចំណោមប្រជាជនដែលមានអាយុចាប់ពី ១៥ដល់២៩ ឆ្នាំ មានចំនួនប្រមាណមួយភាគបួននៃចំនួនប្រជាជនរបស់ប្រទេសនេះដោយមាន ៥១,៥% មានអាយុក្រោម ២៨ ឆ្នាំនិង ៥៥% មានអាយុតិចជាង ៣០ ឆ្នាំ។ រហូតមកដល់ពេលនេះក្រុមនិស្សិតនិងយុវជនជាច្រើន ត្រូវបានគេដឹងថា គឺជាសកម្មជន ដឹកនាំសិទ្ធិមនុស្ស និងចលនាប្រជាធិបតេយ្យនានា ហើយនៅក្នុងចលនាតវ៉ាប្រឆាំងនឹង របបយោធាដែលកំពុងតែកាន់កាន់អំណាចនៅក្នុងប្រទេសនេះ ក៏កំពុងតែត្រូវរងសំពាធខ្លាំងដោយ សកម្មជនមកពីក្រុមយុវជននេះផងដែរ។

កាលពីដើមខែមីនា កន្លងទៅនេះ រដ្ឋមន្ត្រីការបរទេសអាស៊ាន ដែលជាអង្គការតំបន់មួយប្រកាន់គោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋសមាជិក ក៏បានរៀបចំកិច្ចប្រជុំ ពិសេសមួយ ដោយរដ្ឋមន្ត្រីការបរទេសអាស៊ានបានជជែកអំពីការគ្រប់គ្រងរបស់របបយោធា នៅក្នុងប្រទេសមីយ៉ាន់ម៉ា។

កិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាននេះគឺកើតឡើងក្រោយពេលដែល អតីតនិស្សិតនៃកម្មវិធីយុវជនអាស៊ាននៅក្នុងប្រទេសមីយ៉ាន់ម៉ាបាននិយាយថា អាស៊ាន គួរតែជជែកជាមួយតំណាងអន្តរជាតិនៃរដ្ឋបាលរបស់លោកស្រី អ៊ុងសាន្ត ស៊ូជី មិនមែនទាក់ទងនឹងរបបយោធានៃប្រទេសនេះទេ។

លិខិតនោះបានសរសេរ ថា៖ «អាស៊ានត្រូវតែយល់ថារដ្ឋប្រហារឬការបោះឆ្នោតឡើងវិញដែលបានសន្យាដោយរបបយោធាគឺមិនអាចទទួលយកបានទាំងស្រុងចំពោះប្រជាជនមីយ៉ាន់ម៉ា»។

ទាក់ទងនឹងសំណើនេះ រដ្ឋមន្ត្រីបរទេសអាស៊ានមិនបានចេញការសម្រេចណាមួយឡើយ ប៉ុន្តែជាគោលការណ៍គេដឹងថា អាស៊ានដែលមាន ១០ប្រទេសគឺជាអង្គការតំបន់មួយ ដែលប្រកាន់នូវគោលការណ៍ កុងសង់ស៊ីស ហើយគោលការគ្រឹះសំខាន់បំផុតគឺមិនលូកដៃចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋសមាជិក។

រដ្ឋមន្ត្រីបរទេសអាស៊ានគឺគ្រាន់តែបានអំពាវនាវឲ្យក្រុមអ្នកនយោបាយស៊ីវិល ដែលដឹកនាំដោយ លោកស្រី អ៊ុងសាន្ត ស៊ូជី និងមេដឹកនាំនយោបាយនៃក្រុមយោធាជជែកគ្នាដើម្បីកសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសនេះឡើងវិញ។

គេនៅមិនទាន់ដឹងថា ជោគវាសនារបស់ប្រជាជាតិមីយ៉ាន់ម៉ា នឹងទៅតាមគន្លងណានោះទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ក្រុមយុវជននៅក្នុងប្រទេសនេះនៅតែបន្តសកម្មភាពនៅក្នុងការខិតខំស្តារនិងកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញ ប៉ុន្តែគេដឹងថា របបយោធានៅក្នុងប្រទេសនេះគឺបានចាក់ឫសគល់ដ៏យូរ ពោលគឺតាំងពីឆ្នាំ ១៩៦២ ដល់ឆ្នាំ២០១១ ហើយនៅឆ្នាំ២០២១ នេះក៏បានបន្តឡើងវិញ។ នៅក្នុងចន្លោះពេលពីឆ្នាំ ២០១១ ដល់ឆ្នាំ២០២១ នេះទោះបីជា លោកស្រី អ៊ុងសាន្ត ស៊ូជី ដណ្តើមបានការគ្រប់គ្រងតាមរយៈការបោះឆ្នោត ប៉ុន្តែអំណាចយោធា គឺនៅតែជាស្នូលនៃការដឹកនាំ ពិតប្រាកដនៅក្នុងឆាកនយោបាយផ្ទៃក្នុងនៅប្រទេសនេះ។

គិតមកដល់ថ្ងៃចន្ទ ទី២៩ ខែមីនា ឆ្នាំ២០២១ ចំនួនបាតុករដែលតវ៉ាប្រឆាំងនឹងរដ្ឋប្រហារយោធារបស់ប្រទេសមីយ៉ាន់ម៉ាចាប់តាំងពីថ្ងៃទី ១ ខែកុម្ភៈមក ត្រូវបានសម្លាប់ដោយកម្លាំងសន្តិសុខ សរុបប្រមាណជា ៥១០ នាក់ ដោយភាគច្រើនគឺយុវជន និងយុវនារី ហើយក៏មានទាំងកុមារមួយចំនួនផងដែរ៕



*ក្រុមយុវជននៅក្នុងប្រទេសមីយ៉ាន់ម៉ានៅតែបន្តសកម្មភាពនៅក្នុងការខិតខំស្តារនិងកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញ។ **រូបភាព៖ បរទេស***

> អាស៊ានត្រូវតែយល់ថារដ្ឋប្រហារឬការបោះឆ្នោតឡើងវិញដែលបានសន្យាដោយរបបយោធាគឺមិនអាចទទួលយកបានទាំងស្រុងចំពោះប្រជាជនមីយ៉ាន់ម៉ា







*ក្រុមនិស្សិតនិងយុវជនជាច្រើន ត្រូវបានគេដឹងថា គឺជាសកម្មជន ដឹកនាំសិទ្ធិមនុស្ស និងចលនាប្រជាធិបតេយ្យនានា។ **រូបភាព៖ បរទេស***



*ក្រុមយុវជននៅក្នុងប្រទេសមីយ៉ាន់ម៉ានៅតែបន្តសកម្មភាពនៅក្នុងការខិតខំស្តារនិងកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញ។ **រូបភាព៖ បរទេស***

# អ្នកម្ដាយមួយរូបបង្កើតសាលាប កុមារអូទីសឹម ដោយខ្លួនឯង ក្រ ជាច្រើនបដិសេធទទួលយកកូន

ការស្រាវជ្រាវជាច្រើនបង្ហាញថា ជំងឺអូទីសឹម (Autism) អាចកើតមានឡើងចំពោះទារក នៅពេលចាប់កំណើតក្នុងផ្ទៃម្ដាយ។ ភាគច្រើនកុមារដែលកើតជំងឺនេះ បង្ហាញរោគសញ្ញា នៅពេលអាយុ ចន្លោះពី៣ខែ ទៅ២ឆ្នាំ។ គេអាចកត់សំគាល់ថាកុមារកើតជំងឺអូទីសឹម ដោយសារកុមារនោះចូលចិត្តនៅម្នាក់ឯង មិនចាប់អារម្មណ៍ចំពោះអ្នកនៅជុំវិញខ្លួន អាយុដល់២ឆ្នាំហើយមិនទាន់ចេះនិយាយ និងពេលខឹងម្ដងៗមិនចង់ឱ្យគេលួងលោមជាដើម។



*សាលារៀនពិសេសដែលទទួលការបណ្ដុះបណ្ដាលកុមារដែលមានបញ្ហាអូទីសឹម។* ***រូបភាព៖ សាលាអប់រំពិសេសនៃការលូតលាស់***

*អត្ថបទ៖ ផល សុផានិត*

ស្រ្តីខ្មែរវ័យ៤០ឆ្នាំមួយរូបបានផ្ដើមគំនិតនិងសម្រេចចិត្តបង្កើតនូវសាលាអប់រំពិសេសមួយសម្រាប់ធ្វើការមើលថែនិងបង្រៀនទៅដល់កុមារមានការលូតលាស់យឺតជាងកុមារទូទៅឬមនុស្សគ្រប់គ្នាតែងស្គាល់និងហៅថា «កុមារអូទីសឹម» បន្ទាប់ពីសាលាជាច្រើនបានបដិសេធទទួលមើលកូនប្រុសរបស់លោកស្រីដែលមានបញ្ហាការលូតលាសយឺត។

លោកស្រី ភោគ ម៉ានី ជាអ្នកដែលផ្ដួចផ្ដើមបង្កើតសាលារៀនដោយបានដាក់ឈ្មោះថា «សាលាអប់រំពិសេសនៃការលូតលាស់ឬហៅជាភាសាអង់គ្លេសថា Growing Special Education School» ដែលត្រូវបានបង្កើតឡើងអ្នកម្ដាយមួយរូបដែលមានកូនប្រុសមានបញ្ហាការលូតលាស់យឺតជាងកុមារធម្មតា។

លោកស្រី បានមានប្រសាសន៍ថា៖ «នេះជាសាលាមួយដែលមានលក្ខណៈខុសប្លែកពីសាលារៀនទូទៅ ក្នុងគោលបំណងសម្រាប់បង្រៀនកូនរបស់ខ្ញុំផ្ទាល់ដែលជាកុមារមានការលូតលាស់យឺតជាងកុមារទូទៅ ឬមនុស្សគ្រប់គ្នាតែងស្គាល់ ឬហៅថាកុមារអូទីសឹម»។



*កុមារអូទីសឹមអាចសិក្សាបាន និងសម្រាលការលំបាកទាំងផ្លូវកាយនិងចិត្តរបស់អ្នកជាអាណាព្យាបាល។* ***រូបភាព៖ សាលាអប់រំពិសេសនៃការលូតលាស់ (Growing Special Education School)***

លោកស្រី បានរៀបរាប់ទៀតថា ផ្ដើមចេញពីអាការៈកូនប្រុសរបស់លោកស្រីដែលមានបញ្ហាការលូតលាស់ យឺតជាងកុមារធម្មតា ហើយស្របពេលដែលសាលារៀនកុមារទូទៅបដិសេធទទួលការបណ្ដុះបណ្ដាលកូនទៀតនោះ ទើបស្រ្តីជាម្ដាយមួយរូបនេះ មានគំនិតនិងសម្រេចបង្កើតនូវសាលារៀនសម្រាប់អប់រំពិសេសមួយនេះឡើង។

លោកស្រី ភោគ ម៉ានី ដែលជានាយិកាសាលាអប់រំពិសេសនៃការលូតលាស់នេះបានប្រាប់ថា៖ «មុនពេលដែលខ្ញុំសម្រេចចិត្តបើកសាលារៀននេះឡើង ដោយសារតែកាលពី៤ឆ្នាំមុន កូនរបស់ខ្ញុំជាកុមារអូទីសឹម ហើយសាលារៀនជាច្រើនបានបដិសេធទទួលកូនប្រុសខ្ញុំ»។

សាលាអប់រំពិសេសនៃការលូតលាស់ ឬហៅជាភាសាអង់គ្លេសថា Growing Special Education School ស្ថិតនៅសង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ Growing Special Education School ជាសាលារៀនពិសេសមួយ ដែលទទួលការបណ្ដុះបណ្ដាលកុមារដែលមានបញ្ហាអូទីសឹម។

បច្ចុប្បន្ន សាលាអប់រំពិសេសនៃការលូតលាស់នេះ ទទួលការបណ្ដុះបណ្ដាលកុមារអូទីសឹម ជាង១០០នាក់ហើយ និងមានគ្រូបង្រៀនពេញសិទ្ធចំនួន ២១នាក់ និងបុគ្គលិកស្ម័គ្រចិត្តមួយចំនួនបន្ថែមទៀត។

ក្រុមគ្រូពេទ្យជំនាញកុមារឱ្យដឹងថា ជំងឺអូទីសឹម គឺជាប្រភេទពិការភាពម្យ៉ាង កើតមានចំពោះកុមារដែលនាំឱ្យប៉ះពាល់ទៅលើការលូតលាស់រាងកាយ សតិបញ្ញាស្មារតី ប៉ះពាល់ទៅលើផ្នែកទំនាក់ទំនងសង្គម និងការស្ដែងចេញនូវអាកប្បកិរិយារបស់កុមារ។ កុមារអូទីសឹម ពិបាកក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ រួមមាន ឪពុកម្ដាយ បងប្អូន និងកុមារដទៃ ដោយបង្ហាញកាយវិការ ចរិតឬកពារខុសប្លែកពីមនុស្សធម្មតា។

លោកស្រី ភោគ ម៉ានី បន្តថា កុមារអូទីសឹមមានអាការៈខុសគ្នាពីកុមារម្នាក់ទៅកុមារម្នាក់ទៀតដោយឡែក កូនលោកស្រីមានអាការៈដូចជា ខាំវ៉ៃ បោកក្បាលនៅជញ្ជាំង មិននៅស្ងៀម រត់រហូតបោះបោករបស់របរដែលនៅជុំវិញខ្លួន។

អ្នកម្ដាយរូបនេះបានលើកឡើងបន្តថា ការអស់សង្ឃឹមខ្លាំងបំផុត កាលពី៦ឆ្នាំមុន លោកស្រី ភោគ ម៉ានី បានស្វែងរកសាលារៀនសម្រាប់កូន រហូតដល់៥សាលា ប៉ុន្តែអ្វីដែលជាក្ដីកង្វល់ធំបំផុត សាលារៀនចុងក្រោយព្រមទទួលការបណ្ដុះបណ្ដាលកូនលោកស្រី តែបានត្រឹមតែ៦ខែប៉ុណ្ណោះ ក៏បញ្ឈប់ការទទួលយល់ព្រមបណ្ដុះបណ្ដាលបន្ត ជាហេតុធ្វើឱ្យអ្នកស្រីអស់សង្ឃឹមថាកូនខ្លួននឹងអាចក្លាយជាមនុស្សធម្មតានៅថ្ងៃអនាគត។

អង្គុយរៀបរាប់ដោយសម្លេងអួលដើមក នាយិកាសាលាអប់រំពិសេសនៃការលូតលាស់ លោកស្រី ភោគ ម៉ានី បានប្រាប់បន្ថែមថា៖ «នៅពេលដែលគេ (សាលារៀន) បញ្ឈប់ការទទួលយល់ព្រមបង្រៀនកូនខ្ញុំតទៅមុខទៀត ខ្ញុំអង្គុយយំអស់

# ណ្តុះបណ្តាល
# ាយសាលា
# មើលថែ



កុមារកំពុងសិក្សានៅក្នុងថ្នាក់រៀនពិសេស។ រូបភាព៖ សាលាអប់រំពិសេសនៃការលូតលាស់

> នេះជាសាលាមួយដែលមានលក្ខណៈខុសប្លែកពីសាលារៀនទូទៅ ក្នុងគោលបំណងសម្រាប់បង្រៀនកូនរបស់ខ្ញុំផ្ទាល់ដែលជាកុមារមានការលូតលាស់យឺតជាងកុមារទូទៅ ឬមនុស្សគ្រប់គ្នាតែងស្គាល់ឬហៅថាកុមារអូទីសឹម



សង្ឃឹមនឹងបន្តទៅមុខទៀត»។

បន្ទាប់ពីការបដិសេធជាបន្តបន្ទាប់មក លោកស្រី ភោគ ម៉ានី សម្រេចចិត្តបើកសាលាអប់រំ ពិសេសសម្រាប់ការលូតលាស់នេះឡើង ដើម្បីជួយដល់កូន និងកុមារអូទីសឹមដទៃទៀត អាចសិក្សាបាន និងសម្រាលការលំបាកទាំងផ្លូវកាយនិងចិត្តរបស់អ្នកជាអាណាព្យាបាល កុមារអូទីសឹម។

លោកស្រី ភោគ ម៉ានី មានប្រសាសន៍ថា៖ «ការបង្កើតសាលានេះដំបូងផ្តើមចេញពីខ្លួនខ្ញុំផ្ទាល់ និងអ្នកជិតខាងមួយចំនួនប៉ុណ្ណោះ។ យើងខ្វះខាតបន្ទប់រៀន អគារយើងតូច (ផ្ទះមួយល្វែង) ប៉ុណ្ណោះតែយើងជួយគ្នា ដើម្បីឱ្យកូនៗយើងបានសិក្សា រៀនសូត្រ និងក្លាយជាមនុស្សធម្មតាទូទៅនៅថ្ងៃអនាគត»។

បើទោះបីជាកង្វះខាតទីតាំង សម្ភារៈផ្សេងៗ កំណើនឡើងនៃចំនួនកុមារអូទីសឹម ពីមួយថ្ងៃទៅមួយថ្ងៃ យ៉ាងណាក៏ដោយ ក៏នាយិកាសាលាអប់រំពិសេសនៃការលូតលាស់ គ្មានគំនិតណាមួយថានឹងបោះបង់ ចោលសាលារៀនពិសេសមួយនេះទេ ដោយសារតែមូលហេតុចម្បងធំបំផុតគឺចង់ឱ្យកុមារអូទីសឹម ទាំងអស់ក្នុងសាលាអប់រំពិសេសនេះ សូម្បីតែម្នាក់ក្នុងចំណោមកុមារទាំងអស់អាចសិក្សាដល់ថ្នាក់ មហាវិទ្យាល័យ និងអាចប្រកបរបរចិញ្ចឹមជីវិតបាននៅថ្ងៃអនាគតពួកគេ។

លោកស្រី ភោគ ម៉ានី បញ្ជាក់ថា៖«គំនិតដែលថាបោះបង់ចោលសាលានេះ គឺគ្មានទេ ព្រោះថា ខ្ញុំសង្ឃឹមថា ទៅថ្ងៃមុខសូម្បីតែកុមារម្នាក់អាចរៀនដល់ថ្នាក់មហាវិទ្យាល័យ នោះជាក្តីបំណងរបស់ខ្ញុំ»។

ងាកមកអាណាព្យាបាលរបស់កុមារអូទីសឹមក្នុងសាលាអប់រំពិសេសនៃការលូតលាស់នេះវិញ អ្នកអាណាព្យាបាលទាំងនោះ មានបំណងចង់ឱ្យសាលារៀនទទួលបង្រៀនកូនរបស់ខ្លួនពេញមួយថ្ងៃ ដើម្បីឱ្យកូនៗរបស់ពួកគាត់អាចឆាប់ក្លាយជាកុមារធម្មតាវិញ។

លោកស្រី ភោគ ម៉ានី បញ្ជាក់បន្ថែមថា៖ «ដូចអ្វីដែលបានឃើញស្រាប់ហើយ អគារយើងតូច យើងមិនអាចទទួលកុមារអូទីសឹមបានពេញមួយថ្ងៃនោះទេ គឺមានតិចភាគរយបំផុត (៦នាក់) នៃកុមារអូទីសឹម ដែលមានការវិវត្តយឺត ដែលយើងអនុញ្ញាតឱ្យរៀននៅទីនេះបានពេញមួយថ្ងៃ។ ក្នុងមួយថ្នាក់យើងដាក់សិស្សបានតែ១០នាក់ និងគ្រូក្នុងមួយថ្នាក់ចន្លោះពី៣ទៅ៥នាក់ តាមការវិវត្តរបស់កូនៗអូទីសឹម»។

តាមការសង្កេតជាក់ស្តែង នៅក្នុងថ្នាក់រៀននីមួយៗនៃសាលាអប់រំពិសេសនៃការលូតលាស់នេះ មានទៅដោយឈ្មោះសត្វជាច្រើនដូចជាដំរី តោ ជាដើម។

ត្រង់ចំណុចនេះ លោកស្រី ភោគ ម៉ានីបានពន្យល់ថា៖ «ឈ្មោះថ្នាក់រៀននេះ គ្រូៗនៅទីនេះជាអ្នកដាក់ឱ្យ ឧទាហរណ៍ សត្វដំរី ជាសត្វធំតែមានការដើរយឺតៗ ដូចជាកុមារអូទីសឹម ដែលមានមាឌធំ អាយុច្រើនតែការវិវត្តយឺតៗដូចគ្នា»។

ប្រសិនបើអាណាព្យាបាលដែលមានកូនៗជួបបញ្ហាអូទីសឹម សូមកុំបោះបង់ចោលក្តីសង្ឃឹម ព្រោះកុមារអូទីសឹមក៏អាចក្លាយជាមនុស្សធម្មតាឡើងវិញគ្រាន់តែយឺតជាងកុមារដទៃទៀតប៉ុណ្ណោះ។ នេះជាការបញ្ជាក់បន្ថែមរបស់លោកស្រី ភោគ ម៉ានី។

លោកស្រីបញ្ជាក់ថា៖ «សូមអាណាព្យាបាលកុំអស់សង្ឃឹម ដូចជាកូនខ្ញុំឥលូវគាត់អាចទៅរៀននៅសាលារដ្ឋធម្មតា (ថ្នាក់ទី៥) អាចជិះកង់ អាចទៅសាលារៀន អាចញ៉ាំអាហារបាន មិនរត់ទៅផ្លូវ មិនបោកក្បាលលើជញ្ជាំងទៀតនោះទេ»។



ក្មេងមួយចំនួនអាចមានសមត្ថភាពក្នុងការរៀនសូត្រ ការគិត និងការដោះស្រាយបញ្ហាបានលឿនយ៉ាងឆាប់រហ័សជាងកុមារធម្មតាទៀតផង។ រូបភាព៖ សាលាអប់រំពិសេសនៃការលូតលាស់ (Growing Special Education School)

កុមារកើតជំងឺអូទីសឹម ភាគច្រើនបង្ហាញរោគសញ្ញាក្នុងអាយុចន្លោះចាប់ពី១ឆ្នាំទៅ២ឆ្នាំ ដូចជាកុមារនោះចូលចិត្តធ្វើកាយវិការក្តាប់ដៃ ទះដៃ បក់ដៃ លោត ដើរប្រើចុងម្រាមជើង យកក្បាលទៅបោកទង្គិចនឹងវត្ថុដែលនៅជិតខ្លួន រឹងរូស ស្រែកយំខ្លាំងៗទាមទារអ្វីមួយ មានអារម្មណ៍ឆាប់ប្រែប្រួល ខឹងឆេវឆាវច្រើន ជាដើម។

បន្ថែមពីនេះ កុមារកើតអូទីសឹម អាយុ១ឆ្នាំហើយ មិនអាចឆ្លើយតបនៅពេលហៅចំឈ្មោះ មិនចូលចិត្តសម្លឹងមើលភ្នែកអ្នកណាឡើយ ច្រើនហូរទឹកមាត់ និងធ្វើអ្វីប្លែកៗ និងសើចខុសទំនងជាដើម ហើយស្ថានភាពរបស់ពួកគេអាចប្រែប្រួលទៅតាមកុមារនីមួយៗ និងកម្រិតពិការភាព។

កុមារអូទីសឹមត្រូវការការយកចិត្តទុកដាក់ និងការគាំទ្រយ៉ាងខ្លាំង ពីសំណាក់ឪពុកម្តាយ និងអាណាព្យាបាល។ ជំងឺអូទីសឹមកើតមានលើកុមារគ្រប់ជាតិសាសន៍។ ការស្រាវជ្រាវបង្ហាញថា ការស្វះស្វែងរកជំនួយភ្លាមៗ ដល់កុមារកើតជំងឺអូទីសឹមនៅពេលកើតថ្មីៗ អាយុតិចនឹងអាចផ្តល់លទ្ធផលជាវិជ្ជមានដល់ពួកគេ ក្នុងជីវិតរស់នៅទៅថ្ងៃអនាគត។

ទោះបីជា អូទីសឹមពាក់ព័ន្ធការលូតលាស់ និងសរសៃប្រសាទក៏ដោយ ក៏ក្មេងមួយចំនួនអាចមានសមត្ថភាពក្នុងការរៀនសូត្រ ការគិត និងការដោះស្រាយបញ្ហាបានលឿនយ៉ាងឆាប់រហ័សជាងកុមារធម្មតាទៀតផងដែរ៕

# កម្ពុជា-សហរដ្ឋអាមេរិក បន្តកិច្ចសហប្រតិបត្តិការ រួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជា និងបង្កើតការងារជូនកម្មករនិយោជិត

*អត្ថបទ៖ អមរិន្ទ ដានុត*

កម្ពុជា-សហរដ្ឋអាមេរិក បានសំដែងនូវការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការជាមួយគ្នាបន្តទៀត ដែលបានចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជា និងការបង្កើតការងារជូនបងប្អូនកម្មករនិយោជិតទោះជាជំងឺកូវីដ១៩បន្តគំរាមកំហែងក៏ដោយ ក៏ការនាំចេញផលិតផលពីកម្ពុជាទៅទីផ្សារមិនមានការធ្លាក់ចុះដែរ។

ការអះអាងបែបនេះធ្វើឡើងរវាង លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ។ ជំនួបនេះគោលបំណង ដើម្បីពិភាក្សាការងារលើវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការកន្លងមក ជាពិសេសកិច្ចសហប្រតិបត្តិការលើការអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនិងបទដ្ឋានការងារអន្តរជាតិ ដែលកម្ពុជាធ្លាប់បានអនុវត្តន៍ប្រកបដោយជោគជ័យជាមួយសហរដ្ឋអាមេរិក តាំងពីឆ្នាំ១៩៩៩ រហូតដល់បច្ចុប្បន្ន។

នាឱកាសនោះ លោកអ៊ិត សំហេង បានថ្លែងអំណរគុណចំពោះភាគីសហរដ្ឋអាមេរិក ដែលទទួលស្គាល់នូវវឌ្ឍនភាពនៃការអនុវត្តសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ការធានាបាននូវលក្ខខណ្ឌការងារ ស្របតាមបទដ្ឋានការងារអន្តរជាតិ ដែលជាកត្តាស្នូលសម្រាប់ភាគីសហរដ្ឋអាមេរិកបន្តផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មដល់កម្ពុជារហូតមកទល់បច្ចុប្បន្ន។

តាមរយៈគម្រោងរោងចក្រកាន់តែប្រសើរឡើងនៅកម្ពុជា ដែលអនុវត្តដោយអង្គការអន្តរជាតិខាងការងារ (ILO) ជាគម្រោងវាយតំលៃប្រកបដោយតម្លាភាពនូវលក្ខខណ្ឌការងារ នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ហើយដែលបច្ចុប្បន្នក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម កំពុងជំរុញការពង្រីកវិសាលភាពអនុវត្តន៍ដល់រោងចក្រផលិតផលិតផលធ្វើដំណើរ និងកាបូប (TGB)។


*លោក អ៊ិត សំហេង (ស្តាំ) រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា។ **រូបភាព៖ សហការី***

ក្រៅពីនេះ ភាគីទាំងពីរក៏បានពិភាក្សាក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើការបន្តលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ការពង្រឹងសមត្ថភាពអធិការការងារតាមរយៈការទស្សនកិច្ចសិក្សានៅសហរដ្ឋអាមេរិកតាមរយៈកម្មវិធី International Visitors Leadership Program on Demand និងការបន្តអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS)។ លោក អ៊ិត សំហេង បានបន្តថា៖ «កិច្ចសហប្រត្តិរវាងក្រសួង និងមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ ក្នុងរយៈពេលកន្លងមកក៏ទទួលបានសមិទ្ធផលជាច្រើន ក្នុងការចូលរួមជួយឱ្យភាគីពាក់ព័ន្ធ ជាពិសេសអង្គការវិជ្ជាជីវៈ កាន់តែមានភាពចាស់ទុំក្នុងការចូលរួមអនុវត្តន៍ច្បាប់ស្តីពីការងារ»។

> ស្ថានភាពអាសន្ន គួរតែត្រូវបានណែនាំដោយគោលការណ៍សិទ្ធិមនុស្ស ហើយទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនគួរយកធ្វើជាលេស ឬជាការដោះសារណាមួយ ចំពោះការបង្ក្រាបក្រុមអ្នកមានមតិប្រឆាំង ឬផលប៉ះពាល់មិនសមាមាត្រា និងអវិជ្ជមានដល់ក្រុមណាមួយផ្សេងទៀតឡើយ

លោកបានបញ្ជាក់ទៀតថា ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបបេឡាជាតិសន្តិសុខសង្គម និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងវិស័យការងារ ដែលទាំងនេះជាផ្នែកមួយដ៏សំខាន់ក្នុងការកាត់បន្ថយនូវវិវាទការងារ ហើយឈានទៅបង្កើតអោយមានសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ។

ទន្ទឹមនេះដែរ លោកឯកអគ្គរដ្ឋទូត ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអនុវត្តបានយ៉ាងល្អក្នុងការចូលរួមធានានូវនិរន្តភាពនៃដំណើរការអាជីវកម្មផលិតកម្ម និងពាណិជ្ជកម្ម តាមរយៈការដាក់ចេញនូវវិធានការ សេចក្តីណែនាំ និងតាមដានត្រួតពិនិត្យមើលការអនុវត្តរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាននានា។

លោកថា ក្រសួងក៏បានចូលរួមដោះស្រាយរាល់បញ្ហានានាប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសការទូទាត់អត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតពេលរោងចក្រព្យួរការងារ និងដោះស្រាយទូទាត់ប្រាក់អតីតភាពការងារ និងអត្ថប្រយោជន៍ពេលរោងចក្របិទទ្វារលែងដំណើរការ ឬរោងចក្រក្ស័យធន ឬម្ចាស់រត់ចោល។

ភាគីទាំងពីរបានឯកភាពគ្នាក្នុងការបន្តពិនិត្យមើលលើចំណុចខ្លះៗនៃបទដ្ឋានគតិយុត្តិ ដែលត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីការអនុវត្តកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ៕

## និពន្ធនាយកសារព័ត៌មានអង្គរធូដេ (Angkor Today) ត្រូវថានបណ្តេញចេញពីកម្ពុជា

*អត្ថបទ៖ ផល សុផានិត*

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានសម្រេចបណ្តេញលោក Shen Kaidong ជាជនជាតិចិន ដែលជានាយកសារព័ត៌មាន Angkor Today ចេញពីប្រទេសកម្ពុជា កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២កន្លងទៅនេះ ក្រោយពីបានផ្សព្វផ្សាយព័ត៌មានបំភ្លៃការពិតថា កម្ពុជាលក់វ៉ាក់សាំងដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន។






ការបណ្តេញជនជាតិចិនរូបនេះ បានធ្វើឡើងបន្ទាប់ពីសមត្ថកិច្ចបានឃាត់ខ្លួន ក្រោយពីបានផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្តាញសង្គម WeChat របស់សារព◌័ត៌មានឈ្មោះ Angkor Today ថា «កម្ពុជាបានយកវ៉ាក់សាំងកូវីដ១៩ ដែលជាជំនួយរបស់ប្រទេសចិនមកលក់ក្នុងតម្លៃថ្លៃ»។ ការផ្សព្វផ្សាយនេះត្រូវបានប្រានចោល និងថ្កោលទោសទាំងស្រុងដោយក្រសួងសុខាភិបាល។

ក្រៅពីបណ្តេញចេញហើយ ជនជាតិចិនរូបនេះក៏ត្រូវបានហាមឱ្យចូលមកប្រទេសកម្ពុជាជាថ្មីផងដែរ។ មិនតែប៉ុណ្ណោះ សារព័ត៌មាន Angkor Today ក៏ត្រូវបានក្រសួងព័ត៌មានកម្ពុជាសម្រេចដកហូតអាជ្ញាបណ្ណផងដែរ។

សារព័ត៌មានក្នុងស្រុក បានស្រង់សម្តីលោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃថា ការបណ្តេញជនជាតិចិនរូបនេះចេញពីកម្ពុជាធ្វើឡើងបន្ទាប់ពីមានសំណើរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ។

លោកបានបញ្ជាក់ឱ្យដឹងថា ជនជាតិចិនរូបនេះ បានចូលមកប្រទេសកម្ពុជាតាំងពីឆ្នាំ២០០៩ ហើយឆ្នាំ២០១៥ បានចាប់ផ្តើមការងារជានិពន្ធនាយកនៅសារព័ត៌មានអង្គរធូដេ (Angkor Today) ប្រចាំខេត្តសៀមរាប ដែលមានទីតាំងនៅភូមិគ្រួស សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានឈ្មោះ អ៊ុង គង្គា ជាចាងហ្វាង។

អ្នកនាំពាក្យរូបនេះ បានបញ្ជាក់ទៀតថា៖ «ជនជាតិចិនរូបនេះ បានទទួលស្គាល់កំហុសវិជ្ជាជីវៈ ដោយសារលោកទទួលបានសារអនាមិកថា មានការយកថ្លៃសេវាចាក់វ៉ាក់សាំងកូវីដ១៩ ប្រមាណ១២០ដុល្លារក្នុងម្នាក់ៗ នៅមន្ទីរពេទ្យកាល់ម៉ែត ហើយបានផ្សព្វផ្សាយបន្ត ដោយមិនបានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា»។

លោកស្រី ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំក្រសួងសុខាភិបាល បានចាត់ទុកថា ការផ្សព្វផ្សាយរបស់ Angkor Today គឺជារឿងផ្តេសផ្តាស់បំផុត។ លោកស្រីបញ្ជាក់ថា មិនមានការលក់វ៉ាក់សាំងកូវីដ១៩នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រដូចការផ្សាយរបស់សារព័ត៌មាននេះឡើយ៕

# ម្ចាស់ពានរង្វាន់ អក្សរសិល្ប៍មេគង្គ តស៊ូរហូតក្លាយជាអ្នកនិពន្ធ



*អត្ថបទ៖ ផល សុផានិត*

សាច់រឿង បូកផ្សំជាមួយទំនុកនិពន្ធដែលមានន័យ និងក្រអួនក្រអៅ គឺជាស្នាដៃនិពន្ធរបស់កញ្ញា លឹម ផាន់ណា ដែលបច្ចុប្បន្ន កញ្ញាជាម្ចាស់ជ័យលេភីពានរង្វាន់អក្សរសិល្ប៍មេគង្គ។

កញ្ញា លឹម ផាន់ណា បានប្រាប់ពីមូលហេតុដែលធ្វើឲ្យខ្លួនក្លាយជាអ្នកនិពន្ធថា កញ្ញាតែងតែសរសេរ កំណាព្យឬរឿងខ្លីៗ បង្ហោះ (Post) នៅក្នុងបណ្ដាញសង្គម (Facebook) របស់កញ្ញា ធ្វើឱ្យមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកលេងក្នុងបណ្ដាញសង្គមមួយនេះ។

មានសម្បុរស រាងស្ដើងខ្ពស់ និងជាកូនទី២ ក្នុងចំណោមបងប្អូនពីរនាក់ក្នុងគ្រួសារនោះ កញ្ញា លឹម ផាន់ណា ជាកូនក្នុងគ្រួសារដែលមានមានជីវភាពមធ្យម។

កញ្ញា លឹម ផាន់ណា ជាអ្នករស់នៅក្នុងរាជធានីភ្នំពេញ និងជាអតីតសិស្សវិទ្យាល័យសន្ធរម៉ុក បច្ចុប្បន្នកញ្ញាបានបញ្ចប់អនុបណ្ឌិតអាហាររូបករណ៍ផ្នែកចិត្តវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជំនាញគណនេយ្យនៅសាកលវិទ្យាល័យមេគង្គកម្ពុជាផងដែរ។

កញ្ញាបានប្រាប់ថា៖ «នាងខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំ២០១២ ពេលថ្មីនេះខ្ញុំកំពុងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែរ»។



*កញ្ញា លឹម ផាន់ណា ម្ចាស់ជ័យលេភីពានរង្វាន់អក្សរសិល្ប៍មេគង្គ។ **រូបភាពៈ សហការី***

នារីវ័យ ២៦ឆ្នាំ និងមានសម្ដីស្រាលៗ កញ្ញា ផាន់ណា បានរំឭកថា ដំបូងឡើយកញ្ញា មិនដែលគិតថា ខ្លួនអាចធ្វើជាអ្នកនិពន្ធបានទេ ធ្លាប់តែស្ដាប់បទចម្រៀង និងលួចសរសើរអ្នកនិពន្ធថា មានគំនិតឆ្លាតវៃ និងពូកែតែប៉ុណ្ណោះ។

ក្រៅតែពីការនិពន្ធបទចម្រៀង ប្រលោមលោក នារីដែលមានរូបសម្រស់ស្រស់ស្អាត មិនចាញ់តារារូបនេះ ក៏ពូកែតែកំណាព្យផងដែរ។ រាល់ការចាប់ផ្ដើមតែងតែជួបការលំបាក គឺជារឿងធម្មតាសម្រាប់ខ្សែជីវិតមនុស្ស។ នេះជាការលើកឡើងរបស់កញ្ញា លឹម ផាន់ណា។

និយាយទាំងស្នាមញញឹម កញ្ញា លឹម ផាន់ណា ថា ធ្វើជាអ្នកនិពន្ធមិនមែនជារឿងងាយស្រួលប៉ុន្មានទេព្រោះកញ្ញាជាមនុស្សម្នាក់ដែលចូលចិត្តស្ដាប់តែបទចម្រៀងជំនាន់ដើម ពោលគឺបទក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ហើយបច្ចុប្បន្នម្ចាស់ផលិតកម្មតម្រូវឱ្យកញ្ញានិពន្ធទំនុកច្រៀងថ្មីៗ ដូច្នេះ ផាន់ណា ត្រូវជួបឧបសគ្គ និងការលំបាកច្រើន។

ជាអតីតសិស្សពូកែនៅក្នុងរាជធានីភ្នំពេញ ផ្នែកអក្សរសាស្ត្រខ្មែរ កាលពីឆ្នាំ ២០០៨ កញ្ញា លឹម ផាន់ណា បានចែករំលែកបទពិសោធខ្លះៗថា ដើម្បីក្លាយខ្លួនទៅជាអ្នកនិពន្ធម្នាក់ តម្រូវឱ្យមានការស្រាវជ្រាវ និងអានឱ្យបានច្រើន ។ កញ្ញា លឹម ផាន់ណា ថា ទម្រាំតែវិវត្តខ្លួនបានមកដល់សព្វថ្ងៃនេះ កញ្ញា បានចំណាយពេលអាន និងស្រាវជ្រាវជាច្រើន ដែលចំណុចទាំងនេះធ្វើឱ្យស្នាដៃនៃការតែងនិពន្ធបានល្អផងដែរ។

ក្រៅពីនិពន្ធបទចម្រៀង ប្រលោមលោក ប្រលោមកំណាព្យ កញ្ញា លឹម ផាន់ណា នៅមានមហិច្ឆតាមួយទៀត គឺចង់ក្លាយខ្លួនជាអ្នកនិពន្ធខ្សែភាពយន្តផងដែរ ទៅថ្ងៃអនាគត។

នាងបានប្រាប់ថា៖ «និយាយទៅខ្ញុំក៏ធ្លាប់ស្រមៃថានឹងក្លាយជាអ្នកនិពន្ធម្នាក់ក្នុងស្ថានីយទូរទស្សន៍មួយ តែក្ដីស្រមៃនេះប្រហែលធំពេកហើយ»។

សូមបញ្ជាក់ថា កញ្ញា លឹម ផាន់ណា កាលពីឆ្នាំ២០០៨ ទទួលបានជ័យលាភី សិស្សពូកែទូទាំងរាជធានី ផ្នែកអក្សរសាស្ត្រខ្មែរ ក្រោយមកកញ្ញាបានទទួលចំណាត់ថ្នាក់លេខ៣ ផ្នែកកំណាព្យក្នុងកម្មវិធី យុវជនស្មគ្រ័ចិត្តអន្តជាតិដែលរៀបចំដោយ UNV និងមានស្នាដៃជាច្រើនទៀត។

ក្នុងនោះកញ្ញា ផាន់ណា ក៏បានបោះពុម្ពផ្សាយស្នាដៃនិពន្ធរបស់ខ្លួនចំនួនពីរក្បាល គឺ





*កញ្ញា លឹម ផាន់ណា ជាអ្នករស់នៅក្នុងរាជធានីភ្នំពេញ និងជាអតីតសិស្សវិទ្យាល័យសន្ធរម៉ុក បច្ចុប្បន្នកញ្ញាបានបញ្ចប់អនុបណ្ឌិតអាហាររូបករណ៍ផ្នែកចិត្តវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជំនាញគណនេយ្យនៅសាកលវិទ្យាល័យមេគង្គកម្ពុជា។ **រូបភាពៈ សហការី***

សៀវភៅ «សោភ័ណជីវិត និងបេះដូងយុវវ័យ» ដែលចងក្រងឡើងដោយការសរសេរជាកំណាព្យសុទ្ធចំនួន១៦៨អត្ថបទ និងចំណាយពេលសរសេរអស់រយៈពេល៨ឆ្នាំ។ ចំណែកសៀវភៅទី២ គឺសរសេរជារឿងខ្លីៗមានចំនួន ៣រឿង ដែលមានចំណងជើងលើក្របមុខថា «បានថើបរសើបបេះដូង»។ ក្រៅតែពីអាជីពជាអ្នកនិពន្ធ បច្ចុប្បន្ន ផាន់ណា ក៏មានការងារផ្សេងទៀត គឺជាអ្នកផ្ដល់យោបល់ផ្នែកសុខភាពផ្លូវចិត្តក្នុងអង្គការមួយផងដែរ៕

# ប្រវត្តិអតីតអភិបាលព្រះសហគមន៍កា
# លោក អ៊ីវ រ៉ាមូស ដែលបានទទួលមរណ
## ជំងឺកូវីដ១៩ នៅ

*(២៣ កុម្ភៈ ១៩២៨ - ២៥ កុម្ភៈ ២០២១)*

*អត្ថបទ៖ ព្រះសហគមន៍កាតូលិកកម្ពុជា*

លោកអភិបាល អ៊ីវ រ៉ាមូស ជាអតីតអភិព្រះសហគមន៍កាតូលិកកម្ពុជា ដែលបានឆ្លងមេរោគកូវីដ-១៩ នៅប្រទេសបារាំង បានទទួលមរណភាពកាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១បន្ទាប់ពីបានបញ្ជូនទៅ សម្រាកព្យាបាលក្នុងមន្ទីរពេទ្យអស់មួយរយៈ។

លោកអភិបាល អ៊ីវ រ៉ាមូស ធ្លាប់ជាអភិបាលព្រះសហគមន៍កាតូលិកនៅកម្ពុជាភូមិភាគភ្នំពេញ ពីឆ្នាំ១៩៦៣-ឆ្នាំ២០០១។

លោកកើតនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩២៨ ក្នុងភូមិសែមបាដែលប្រទេសបារាំង។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៥៣ ហើយលោកបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា កាលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៥៧។

លោកបានទទួលតែងតាំងជាអភិបាលព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៣។ លោកបានបំពេញមុខងារជាគង្វាលដ៏ល្អក្នុងប្រទេសកម្ពុជា។

លោកត្រូវខ្មែរក្រហមបណ្តេញចេញពីប្រទេសកម្ពុជា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥។ នៅឆ្នាំ ១៩៧៦ លោកបានសុំលាលែងពីមុខតំណែងជាអភិបាលភូមិភាគភ្នំពេញ ដើម្បីផ្ទេរឱ្យលោក យ៉ូសែប ឆ្មារ សាឡាស ដែលជាអភិបាលឧបត្ថម្ភក:។

នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៨៣ ដោយសារ លោកអភិបាល យ៉ូសែប ឆ្មារ សាឡាស បានទទួលមរណភាព សម្តេចប៉ាប ក៏បានប្រគល់ឱ្យលោក អ៊ីវ រ៉ាមូស ទទួលខុសត្រូវលើគ្រីស្តបរិស័ទជាតិកម្ពុជា នៅគ្រប់ទីកន្លែងដែលរស់នៅ ព្រមទាំងឱ្យលោកមានភារកិច្ចជាអភិបាលពេញសិទ្ធិក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។

នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩២ សន្តអាសនៈ ក៏បានប្រគល់ឱ្យលោកធ្វើជាអភិបាលទទួលខុសត្រូវលើព្រះសហគមន៍ភូមិភាគភ្នំពេញ ក្នុងនាមសម្តេចប៉ាបជាថ្មីម្តងទៀត។ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ១៩៩២ លោកទទួលមុខងារជាអ្នកណែនាំព្រះសហគមន៍ភូមិភាគបាត់ដំបងរហូតដល់ឆ្នាំ២០០០ ។ លោកបានលាលែងពីមុខតំណែង ជាអភិបាលភូមិភាគភ្នំពេញ នៅថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០០១ ហើយលោកបានចាកចេញពីប្រទេសកម្ពុជាទៅប្រទេសបារាំងវិញក្នុងឆ្នាំ២០១៣។

ឪពុករបស់លោកឈ្មោះ យ៉ាគ រ៉ាមូស ជាបុគ្គលិកផ្លូវដែក និងម្តាយឈ្មោះ យូលី កាលែត។ លោកជាកូនពៅក្នុងចំណោមបងប្អូន៣នាក់។ នៅឆ្នាំ១៩៤២ លោក អ៊ីវ រ៉ាមូស ចូលសិក្សានៅអនុទេវវិទ្យាល័យ La Chartreuse នៅ Brives-Charensac។

ក្នុងឆ្នាំ១៩៤៧ លោកបន្តការសិក្សានៅទេវវិទ្យាល័យ នៃក្រុមសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៥៣។ លោកបានបញ្ចប់ការសិក្សានៅទីក្រុងរ៉ូម និងបានការពារនិក្ខេបបទលើប្រធានបទ The Great Catechesis of Saint Gregory of Nyssa ក្នុងឆ្នាំ១៩៥៧។

នៅពេលមកដល់ប្រទេសកម្ពុជា លោកបានសិក្សាភាសាខ្មែរ និងវៀតណាមនៅ បាណាម (Banam) ហើយបន្ទាប់មកនៅព្រះវិហារសន្តសិលា និងសន្តប៉ូល Saint-Pierre-et-Saint-Paul (Xom Bien) ក្នុងរាជធានីភ្នំពេញ។

នៅឆ្នាំ១៩៦០ លោកត្រូវបានតែងតាំងជាសាស្ត្រាចារ្យនៅទេវវិទ្យាល័យ នៃក្រុងសៃហ្គន មុនពេលផ្លាស់មកបង្រៀននៅអនុទេវវិទ្យាល័យក្នុងក្រុងភ្នំពេញនៅឆ្នាំបន្ទាប់។ នៅឆ្នាំ១៩៦២ លោកត្រូវបានចាត់ឲ្យទៅបង្រៀនរយៈពេលខ្លី នៅទេវវិទ្យាល័យនៃក្រុមសាសនទូតក្រៅប្រទេសនាក្រុងប៉ារីនៅប៊ីវីប្រេស។





នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៦២ សម្តេចប៉ាបបានជ្រើសតាំងលោកជាអភិបាលព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ ដែលមានអាសនៈក្នុងភូមិភាគពីស៊ីតា (the Titular See of Pisita) ពេលនោះលោកមានវ័យត្រឹមតែ៣៥ឆ្នាំ។ លោកទទួលអគ្គសញ្ញាតែងតាំងជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៣ ដោយលោកអភិបាល រ៉ាបាឡង់ នៅក្នុងព្រះវិហាររបស់ទេវវិទ្យាល័យសាសនទូតក្រៅប្រទេសនាក្រុងបារីស (the chapel of the Foreign Missions Seminary -Paris, Franc)។

លោកអភិបាល អ៊ីវ រ៉ាមូស បានចូលរួមក្នុងមហាសន្និបាតវ៉ាទីកង់ទី២ នៅវគ្គទី២ ទី៣ និងទី៤ ។ លោកគឺជាអភិបាលម្នាក់ក្នុងចំណោមអភិបាល១២អង្គ ដែលបានចូលរួមអបអរសាទរខួបលើកទី៥០នៃមហាសន្និបាតវ៉ាទីកង់ទី២ ដែលរៀបចំឡើងដោយ



# តូលិកកម្ពុជា ហភាពដោយសារ ប្រទេសបារាំង









សម្តេចប៉ាប បេណេឌីក ទី១៦ នៅទីក្រុងរ៉ូម កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ក្នុងពេលមហាសន្និបាតក្រុមលោកអភិបាលទូទាំងពិភពលោកស្តីអំពី «ការប្រកាសដំណឹងល្អ» The Synod of Bishops for the New Evangelization។

នៅក្នុងមហាសន្និបាតវ៉ាទីកង់ទី២ លោកអភិបាល អ៊ីវ រ៉ាមូស បានជួបលោកអភិបាលព្រះសហគមន៍ពីររូបមកពីប្រទេសឡាវ គឺលោកអភិបាល អាណូដ៏ (Mgr. Arnaud, MEP) និងលោកអភិបាល លូសដ្រែត៍ (Mgr. Loosdret, OMI)។ នៅឆ្នាំ១៩៦៨ លោកបានបង្កើតសភាក្រុមលោកអភិបាលព្រះសហគមន៍ឡាវ-កម្ពុជា (CELAC) ដែលជួបប្រជុំគ្នាជារៀងរាល់ឆ្នាំ ម្តងប្រជុំនៅប្រទេសឡាវម្តងប្រជុំនៅប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៧៤ ។ ប៉ុន្តែ ការជួបប្រជុំនេះត្រូវផ្អាក ចាប់តាំងពីប្រទេសកម្ពុជាធ្លាក់ក្នុងរបបខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩២ ។

លោកអភិបាលវ័យក្មេង ពេលដែលត្រឡប់មកពីមហាសន្និបាតវ៉ាទីកង់ទី២ គឺពោរពេញដោយភាពរីករាយ។ ជាដំបូងបង្អស់ លោកឈ្វេងយល់អំពីស្ថានភាពបេសកកម្មនៅកម្ពុជា។ លោកបានអញ្ជើញលោកបូជាចារ្យ ប៊ូឡាដ៍ (Fr. Boulard) អ្នកជំនាញសង្គមវិទូ ជាតិបារាំងដ៏ល្បីឈ្មោះ ដើម្បីកំណត់បញ្ហាប្រឈមនានា ក្នុងកិច្ចការព្រះសហគមន៍នៅកម្ពុជា និងឈ្វេងយល់អំពីគម្លាតរវាងព្រះសហគមន៍នៅតាមជនបទ ដែលផ្តោតសំខាន់ទៅលើជនជាតិភាគតិច និងពីស្ថានភាពប្រទេសមួយដែលមាននគរូបនីយកម្មពេញលេញ និងការដឹកនាំដោយគោលនយោបាយជាតិនិយម។

លោកអភិបាល អ៊ីវ រ៉ាមូស បានដាក់ចេញវិធានការពិសេសដោយគោរពតាមស្មារតីនៃមហាសន្និបាតវ៉ាទីកង់ទី២ អំពីការប្រារព្ធពិធីបុណ្យ (Sacrosanctum Concilium) ដោយស្នើសុំឱ្យបូជាចារ្យធ្វើពិធីបុណ្យជាភាសាជាតិ។ វិធានការនេះ ពិតជាមានអត្ថន័យនៅផ្លាស់ប្តូរទំនៀមទម្លាប់ ដែលមានតាំងពីសម័យកាលលោកអភិបាល មីស្ស (Bishop Miche)។

លោកបានឲ្យលោកបូជាចារ្យដែលមកថ្មីត្រូវរៀនភាសាខ្មែរជំនួសភាសាវៀតណាម (១៩៦៦)។ លើលពីនេះទៅទៀត មានគ្រីស្តបរិស័ទមួយចំនួនបានបកប្រែពិធីបុណ្យអភិបូជាមកជាភាសាខ្មែរ។ ការងារបកប្រែព្រះគម្ពីរបានចាប់ផ្តើមនៅពេលនោះ។

សភាក្រុមលោកអភិបាលព្រះសហគមន៍ឡាវ-កម្ពុជា (CELAC) ក៏សម្រេចចិត្តបើកទូលាយទ្វារព្រះសហគមន៍ ដើម្បីស្វែងរកយល់អំពីព្រះពុទ្ធសាសនា។ សន្និបាតមួយបានរៀបចំឡើង សម្រាប់លោកបូជាចារ្យ បព្វជិតបព្វជិតា និងគ្រហស្ថ ក្នុងបំណងបំភ្លឺដល់សាសនទូតទាំងអស់ ដើម្បីមើលឃើញយ៉ាងច្បាស់ ចំពោះស្ថានភាពរបស់បងប្អូនឯទៀតៗមិនទាន់ជឿលើគ្រីស្តសាសនា ដែលនៅក្នុងបេសកកម្មប្រកាសដំណឹងល្អរបស់ពួកគេ។

ក្នុងអំឡុងទសវត្ស១៩៥០ និង១៩៦០ មានយុវជនខ្មែរមួយចំនួនបានទទួលអគ្គសញ្ញាជាបូជាចារ្យ បន្តិចម្តងៗលោកអភិបាល រ៉ាមូស បានអនុញ្ញាតឲ្យអស់លោកបំពេញមុខងារទទួលខុសត្រូវនិងណែនាំព្រះសហគមន៍។ ដោយសារចំណុចនេះហើយ លោកអភិបាល អ៊ីវ រ៉ាមូស បានស្នើទៅក្រុងរ៉ូមដើម្បីបែកព្រះសហគមន៍ភូមិភាគភ្នំពេញជាបីផ្នែក ហើយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៦៨ សន្តអសនៈបានបង្កើតព្រះសហគមន៍ភូមិភាគបាត់ដំបង និងព្រះសហគមន៍ភូមិភាគកំពង់ចាម។

សន្តអសនៈ បានជ្រើសតាំងលោកឪពុកជាតិកម្ពុជា ប៉ូល ទេព អ៊ីមសុត្ថា ជាអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង និងលោកឪពុក អនដ្រេ ឡឺស៊ូអេហ្វ André Lesouëf (MEP) ជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម។ ប៉ុន្តែ ដោយសារខ្វះបូជាចារ្យខ្មែរ គឺមិនអាចផ្ទេរសិទ្ធិទាំងស្រុង ទៅបូជាចារ្យជនជាតិខ្មែរ ដើម្បីណែនាំព្រះសហគមន៍នោះបានទេ។

លោកអភិបាល អ៊ីវ រ៉ាមូស បានសម្រេចចិត្តបង្កើតទេវវិទ្យាល័យមួយនៅជ្រោយចង្វារ ទល់មុខរាជធានីភ្នំពេញ ក្នុងគោលបំណងដើម្បីអប់រំយុវជនឱ្យក្លាយជាគង្វាលថ្មី នៅក្នុងព្រះសហគមន៍កម្ពុជា ហើយក៏ស្របពេលដែលមានសភាពការណ៍តានតឹងខ្លាំងនៅវៀតណាមខាងត្បូងផងដែរ។

លោកអភិបាលបានតែងតាំងលោកឪពុក វ៉ាំងសង់ រ៉ូលីន និងលោកឪពុក អេមីល ដេតម្ប ជាសាស្ត្រាចារ្យ ហើយលោកបានណែនាំនិស្សិតទេវវិទ្យាល័យទាំងអស់ ទៅតាមសភាពការណ៍ជាក់ស្តែងរបស់កម្ពុជាក្នុងអំឡុងឆ្នាំ១៩៦៨-១៩៦៩ ដើម្បីឆ្លើយតបទៅនឹងសេចក្តីណែនាំរបស់សភាក្រុមលោកអភិបាលឡាវ-កម្ពុជា។ ប៉ុន្តែដោយសារស្ថានភាពនយោបាយក្នុងប្រទេសកម្ពុជាប្រែប្រួល នៅឆ្នាំ១៩៧០ទេវវិទ្យាល័យនេះមិនអាចដំណើរការបានឡើងវិញឡើយ។

នៅពេលប្រទេសកម្ពុជាធ្លាក់ក្នុងសង្គ្រាមស៊ីវិល ជនជាតិវៀតណាមទាំងអស់ត្រូវចាកចេញពីប្រទេសកម្ពុជានៅខែមីនា ឆ្នាំ១៩៧០។ គ្រីស្តបរិស័ទកាតូលិកមានជាង៦៥០០០នាក់ នៅសល់តែប្រមាណ៧០០០នាក់ ហើយដូនជីកាតូលិកចំនួនប្រមាណ១៨៥នាក់ នៅសល់តែពីរបីនាក់ ដែលបន្តរស់នៅក្នុងប្រទេសកម្ពុជា ហើយដូនជីទាំងនោះភាគច្រើនបានស្លាប់នៅក្នុងរបបប៉ុលពត។

លើសពីនេះទៅទៀតសង្គ្រាមស៊ីវិល បានធ្វើឱ្យសកម្មភាពសាសនទូតនានាត្រូវគាំង។ លោកអភិបាល អ៊ីវ រ៉ាមូស ក្នុងគ្រានោះបានបដិសេធទទួលជំនួយពីអង្គការ ACRS ដើម្បីកុំឱ្យព្រះសហគមន៍មានមុខជាអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែលោកក៏មិនចូលរួមជាមួយជំរុំមួយក្នុងចំណោមជំរុំទាំងពីរដែរ។

ការវាយសម្រុកចុងក្រោយរបស់ខ្មែរក្រហមចូលរាជធានីភ្នំពេញ នៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៥ បានបង្ខំឱ្យសាសនទូតទាំង





អស់រិះគិតអំពីអនាគតព្រះសហគមន៍កាតូលិកនៅកម្ពុជា។ លោកអភិបាល អ៊ីវ រ៉ាមូស បានអញ្ជើញសាសនទូតទាំងអស់ដែលនៅសល់ក្នុងប្រទេសកម្ពុជា ដើម្បីសម្រេចចិត្តថា តើត្រូវចាកចេញតាមយន្តហោះជម្លៀសចុងក្រោយ ឬក៏ស្នាក់នៅ?

រូបលោកផ្ទាល់បានសម្រេចចិត្តបន្តស្នាក់នៅក្នុងប្រទេសកម្ពុជារួមជាមួយលោកឪពុក រ៉ូប៊ែរ វីណេ លោកឪពុក អេមីល ដេតម្ប និងលោកឪពុក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ ជាបូជាចារ្យនៃក្រុមសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស។

នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៥ លោកបានអញ្ជើញលោកឪពុក យ៉ូសែប ឆ្មារ សាឡាស ដែលសិក្សានៅប្រទេសបារាំង ឲ្យត្រឡប់មកប្រទេសកម្ពុជាវិញបន្ទាន់ ហើយលោកអភិបាលបានទទួលការអនុញ្ញាតពីទីក្រុងរ៉ូម ដើម្បីតែងតាំងលោក យ៉ូសែប ឆ្មារ សាឡាស ជាអភិបាលឧបត្ថម្ភកៈនៃព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ដើម្បីកុំឱ្យគ្រីស្តបរិស័ទនៅក្នុងប្រទេសកម្ពុជាគ្មានអ្នកគង្វាល ព្រោះដឹងច្បាស់ថាគ្រប់សាសនទូតទាំងអស់នឹងត្រូវស្លាប់ឬនឹងត្រូវបណ្តេញពីប្រទេសកម្ពុជា។

នៅថ្ងៃចន្ទ ទី១៤ ខែមេសា ឆ្នាំ១៩៧៥ លោកអភិបាល អ៊ីវ រ៉ាមូស បានប្រារព្ធអគ្គសញ្ញាតែងតាំងលោក យ៉ូសែប ឆ្មារ សាឡាស ជាអភិបាលព្រះសហគមន៍ នៅព្រះសហគមន៍ខ្មែរព្រះវិហារព្រះមាតារាជធានីភ្នំពេញ ដែលមានតែលោកអភិបាល អន់ដ្រេ ឡឺស៊ូអេហ្វ ចូលរួមជាមួយលោក ក្រោមសន្ទឹកនៃគ្រាប់រ៉ុកកែតផ្លោងចូលក្រុងភ្នំពេញ។

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ លោក យ៉ូសែប ឆ្មារ សាឡាស ជាអភិបាលថ្មី បានប្រមូលលោកបូជាចារ្យបរទេសបន្តស្នាក់នៅកម្ពុជា និងលោកបូជាចារ្យខ្មែរ (ប្អូនប្រុសរបស់លោក គឺលោកឪពុក សាឡឹម និងលោកឪពុកសំរើន) នៅគេហដ្ឋានរបស់លោកអភិបាល។ នោះជាពេលដែលបែកគ្នា មុនពេលកងកម្លាំងខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញ (១៧ មេសា ១៩៧៥) លោកអភិបាលថ្មីមានប្រសាសន៍ថា៖ «សូមប្រាប់ពិភពលោកអំពីពួកយើង» លោកបាននិយាយទៅកាន់អស់លោកបូជាចារ្យ ដែលជាពាក្យចុងក្រោយរបស់លោក។

ជនបរទេសទាំងអស់ បានប្រមូលផ្តុំគ្នានៅឯស្ថានទូតបារាំង ហើយ៥សប្តាហ៍ក្រោយមក ខ្មែរក្រហមបានបណ្តេញលោកបូជាចារ្យបារាំងទាំងអស់ ឲ្យចេញពីប្រទេសកម្ពុជាទៅប្រទេសថៃ។ លោកអភិបាល អ៊ីវ រ៉ាមូស ស្រណោះយ៉ាងខ្លាំងដែលខ្លួនលោកត្រូវចាកចេញពីប្រជាជនដ៏ជាទីស្រឡាញ់របស់លោក។

ប៉ុន្មានឆ្នាំក្រោយមក លោកអភិបាល អ៊ីវ រ៉ាមូស បានផ្តល់សក្ខីភាពថា៖ «ការនិរទេសខ្លួនគឺជាការបដិសេធការចាត់ឲ្យទៅបំពេញបេសកកម្ម។ យើងត្រូវបានគេបណ្តេញចេញដូចសម្រាម។ ដូច្នេះ យើងប្រឈមមុខនឹងការចាត់ទុកថាគ្មានបានការ។ សាសនទូតជាច្រើនបានធ្លាក់ទឹកចិត្ត ព្រោះពួកគេមិនអាចបំពេញចន្លោះប្រហោងនៃភាពគ្មានបានការនោះបាន»។

មួយឆ្នាំបន្ទាប់ពីការបណ្តេញចេញពីប្រទេសកម្ពុជា លោកអភិបាល អ៊ីវ រ៉ាមូស បានលាឈប់ពីមុខងាររបស់លោកជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ។ លោកបានទៅប្រទេសឥណ្ឌូនេស៊ី (Tanjung Pinang) ដើម្បីបាននៅជិតប្រទេសកម្ពុជា និងថែរក្សាជនភៀសខ្លួនជាច្រើនដែលបានទៅស្នាក់នៅតាមឆ្នេរនៃប្រទេសនោះ។ ដោយមានការព្រួយបារម្ភ អំពីជនភៀសខ្លួនជាតិកម្ពុជា លោកបានជូនដំណឹងទៅបុរីវ៉ាទីកង់អំពីអនាគតគ្រីស្តបរិស័ទកាតូលិកខ្មែរ។

នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៣ ក្រសួងប្រកាសដំណឹងល្អនៃប្រជាជនទាំងឡាយ បានបង្កើតការិយាល័យគាំទ្រការប្រកាសដំណឹងសម្រាប់ប្រជាជនកម្ពុជា និងបានប្រគល់មុខងារឱ្យលោកអភិបាល អ៊ីវ រ៉ាមូសទទួលខុសត្រូវលើគ្រីស្តបរិស័ទជាតិកម្ពុជា នៅគ្រប់ទីកន្លែងដែលគេរស់នៅ។ លោកអភិបាល អន់ដ្រេ ឡឺស៊ូអេហ្វ បានជួយលោកក្នុងការបំពេញបេសកកម្មនេះ។ គោលបំណងនៅពេលនោះ គឺដើម្បីជួយជនភៀសខ្លួនជាគ្រីស្តបរិស័ទរស់នៅក្រៅប្រទេសឱ្យមានទំនាក់ទំនងជាមួយព្រះសហគមន៍និងភូមិភាគរបស់គេ។ ក្នុងទិសដៅបង្កើតក្រុមគង្វាល ដើម្បីយកចិត្តទុកដាក់មើលថែដល់ប្រជាជនចំណាកស្រុក។

ការដួលរលំប្លុកកុម្មុយនីស្ត និងការដកកងទ័ពវៀតណាមចេញ (១៩៨៩) ជាយុគសម័យថ្មីបានមកដល់កម្ពុជា។ សន្ធិសញ្ញាសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ បានឈានដល់ការបញ្ចប់សង្គ្រាមស៊ីវិល និងបង្កើតរដ្ឋធម្មនុញ្ញថ្មី (ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣) ដែលបើកផ្លូវថ្វាយព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ឡើងគ្រងរាជ្យជាថ្មី។

នៅឆ្នាំ១៩៨៩ លោកអភិបាល អ៊ីវ រ៉ាមូស បានមកប្រទេសកម្ពុជា អរគុណដល់គណៈកម្មាធិការកាតូលិកប្រឆាំងនឹងភាពអត់ឃ្លាន និងដើម្បីការអភិវឌ្ឍ។ ពេលនោះស្ថានភាព ព្រះសហគមន៍កាតូលិកគឺលំបាកណាស់។ ទីសក្ការៈបូជាភាគច្រើន ត្រូវបានបំផ្លាញគ្មានសល់ដូចជាវិសាលវិហារនៅភ្នំពេញ ដែលខ្មែរក្រហមបានបំផ្ទុះគ្រាប់បែកកម្ទេចចោល។ គ្រីស្តបរិស័ទជាច្រើនបានស្លាប់ ឬត្រូវរស់នៅខ្ចាត់ខ្ចាយ។

លោកបូជាចារ្យ និងបព្វជិតបព្វជិតាខ្មែរទាំងអស់ បានបាត់ខ្លួននៅក្នុងពេលស្រុកច្របូកច្របល់។ លើសពីនោះ លោកអភិបាលមិនអាចរស់នៅផ្ទះលោកអភិបាលបានទេ ព្រោះផ្ទះនោះបានក្លាយទៅជាសាលាក្រុងភ្នំពេញទៅហើយ។ លោកក៏មិនអាចជួបជាមួយគ្រីស្តបរិស័ទបានដែរ (មានការហាមឃាត់ប្រជាជនកម្ពុជាទាក់ទងជាមួយជនបរទេស) លោកបានដើរតាមបណ្តោយមហាវិថីព្រះមុនីវង្ស ដោយសង្ឃឹមថានឹងបានជួបអ្នកស្គាល់។

គ្រីស្តបរិស័ទម្នាក់ បាននិយាយជាមួយលោកតែពីរបីម៉ាត់ថា៖ «ពួកយើងកំពុងរង់ចាំលោកនៅភោជនីយដ្ឋានដែលប្អូនថ្លៃខ្ញុំគ្រប់គ្រង»។ លោកអភិបាល បានបង្កើតគណៈកម្មាធិការមួយជាមួយគ្រីស្តបរិស័ទមួយចំនួនតូច ដែលលោកបានជួបនៅក្នុងភោជនីយដ្ឋាននោះ។ ការទាក់ជាមួយបងប្អូនគ្រីស្តបរិស័ទមានដំណើរទៅមុខជាបណ្តើរៗហើយ។

នៅឆ្នាំ១៩៩២ សន្តអសនៈបានប្រគល់មុខងារឱ្យលោកអភិបាល អ៊ីវ រ៉ាមូស ធ្វើជាអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញជាថ្មីម្តងទៀត ប៉ុន្តែមិនមែនដោយគ្មានការលំបាកនោះទេ។ ការធ្វើអន្តរាគមន៍របស់ព្រះមហាក្សត្រ សម្តេចព្រះនរោត្តម សីហនុ ជាមួយលោកអភិបាល ណែនាំឱ្យលោកសម្រេចចិត្តនៅទីនេះ។

ចំណងទាក់ទងរវាងព្រះមហាក្សត្រនិងលោកអភិបាល តែងតែផ្តល់ភាពកក់ក្តៅជានិច្ច។ លោកអភិបាល អ៊ីវ រ៉ាមូស ក៏ត្រូវបានតែងតាំងជាអ្នកមើលថែរក្សាព្រះសហគមន៍ភូមិភាគបាត់ដំបង រហូតដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០០ នៅពេលដែលលោក គីគេ ហ្វីការេដូ ត្រូវបានតែងតាំងជាអភិបាលភូមិភាគបាត់ដំបង។

លោកអភិបាល អ៊ីវ រ៉ាមូស បានសម្រេចចិត្តអនុញ្ញាតឱ្យគ្រីស្តបរិស័ទខ្មែរកសាងព្រះវិហាររបស់ពួកគេឡើងវិញ។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩១ លោកបូជាចារ្យ អេមីល ដេតម្ប បានអញ្ជើញគ្រីស្តបរិស័ទជាគណៈកម្មការព្រះសហគមន៍ចូលរួមក្នុងមហាសន្និបាតព្រះសហគមន៍។

មាន៦០២គ្រួសារ (ប្រហែល៣០០០នាក់ បានទទួលបុណ្យជ្រមុជទឹក) រួមជាមួយគ្រីស្តបរិស័ទ៣៥០នាក់មកពីជំរុំក៏ដូចជាជនជាតិវៀតណាម១ម៉ឺននាក់ដែលមកតាំងទីលំនៅនិងប្រកបមុខរបរនៅស្រុកខ្មែរ។ សន្និបាតបានធ្វើឡើងពីរដងក្នុងមួយឆ្នាំ ដើម្បីរៀបចំសហគមន៍ឡើងវិញ តាមលំនាំនៃព្រះសហគមន៍ដើមដំបូង









ក្នុងកិច្ចការគ្រីស្តទូត ដោយព្រះសហគមន៍បង្កើតគណៈកម្មការចំនួន៣ គឺគណៈកម្មការពិធីបុណ្យ គណៈកម្មការសង្គហៈ និងគណៈកម្មការអប់រំជំនឿ។

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤ លោកអភិបាល អ៊ីវ រ៉ាមូស បន្ទាប់ពីការចរចាជាច្រើនលើកជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា បានបង្កើតចំណងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងសន្តអសនៈ។

នៅឆ្នាំ១៩៩៧ លោកអភិបាល អ៊ីវ រ៉ាមូស បានបង្កើតលក្ខន្តិកៈព្រះសហគមន៍កាតូលិកនៅកម្ពុជា ដែលមានការទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងធម្មការ និងសាសនា។ លក្ខន្តិកៈទាំងនេះ ផ្តល់មូលដ្ឋានគតិយុត្តិដល់ព្រះសហគមន៍ បើកឲ្យមានការទទួលស្គាល់ថា ជាសាសនាមួយមានសិទ្ធិពេញលេញ ហើយមិនមែនជាសមាគមសាសនាឬអង្គការក្រៅរដ្ឋាភិបាលឡើយ។

នៅក្នុងលិខិតផ្លូវការនៅឆ្នាំ១៩៩៦ លោកអភិបាល អ៊ីវ រ៉ាមូស បានសរសេរថា៖ «អាទិភាពក្នុងការកសាងព្រះសហគមន៍នៅកម្ពុជា គឺត្រូវយកចិត្តទុកដាក់បង្កើតឱ្យមានបូជាចារ្យភូមិភាគ»។ លោកបានទៅប្រទេសកាណាដា ដើម្បីជួបជាមួយយុវជន សិលា ទម្លាប់សុផល ដែលលោកមានសេចក្តីសោមនស្ស ធ្វើអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅឆ្នាំ១៩៩៥។ បន្ទាប់មកមានយុវជនពីជំរុំនៅប្រទេសថៃឬជនភៀសខ្លួននៅកាណាដាបានរួមគ្នារស់នៅជាក្រុមនិស្សិតទេវវិទ្យាល័យ នៅដើមឆ្នាំ១៩៩០។ បូជាចារ្យខ្មែរចំនួន៤រូប ត្រូវបានតែងតាំងនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០១។

នៅឆ្នាំ១៩៩៧ លោកអភិបាល អ៊ីវ រ៉ាមូស ស្នើសុំទៅរ៉ូមឱ្យមានអភិបាលឧបត្ថម្ភកៈមួយអង្គ។ លោកបានធ្វើអគ្គសញ្ញាតែងតាំងលោកឪពុក អេមីល ដេតម្ប Emile Destombes (MEP) ជាអភិបាលនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៧ ដែលជាលោកអភិបាលថ្មីបន្តមុខងារពីលោក ជាអភិបាលព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០១។



លោកអភិបាល អ៊ីវ រ៉ាមូស បានបន្តរស់នៅក្នុងប្រទេសកម្ពុជារហូតដល់ឆ្នាំ២០១៤ នៅក្នុងព្រះសហគមន៍កាតូលិកខេត្តព្រះសីហនុ ដែលលោកគឺជាគ្រូគង្វាលមិនចេះនឿយហត់ និងជាទីស្រឡាញ់ ហើយលោកតែងតែត្រៀមខ្លួនក្នុងការផ្តល់ដំបូន្មាន។ ជាមួយបូជាចារ្យព្រះសហគមន៍កាតូលិក គឺលោកឪពុក វីរៈជ័យ (TMS) និងបន្ទាប់មកលោកឪពុក អ៊ុន សុន លោកចូលចិត្តរៀបចំពិធីបុណ្យធំៗយ៉ាងល្អិតល្អន់ និងប្រកបដោយការច្នៃប្រឌិត។ លោកក៏បានសាងសង់អាគារសំណាក់ធម៌នៅខេត្តព្រះសីហនុផងដែរ។

លោកបានចូលនិវត្តន៍ត្រឡប់ទៅនៅម៉ុនបេតុន ប្រទេសបារាំង នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៤។ លោកបន្តអធិដ្ឋានសម្រាប់ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ដែលលោកស្រឡាញ់ និងបម្រើដោយអស់ពីដួងចិត្ត ក្នុងមុខលោកជាបូជាចារ្យ និងជាអភិបាលព្រះសហគមន៍។

លោកបានទទួលមរណភាពដោយមិនអស់ចិត្ត ដោយសារជំងឺកូវីដ-១៩ នៅក្នុងភាពស្ងៀមស្ងាត់ នៅមន្ទីរពេទ្យនាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ ចំពេលត្រូវប្រារព្ធខួបចម្រើនជន្មាយុលើកទី៩៣ (ថ្ងៃទី២៣ ខែកុម្ភៈ) និងទី៥៨ជាអភិបាល (ថ្ងៃទី២៤ ខែកុម្ភៈ)។

ភាពអត់ធ្មត់ ចក្ខុវិស័យ ទស្សនវិស័យ ភាពអង់អាចក្លាហានការលះបង់របស់លោកអភិបាល នាំឱ្យព្រះសហគមន៍កាតូលិកនៅកម្ពុជា បានងើបចេញពីផេះផង់នៅទសវត្សឆ្នាំ១៩៩០។ មនុស្សជំនាន់ក្រោយ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកមិនស្គាល់លោកអភិបាល អ៊ីវ រ៉ាមូសទេ ប៉ុន្តែពួកគេនៅទីនេះសព្វថ្ងៃដោយសេចក្តីរីករាយ និងដើរតាមព្រះគ្រីស្តដោយគុណូបការៈរបស់លោកអភិបាល អ៊ីវ រ៉ាមូស។

សូមលោកអភិបាលជាទីគោរពដ៏ខ្លង់ខ្លស់នៃយើងខ្ញុំ សម្រាកយ៉ាងសុខសាន្ត សុភាពរាបសារ និងរីករាយ ក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់។ អាម៉ែន៕

អត្ថបទរៀបចំ ដោយលោកបូជាចារ្យហ្សាំងសង់ ប្រេចទៀន(MEP) និងលោកអភិបាលអូលីវីយេ ឆ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ៕







# ព្រះសហគមន៍កាតូលិកកម្ពុជា នៅតែចងចាំលោកអភិបាល អ៊ីវ រ៉ាម៉ូស

*(២៣ កុម្ភៈ ១៩២៨ - ២៥ កុម្ភៈ ២០២១)*

*អត្ថបទ៖ ព្រះសហគមន៍កាតូលិកភ្នំពេញ*

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១នេះ បានជូនសៀវភៅដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់តាមរយៈបណ្តាញសង្គមស្តីអំពី «អនុស្សាវរីយ៍បុណ្យសពលោកអភិបាលអ៊ីវ រ៉ាម៉ូស» ដែលត្រូវបានព្រះជាម្ចាស់ត្រាស់ហៅឱ្យចូលរួមនៅក្នុងជីវិតអស់កល្បជានិច្ចដោយសុខសាន្ត កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ដោយសារជំងឺកូវីដ១៩។

នៅក្នុងសៀវភៅនេះ លោកអភិបាលអូលីវីយ៉េ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រមូលនូវគ្រប់សាររំលែកមរណទុក្ខ សក្ខីភាព និងធម្មទេសនាទាំងឡាយនៅក្នុងកម្មវិធីបុណ្យសព ដោយមានអត្ថបទខ្លះជាភាសាខ្មែរ ខ្លះជាភាសាបារាំង និងខ្លះជាភាសាអង់គ្លេស។ ក្រៅពីសារលិខិតទាំងនេះ លោកបានដាក់បញ្ចូលនូវរូបភាពស្រស់ស្អាតជាច្រើន ជាពិសេសលោកបានផ្ញើជូនបងប្អូនគ្រីស្តបរិស័ទនូវតំណភ្ជាប់ទៅកាន់វីដេអូ អំពីជីវិតរបស់លោកអភិបាល អ៊ីវ រ៉ាម៉ូស (ជាភាសាខ្មែរ និងមានអក្សររត់ជាភាសាអង់គ្លេស) ផងដែរ។

លោកអភិបាលអូលីវីយ៉េ ក៏បានថ្លែងអំណរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានលោកអភិបាល អ៊ីវ រ៉ាម៉ូស ជាព្រះអំណោយសម្រាប់ជីវិតព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា។

នៅក្នុងសៀវភៅអនុស្សាវរីយ៍នេះ លោកបូជាចារ្យជនជាតិខ្មែរ ទម្លាប់ សុផល ជាតំណាងព្រះសហគមន៍ភូមិភាគបាត់ដំបង និងធ្លាប់មានទំនាក់ទំនងជាមួយលោកអភិបាលអ៊ីវ រ៉ាម៉ូសតាំងពីឆ្នាំ ១៩៨២ កាលនៅជំរំខាវអ៊ីដាង ក៏បានបង្ហាញសក្ខីភាព និងការចងចាំអំពីលោកអភិបាលអ៊ីវ រ៉ាម៉ូសគិតចាប់ពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ ១៩៨៩ កាលលោកនៅម៉ុងត្រេអាល់ ប្រទេសកាណាដា ពិតជាមានសារសំខាន់ចំពោះលោក ព្រោះកាលលោកបានសម្រេចចិត្តឈប់តាមការត្រាស់ហៅជាបូជាចារ្យ ហើយចាកចេញមករកស៊ីធម្មតាវិញ ប៉ុន្តែលោកអភិបាលអ៊ីវ រ៉ាម៉ូស លោកតាប៉ុងសូង៍ និងលោកវីណេ ត្រូវបានព្រះជាម្ចាស់ផ្ញើឱ្យទៅរកលោក។

លោកសុផល បានបញ្ជាក់នៅក្នុងសារលិខិតថា៖«លោកទាំងបីស្វែងរកខ្ញុំ ដើម្បីនិយាយពីស្ថានភាពព្រះសហគមន៍នៅកម្ពុជា»។

លោកបានបន្តរៀបរាប់ថា ក្រោយពេលដែលលោកទទួលដំណឹងហើយ ចិត្តរបស់លោកក៏ចាប់ផ្តើមប្រែ និងយល់ថានេះជាសំឡេងនៃការត្រាស់ហៅច្បាស់ ដែលព្រះជាម្ចាស់បានរៀបចំផ្លូវសម្រាប់លោក។

លោកបានបញ្ជាក់ទៀតថា ៖ «ក្រោយមក ខ្ញុំបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យពីលោកអភិបាល អ៊ីវ រ៉ាម៉ូស កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៥ ហើយខ្ញុំក៏ជាបេក្ខជនចុងក្រោយដែលលោកបានតែងតាំង និងចាត់ឱ្យទៅតំបន់កំពង់ធំ»។

លោកសុផលក៏បានរំឭកពីអនុស្សាវរីយ៍ដែលលោក អ៊ីវ រ៉ាម៉ូស បានលើកទឹកចិត្តលោកក្រោយពេលលោកបានទៅបំពេញបេសកកម្មប្រកាសដំណឹងល្អនៅតំបន់បាត់ដំបង ដោយលោកអ៊ីវ រ៉ាម៉ូស បានខិតខំបើកឡានទៅមកពីភ្នំពេញតែម្នាក់ឯង៣ដង ទោះបីជាស្ថានភាពផ្លូវកាលនោះមានភាពលំបាកក៏ដោយ។

រីឯលោកបូជាចារ្យ អ៊ុន សុន ក៏បង្ហាញពីសក្ខីភាពរបស់លោកជាមួយលោកអភិបាលអ៊ីវ រ៉ាម៉ូសផងដែរ ដោយលោកលើកយកអនុស្សាវរីយ៍ដែលបានជួបជាមួយលោកអភិបាល អ៊ីវ រ៉ាម៉ូស លើកដំបូងនាឆ្នាំ១៩៨៩ នៅទីក្រុងប៉ារីស ដើម្បីចូលរួមប្រជុំអំពីព្រះសហគមន៍កាតូលិកកម្ពុជា និងអ្នកដែលទទួលការត្រាស់ហៅ និងក្រោយមកនៅជំរំជនភៀសខ្លួនក្នុងប្រទេសថៃ។

លោកសុន បានបញ្ជាក់ថា ៖ «នៅឆ្នាំ១៩៩១ នៅក្រុងម៉ុងត្រេអាល់ ប្រទេសកាណាដា ជាពេលដែលលោក អ៊ីវ រ៉ាម៉ូសបានជួយណែនាំខ្ញុំក្នុងការសម្រេចចិត្តជ្រើសរើសទីកន្លែង និងព្រះសហគមន៍ដែលខ្ញុំត្រូវបម្រើនាពេលអនាគត រវាងក្រុមគ្រួសារបុត្រានៃមេត្តាករុណា និងព្រះសហគមន៍កាតូលិកកម្ពុជា»។

លោកសុនបានបន្ថែមថា ក្នុងឆ្នាំ១៩៩២ ដល់២០១៤ លោករស់នៅស្រុកខ្មែរជាមួយលោកអភិបាល អ៊ីវ រ៉ាម៉ូស និងក្នុងឆ្នាំ២០១២ លោកមានឱកាសបម្រើព្រះសហគមន៍មណ្ឌលសកម្មភាពកំពង់សោម ពេលនោះហើយដែលរូបលោកបានរៀនពីស្នាដៃដ៏អស្ចារ្យពីលោកជាច្រើនដូចជា។ ស្នាដៃទាំងនោះមាន ជាអ្នកគង្វាលដែលមានសេចក្តីស្រឡាញ់តាមរកកូនចៀមនៅគ្រប់ប្រទេស ជាស្ថាបនិកដែលធ្វើឱ្យមណ្ឌលសកម្មភាពក្រុងព្រះសីហនុក្លាយទៅជាកន្លែងទទួលស្វាគមន៍ស្នាក់នៅសម្រាប់សកម្មភាពនានា ហើយលើសពីនេះទៅទៀត លោកបានសាងសង់គ្រប់អគារព្រះវិហារ ដែលស្ថិតនៅក្នុងមណ្ឌលសកម្មភាពក្រុងព្រះសីហនុ រួមមាន៦ព្រះសហគមន៍ ព្រមទាំងកម្មវិធីអប់រំផងដែរ។

ចំណែកលោកបូជាចារ្យ សួន ហង្សលី ក៏បានលើកឡើងអំពីសក្ខីភាពរបស់លោក ជាមួយលោកអភិបាលអ៊ីវ រ៉ាម៉ូស កន្លងមកដែលបានធ្វើឱ្យលោកចាប់អារម្មណ៍ទៅលើពាក្យពឃ្លាគឺ សេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់ និងការទទួលរាក់ទាក់ ដែលជាគំរូសម្រាប់ទាំងអស់គ្នា។

លោកលីលើកឡើងថា ៖ «សេចក្តីស្រឡាញ់របស់លោកអភិបាល នៅពេលដែលខ្មែរក្រហមចូលកាន់កាប់ក្រុងភ្នំពេញ គេបណ្តេញជនបរទេសទាំងអស់ ប៉ុន្តែលោកអភិបាលមិនចង់ចាកចេញទេ និងពេលលោកចេញទៅក្រៅប្រទេស លោកមិនបានបោះបង់ចោលបងប្អូនខ្មែរទេដោយលោកដើរស្វែងរកជនជាតិខ្មែរភៀសខ្លួននៅក្រៅប្រទេស»។

លោកលីបានបន្តទៀតថា ក្នុងសម័យដែលលំបាកមែនទែន លោកអ៊ីវ រ៉ាម៉ូសមិនដែលត្អូញត្អែរក្នុងការបម្រើព្រះសហគមន៍ ហើយលោកតែងតែចាប់អារម្មណ៍ និងយកចិត្តទុកដាក់នៅក្នុងប្រទេសកម្ពុជា។

លោកបន្ថែមថា លោកអភិបាល អ៊ីវ បានយកសេចក្តីសម្រេចរបស់មហាសន្និបាតវ៉ាទីកង់ទី២មកអនុវត្តន៍ក្នុងកម្ពុជា ដើម្បីឱ្យមានវប្បធម៌ខ្មែរចូលក្នុងពិធីបុណ្យរបស់ព្រះសហគមន៍ និងបានយកចិត្តទុកដាក់រៀបចំទីសក្ការបូជា ព្រមទាំងយកចិត្តទុកដាក់រៀបចំធម្មទេសនាបានល្អ។

អ្នកស្រី យូរ ប្រាកដ បានរៀបរាប់ពីការចងចាំរបស់អ្នកស្រីដែលបានស្គាល់លោកអភិបាលអ៊ីវ រ៉ាម៉ូសតាំងពីអាយុ១១ឆ្នាំ និងបានទទួលអគ្គសញ្ញាជ្រមុជទឹកពីលោកកាលពីអាយុ១៤ឆ្នាំ។

អ្នកស្រីប្រាកដបានរំឭកថា ៖ «លោកអភិបាល អ៊ីវ រ៉ាម៉ូស បានយកចិត្តទុកដាក់ប្រើគ្រប់មធ្យោបាយ ដើម្បីជួយដល់អស់បងប្អូនទាំងគ្រីស្តបរិស័ទ និងមិនមែនជាគ្រីស្តបរិស័ទដែលត្រូវបានជិះជាន់ដោយទាហាន លន់ ណុល»។

លោកស្រីថា លោក អ៊ីវ រ៉ាម៉ូស ត្រូវបានគេដាក់នៅក្នុងបន្ទប់ឃុំឃាំង អត់បាយ អត់ទឹក អត់ថ្នាំជាដើម។ នៅឆ្នាំ១៩៧៩ លោកបានវិលត្រលប់ចូលស្រុកខ្មែរម្តងជាពីរដង ដើម្បីស្វែងរកគ្រីស្តបរិស័ទ និងនៅឆ្នាំ១៩៨៨ លោកអភិបាលបានជួបគ្រីស្តបរិស័ទ៧ទៅ៨នាក់ដែលរួចពីស្លាប់ និងបានបង្កើតគណៈកម្មការព្រមទាំងឆ្លៀតសរសេរប្រវត្តិព្រះសហគមន៍កាតូលិកនៅកម្ពុជា និងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ ហើយជាលទ្ធផលព្រះសហគមន៍កាតូលិកមានសិទ្ធិក្នុងការប្រកាសដំណឹងល្អរបស់ខ្លួន កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩០។

អ្នកស្រី ប្រាកដ បានបន្តថា ៖ «លោកអភិបាលបានទៅគ្រប់ទីកន្លែងដើម្បីប្រមូលគ្រីស្តបរិស័ទ និងលើកទឹកចិត្តពួកគេឱ្យរក្សាជំនឿដោយទុកចិត្តលើព្រះជាម្ចាស់ ហើយលោកអត់មានភ័យខ្លាចអ្វីឡើយ ទោះជាផ្លូវលំបាកវេទនាយ៉ាងណាក៏លោកនៅតែតស៊ូទៅគ្រប់ទីកន្លែងដើម្បីស្វែងរកកូនចៀមរបស់ព្រះជាម្ចាស់»។

លោក អ៊ីវ រ៉ាម៉ូស កើតនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩២៨ នៅភូមិសែមបាដែល Sembadel (Haute-Loire- France) ជាក្រុងមួយស្ថិតនៅក្នុងភូមិភាគពុយ។ លោកជាកូនពៅក្នុងចំណោមបងប្អូន៣នាក់។ នៅឆ្នាំ១៩៤២ លោក អ៊ីវ រ៉ាម៉ូស ចូលសិក្សានៅអនុវិទ្យាល័យនៃក្រុមសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស ។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៥៣។ ក្រោយពីបានបញ្ចប់ការសិក្សានៅក្រុងរ៉ូម ក្នុងឆ្នាំ១៩៥៧ លោកបានចេញដំណើរមកប្រទេសកម្ពុជានៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៧៕

# វិបត្តិកូវីដ ពិធីបុណ្យហែស្លឹកឆ្នាំនេះ ប្រារព្ធដោយភាពស្ងប់ស្ងាត់

*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*



នៅថ្ងៃទី២៨ ខែមីនា ឆ្នាំនេះ ព្រះសហគមន៍កាតូលិកកម្ពុជា បានប្រារព្ធពិធីបុណ្យហែស្លឹកមានលក្ខណៈ ខុសប្លែកជាងបណ្ដាឆ្នាំមុនៗ ដោយពិធីនេះមានគ្រីស្ដបរិស័ទចូលរួមតិចតួចបំផុត មិនដូចរាល់ឆ្នាំ ដែលអាចប្រារព្ធយ៉ាងឱឡារិក ក៏ព្រោះតែកម្ពុជាកំពុងរងការរាតត្បាតយ៉ាងខ្លាំងនូវជំងឺកូវីដ ១៩ ក្នុងសហគមន៍។

តាមប្រសាសន៍ណែនាំរបស់លោកអភិបាល អូលីវីយ៉េ ឆ្មីតហាស្លេរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញដែលបានថ្លែងនៅក្នុងធម្មទេសនាថា រដូវ៤០ថ្ងៃដែលព្រះសហគមន៍អញ្ជើញឱ្យធ្វើដំណើររួមជាមួយព្រះយេស៊ូ ដើម្បីទទួលមរណភាពនៅក្រុងយេរូសាឡឹម។

លោកថា ៖«ខ្ញុំស្ដាយ ដោយសារឆ្នាំនេះយើងបានរៀបចំ សម្ដែងអំពីរឿងនេះអស់ពីសមត្ថភាព ប៉ុន្ដែដោយសារកូវីដ១៩ យើងសម្ដែងមិនបាន។ នៅពេលយើងឃើញផ្ទាល់ភ្នែក យើងឈឺចិត្តណាស់ ឈឺក្នុងដួងចិត្តរបស់យើងមែនទែន។ ប្រហែលយើងបានគិតថា ដូចគេបានគិតពីដើមនៅពេលគេសម្លាប់ព្រះយេស៊ូ តាមពិតនេះជារបៀបដែលខ្វះខ្នាយ ស្ដាយណាស់ ស្ដាយដែលគេសម្លាប់ព្រះយេស៊ូ»។

ជាមួយគ្នានេះដែរ លោកអភិបាលរូបនេះបានពញ្ញាក់ស្មារតីគ្រីស្ដបរិស័ទភូមិភាគភ្នំពេញទាំងអស់នៅក្នុងឆ្នាំ២០២១នេះឱ្យរិះគិតឡើងវិញនូវបញ្ហាដែលកំពុងកើតមាននៅលើពិភពលោក។ លោកអភិបាលអូលីវីយ៉េ ថ្លែងថា៖ «តើយើងមានគំនិតច្រើនទេសព្វថ្ងៃ ដើម្បីកែប្រែចិត្តគំនិត និងជួយឱ្យពិភពលោកមានការផ្លាស់ប្ដូរ? ពិភពលោករបស់យើងសព្វថ្ងៃយំសោកខ្លាំងណាស់ ពិភពលោករបស់យើងដូចជា ព្រួយបារម្ភនិងរងទុក្ខលំបាកយ៉ាងច្រើនដែរ»។

លោកអភិបាលអូលីវីយ៉េ បន្តថា ពិភពលោកបច្ចុប្បន្ននេះកំពុងតែខ្វះខ្នាយ ដូចជាការចំណាយទៅលើម្ហូបអាហារ អាវុធ សំលៀកបំពាក់ ការធ្វើសង្គ្រាម អំពើហឹង្សា ភេរវកម្ម ការកាប់បំផ្លាញព្រៃឈើ ការលុបបឹង និងការបំផ្លាញធម្មជាតិជាដើម។

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានលើកឡើងថា ៖ «កូវីដ១៩កើតឡើងដោយសារយើងខ្វះអនាម័យ។ ប្រហែលប៉ុន្មានឆ្នាំកន្លងមកយើងរស់នៅខ្វះអនាម័យខ្លាំងណាស់។ ទម្លាប់របស់យើងអំពីការថែរក្សាសុខភាពក៏មានកម្រិតខ្លាំងណាស់ដែរ។ ចេះតែញ៉ាំម្ហូបដែលអត់មានប្រយោជន៍ ចេះតែអង្គុយមើលទូរស័ព្ទ មើលទូរទស្សន៍ ប៉ុន្ដែភ្លេចហាត់ប្រាណ»។

លោកបន្ដថា ៖«ប្រហែលដោយសារកន្លងមកនេះ យើងមិនបានថែរក្សាសុខភាពរបស់យើងបានត្រឹមត្រូវ។ នៅពេលនេះយើងឃើញបងប្អូនរបស់យើងដែលបានស្លាប់ដោយ ជំងឺកូវីដ១៩ ហើយអ្នកដែលស្លាប់ គឺអ្នកដែលមានសុខភាពទន់ខ្សោយរួចហើយ»។

បន្ថែមលើពីនេះ លោកអភិបាល អូលីវីយ៉េ បន្តថា ការខ្វះខ្នាយសព្វថ្ងៃនេះ របស់មនុស្សទៅលើការខ្វះនូវពេលវេលា ដោយបណ្ដោយខ្លួនទៅលើគ្រឿងអេឡិចត្រូនិច ភ្លេចបង្កើននូវទំនាក់ទំនងសង្គម ដោយភ្លេចយកចិត្តទុកដាក់លើមនុស្សដែលកំពុងតែទទួលរងទុក្ខលំបាក៕

# ពលរដ្ឋប្រមាណ១០០គ្រួសារក្នុងភូមិជ្រៃធំ ស្រុកកោះធំ ទទួលបានអំណោយរបស់អភិបាលភូមិភាគភ្នំពេញ



*អត្ថបទ៖ ព្រះសហគមន៍កាតូលិកភ្នំពេញ*

អំណោយជាគ្រឿងឧបភោគបរិភោគរបស់លោកអភិបាល អូលីវីយ៉េ ឆ្មីតហាស្លេរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានប្រគល់ជូនដល់ប្រជាពលរដ្ឋមានជីវភាពខ្វះខាតដែលកំពុងរស់នៅកន្លែងដែលត្រូវបានហាមចេញចូលដោយសារបារម្ភពីការប៉ះពាល់នឹងអ្នកមានវីរុសកូវីដ១៩។

ការចែកជូននូវគ្រឿងបរិភោគ តាមរយៈអង្គការការីតាសកម្ពុជា សហការជាមួយនឹងព្រះសហគមន៍ជ្រៃធំ ព្រះវិហារសន្តយ៉ូសែប ក្នុងស្រុកកោះធំ ខេត្តកណ្ដាល ទៅដល់ប្រជាពលរដ្ឋចំនួនប្រមាណ១០០គ្រួសារដែលស្ថិតនៅក្នុងកន្លែងហាមឃាត់ចេញក្រៅភូមិ ដោយបញ្ហាកូវីដ ១៩ នាពេលកន្លងមកនេះ។

គ្រួសារក្រីក្រមួយគ្រួសារដែលស្ថិតនៅកន្លែងហាមឃាត់ និងបាត់បង់ការងារពាសប្ដាហ៍មក ហើយប្រកាសថ្លែងអំណរគុណទាំងអំណរសប្បាយ ក្រោយពេលដែល ក្រុមសង្គហៈព្រះសហគមន៍បានយកអំណោយទៅចែកជូនដល់លំនៅឋាន។

គ្រឿងឧបភោគបរិភោគដែលត្រូវបានផ្ដល់ដោយលោកអភិបាលអូលីវីយ៉េមាន ទឹកត្រី អង្ករ មី ទឹកស៊ីអ៊ីវ និងត្រីខកំប៉ុង។

តាមការបញ្ជាក់របស់បងស្រី ម៉ាថា ជាដូនជីកាតូលិក និងជាតំណាងគណៈកម្មការព្រះសហគមន៍មណ្ឌលសកម្មភាពទន្លេបាសាក់ បានថ្លែងអំណរគុណដល់លោកអភិបាលអូលីវីយ៉េ ក្នុងនាមតំណាងឱ្យព្រះសហគមន៍ជ្រៃធំ ដែលតែងតែយកចិត្តទុកដាក់ នឹកនាដល់កូនចៅនៅទីនេះ។

បងស្រីបន្តថា៖ «ពួកកូនមិនដឹងយកពាក្យអ្វីមកអរគុណលោកអភិបាលទេ ប៉ុន្ដែពួកកូនសូមអង្វរព្រះជាម្ចាស់សូមថែរក្សាការពារលោកអភិបាលឱ្យមានសុភាពល្អ និងអំណរសប្បាយ»។

ដោយមានអ្នកវិជ្ជមានជំងឺកូវីដ១៩នៅតំបន់ជ្រៃធំ អាជ្ញាធរបានសម្រេចបិទការចេញចូល និងដាក់តំបន់នោះជាតំបន់ហាមឃាត់កាលពីសប្ដាហ៍មុន។ ស្ថិតនៅក្នុងស្ថានភាពបែបនេះ លោកអភិបាលអូលីវីយ៉េ បានសម្រេចជូននូវគ្រឿងបរិភោគដល់ប្រជាជនក្រីក្រ និងចាស់ជរា។

អំណោយទាំងនោះបានទៅដល់ព្រះសហគមន៍ជ្រៃធំ កាលពីថ្ងៃទី១៦ មីនា ២០២១កន្លងទៅនេះ និងបានចែកជូនជនក្រីក្រ ចាស់ជរា ដែលស្ថិតនៅក្នុងតំបន់ហាមឃាត់ក្នុងមួយថ្ងៃ២០គ្រួសារគិតចាប់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១មក៕

# បេក្ខជន១២នាក់នៃមណ្ឌលសកម្មភាពទន្លេមេគង្គទទួលពិធីជម្រះចិត្តគំនិតលើកទីពីរ

*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*

បេក្ខជន១២នាក់នៃមណ្ឌលសកម្មភាពទន្លេមេគង្គទទួលពិធីជម្រះចិត្តគំនិតលើកទីពីរ ដែលជាពិធីមួយនៅក្នុងប្រពៃណីព្រះសហគមន៍កាតូលិក មុននឹងបេក្ខជនទទួលពិធីជ្រមុជទឹកនាថ្ងៃបុណ្យចម្លងខាងមុខ។

ពិធីនេះធ្វើនៅព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយ៉េ នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១កន្លងមកនេះ ដែលណែនាំដោយលោក វីរៈជ័យស្រ៊ីប្រាម៉ុង ជាបូជាចារ្យទទួលបន្ទុកព្រះសហគមន៍មណ្ឌលសកម្មភាពទន្លេមេគង្គ ដោយបានប្រកាន់ខ្ជាប់នូវការអនុវត្តតាមវិធានណែនាំរបស់ក្រសួងសុខាភិបាល។

តាមប្រសាសន៍លោកបូជាចារ្យវីរៈជ័យ បានឱ្យដឹងថា ពិធីជម្រះចិត្តលើកទីពីរនេះ ព្រះសហគមន៍អាចហៅម្យ៉ាងទៀតបានថា «ពិធីអេប្បាថា» គឺជាពិធីបើកឡើង និងអត្ថបទព្រះគម្ពីរដែលព្រះសហគមន៍បានប្រើកាលពីថ្ងៃអាទិត្យគឺ ព្រះយេស៊ូបានប្រោសមនុស្សខ្វាក់ម្នាក់ឱ្យបានជា។ លោកបញ្ជាក់ថា៖ «នៅក្នុងពិធីព្រះសហគមន៍សូមឱ្យបេក្ខជនបើកដួងចិត្តទទួលសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់»។

លោកបន្តថា ពួកគាត់ស្រឡាញ់ព្រះជាម្ចាស់ គាត់នឹងអាចស្រឡាញ់អ្នកដទៃ ចេះលើកលែងទោសឱ្យអ្នកដទៃ ទោះបីពីមុនគាត់មិនសូវចាប់អារម្មណ៍លើអ្នកជិតខាង អ្នកក្រីក្រ ប៉ុន្តែតាំងពីថ្ងៃនេះតទៅភ្នែករបស់គាត់ចាប់ផ្ដើមបើកឡើងវិញ ដើម្បីមើលឃើញពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។

ឆ្លៀតក្នុងឱកាសនេះគង្វាលព្រះសហគមន៍រូបនេះ ក៏សំណូមពរដល់បេក្ខជន និងគ្រីស្ដបរិស័ទទាំងអស់ ដែលបានខិតខំមករៀន និងចូលរួមពិធីផ្សេងៗ នៅពេលដែលទទួលបានពិធីជ្រមុជទឹករួចហើយ សូមកុំបាត់ខ្លួន។

លោកបន្តថា ៖ «ជីវិតរបស់យើងពេលក្លាយជាគ្រីស្ដបរិស័ទហើយ ត្រូវតែធ្វើដំណើររួមជាមួយគ្នាដើរទៅមុខទៀត និងចេះសម្ដែងសេចក្ដីស្រឡាញ់ទៅអ្នកដទៃដោយចេះជួយគ្នាទៅវិញទៅមក ជួយអ្នកដទៃ ទោះបីយើងស្ថិតនៅក្នុងសភាពការណ៍ពេលនេះ យើងមិនអាចជួបជុំគ្នាបាននេះមែន ប៉ុន្តែយើងខិតខំអង្វរព្រះជាម្ចាស់សម្រាប់យើងទាំងអស់គ្នា»។

បន្ទាប់ពីធម្មទេសនារួច លោកបូជាចារ្យបានគូសសញ្ញាឈើឆ្កាងនៅលើភ្នែក ត្រចៀក បបូរមាត់ ដើមទ្រូង និងបាតដៃរបស់បេក្ខជន ដោយទូលអង្វរសូមព្រះជាម្ចាស់បើកភ្នែក បើកត្រចៀក និងចិត្តគំនិតដល់បេក្ខជនទាំងនោះ៕



# ព្រះសហគមន៍ប៊ូស្រានឹងមានព្រះវិហារថ្មី



*រូបភាពគំរូព្រះវិហារថ្មី ឈ្មោះសន្តយ៉ូហានបាទីស្ត ដែលបានធ្វើពិធីបញ្ចុះបឋមសិលារួចរាល់។ **រូបភាព៖ សហការី***

*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*

លោកអភិបាលប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាពកំពង់ចាមបានធ្វើជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលា ព្រះវិហារថ្មី ឈ្មោះសន្តយ៉ូហានបាទីស្ត ស្ថិតនៅក្នុងទឹកដីឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១ ។

លោកអភិបាលមានប្រសាសន៍នៅថ្ងៃនោះថា ព្រះយេស៊ូគ្រីស្តជាគ្រឹះយ៉ាងមាំមួនសម្រាប់ព្រះសហគមន៍របស់យើង។ ព្រះយេស៊ូជាផ្លូវ ជាជីវិត ជាពន្លឺនៃព្រះសហគមន៍របស់យើង។ ហើយបងប្អូនដែលនៅទីនេះ ជាគ្រឹះនៃព្រះសហគមន៍របស់យើងជាពិសេសនៅប៊ូស្រា។

លោកអភិបាលបានប្រោះទឹកព្រះពរលើដុំថ្មមួយដុំ ដើម្បីប្រសិទ្ធពរឲ្យក្លាយជាគ្រឹះសម្រាប់ព្រះវិហារថ្មី។ លោកអភិបាលបាន អង្វរព្រះជាម្ចាស់ សូមឲ្យគ្រីស្តបរិស័ទនៅទីនោះក្លាយជាគ្រឹះ និងមានជំនឿមាំមួន ដើម្បីធ្វើជាសាក្សីជាមួយបងប្អូនឯទៀត។

ព្រះវិហារថ្មីនេះមានទំហំ ១៦ គុណ៣៦ម៉ែត្រ ដែលមានឈ្មោះថា សន្តយ៉ូហានបាទីស្ត។ ព្រះសហគមន៍ប៊ូស្រា ជាព្រះសហគមន៍មួយរបស់បងប្អូនជនជាតិដើមភាគតិចពូនង។ បច្ចុប្បន្ននៅព្រះសហគមន៍នេះ មានគ្រីស្តបរិស័ទប្រមាណ ៣០០នាក់ ទាំងចាស់និងក្មេង។

តាមប្រសាសន៍របស់លោកបូជាចារ្យទទួលខុសត្រូវ ហ្វ្រង់ស្វ័រ អេមេល្យដាល ឲ្យដឹងថា ជារៀងរាល់ខែមានយ៉ាងហោចណាស់មួយគ្រួសារមកសុំចូលព្រះសហគមន៍នេះ ដែលធ្វើឲ្យចំនួនគ្រីស្តបរិស័ទចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

លោកបូជាចារ្យបន្ថែមថា ក្នុងឆ្នាំ២០២១នេះ ក្នុងពេលបុណ្យចម្លង នឹងមានមនុស្ស៣៧ នាក់ទទួលពិធីជ្រមុជទឹក និងមានមនុស្សចំនួន៥០នាក់ទៀតកំពុងឈ្វេងយល់អំពីជំនឿ។

លោកបន្តថា «ភាគច្រើនគេសុំចូលគ្រីស្តសាសនាដោយសារគេថា សាសនាដើមរបស់គេ ជាលុយច្រើន (ចំណាយប្រាក់ច្រើន)»។ ត្រង់ចំណុចលោកបានបញ្ជាក់ថា ធ្វើឲ្យលោកមានក្តីបារម្ភបន្តិច ប៉ុន្តែលោកនៅតែមានសង្ឃឹម ដោយសារតែព្រះវិញ្ញាណកំពុងធ្វើកិច្ចការងារនៅក្នុងចិត្តរបស់ពួកគាត់។ លោកបូជាចារ្យនិយាយថា «ត្រូវការពេលវេលា ភាពអត់ធ្មត់»។

លោកហ្វ្រង់ស្វ័រឲ្យដឹងថា ព្រះវិហារថ្មីនេះ អាចទទួលមនុស្សបានដល់៥០០នាក់ និងមានរូបរាងដូចឈើឆ្កាង។ ក្រោយចុះបឋមសិលានៅពេលនេះគឺចាប់ផ្តើមកសាងព្រះវិហារថ្មីនេះហើយ ដោយប្រើរយៈពេល១ឆ្នាំ។

ព្រះវិហារថ្មីនេះ មានឈ្មោះថា យ៉ូហានបាទីស្ត ដែលគាត់រស់នៅវាលរហោស្ថាន និងទទួលការលំបាកច្រើន «គឺប្រៀបដូចជាបងប្អូនជនជាតិព្នងនៅទីនេះ ធ្វើចម្ការរហូត ប៉ុន្តែខ្ញុំចង់បន្ថែមថា យ៉ូហានបាទីស្តគាត់រៀបចំផ្លូវថ្វាយព្រះយេស៊ូ។ ដូច្នេះ យើងនៅទីនេះ ធ្វើយ៉ាងម៉េចដើម្បីប្រកាសដំណឹងល្អ ជាពិសេសឲ្យបងប្អូនខ្មែរ»៕

# លោកអូលីវីយេ៉៖ ក្នុងពេល៤០ថ្ងៃ ត្រូវយកចិត្តទុកដាក់ថែរក្សាជំនឿ ថែរក្សាសេចក្តីសង្ឃឹម សម្តែងធម៌មេត្តាករុណា និងតមអាហារ





*អត្ថបទ៖ ដាលីស*

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ប្រារព្ធពិធីបុណ្យរោយផេះ ដែលជាប្រពៃណីព្រះសហគមន៍នាថ្ងៃដំបូងចូលក្នុងរដូវអប់រំពិសេស (រដូវ៤០ថ្ងៃ ឬ រដូវត្រណម) ។ ព្រះសហគមន៍ ប្រារព្ធបុណ្យរោយផេះដើម្បីរំឭកដល់គ្រីស្តបរិស័ទទាំងអស់ឱ្យរស់នៅដោយកែប្រែចិត្តគំនិត ជាពិសេសរំឭកអំពីកំណើតរបស់មនុស្សយើងដែលកើតមកពីធូលីដី និងស្លាប់ទៅវិញក៏ក្លាយទៅជាធូលីដីវិញ។

ពិធីបុណ្យនេះប្រារព្ធ នៅព្រះវិហារព្រះមាតានៃសន្តិភាព (អរិយក្សត្រ) ក្រោមអធិបតីភាពលោកអូលីវីយេ៉ ជ្មិតហាស្លេរ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ និងមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ នាល្ងាចថ្ងៃទី ១៧ កុម្ភៈ ២០២១ ។

តាមប្រសាសន៍ណែនាំរបស់លោកអភិបាលអូលីវីយេ៉ នៅក្នុងធម្មទេសនា លោកថា រដូវ៤០ថ្ងៃដែលព្រះសគមន៍អញ្ជើញយើងឱ្យធ្វើដំណើររួមជាមួយព្រះយេស៊ូ ដើម្បីទទួលមរណភាពនៅក្រុងយេរូសាឡឹម ក៏ប៉ុន្តែមរណៈភាពមិនបានបញ្ឈប់ដំណើររបស់យើងទេ ព្រោះបីថ្ងៃក្រោយមកព្រះយេស៊ូនឹងមានព្រះជន្មរស់ឡើងវិញ។ លោកថា ដូច្នេះយើងធ្វើដំណើររួមជាមួយព្រះយេស៊ូដែលរងទុក្ខលំបាក សោយព្រះទិវង្គត រហូតដល់ព្រះអង្គមានព្រះជន្មរស់ឡើងវិញដោយរុងរឿងទៅគង់ខាងស្តាំព្រះបិតា។

ជាមួយគ្នានេះដែរ លោកអូលីវីយេ៉ ក៏បានពញ្ញាក់ស្មារតីគ្រីស្តបរិស័ទភូមិភាគភ្នំពេញទាំងអស់នៅក្នុងឆ្នាំ២០២១នេះឱ្យរិះគិតឡើងវិញនូវបញ្ហាដែលយើងបានជួបកាលពីឆ្នាំ២០២០កន្លងទៅ ជាពិសេសកូវីដ១៩នេះ តើយើងមានចំណុចខ្សោយ និងចំណុចខ្លាំងអ្វីខ្លះនៅក្នុងគ្រួសារ សង្គម និងព្រះសហគមន៍? តើ៤០ថ្ងៃខាងមុខនេះយើងនឹងធ្វើដូចម្តេចដើម្បីធ្វើជាមនុស្សថ្មី?

លោកអភិបាលភូមិភាគភ្នំពេញអូលីវីយេ៉ ក៏បានផ្តល់នូវអនុសាសន៍ចំនួន៤ចំណុចសម្រាប់ជួយដល់គ្រីស្តបរិស័ទដើម្បីដំណើររួមជាមួយព្រះយេស៊ូក្នុង៤០ថ្ងៃខាងមុខនេះគឺ៖ « ១) សូមឱ្យយើងការពារថែរក្សាជំនឿរបស់យើងដោយផ្តល់សាក្ខីភាពពិតប្រាកដ។ យកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលនិងអធិដ្ឋានថែមទៀត។ ២) ថែរក្សាសេចក្តីសង្ឃឹមរបស់យើងដែលជាសញ្ញាសម្គាល់អំពីគ្រីស្តបរិស័ទ ទោះបីជាយើងមានទុក្ខលំបាកយ៉ាងណាក៏ដោយព្រោះយើងមានព្រះគ្រីស្តមានព្រះបន្ទូល និងព្រះសហគមន៍ជាទីពឹងនៅក្នុងជីវិត។ ៣) សូមធ្វើជាគ្រីស្តបរិស័ទមួយរូបដែលបង្ហាញពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ហើយនេះជាពេលវេលាដើម្បីជួយដល់អ្នកខ្វះខាត និងខ្វះសេចក្តីសង្ឃឹម។ ៤) នៅក្នុងរដូវ៤០ថ្ងៃនេះ ព្រះសហគមន៍អញ្ជើញយើងឱ្យតមអាហារ ដោយពិចារណា យកចិត្តទុកដាក់ចំពោះកម្លាំងកាយ និងកម្លាំងចិត្តរបស់យើងផ្ទាល់ខ្លួន និងយកចិត្តទុកដាក់ចំពោះបងប្អូនឯទៀតៗផងដែរ។ លោកបន្ថែមថា អត្ថន័យនៃការតមអាហារមិនមែនឱ្យយើងឈប់ញ៉ាំទេ ប៉ុន្តែជារបៀបនៃការរស់នៅ និងទំនាក់ទំនងរបស់យើងនៅក្នុងជីវិតពិតប្រាកដ»

ក្រោយបញ្ចប់ធម្មទេសនា លោកអភិបាលអូលីវីយេ និងលោកបូជាចារ្យ បានអធិដ្ឋាន និងប្រទានពរលើផេះដែលបានមកពីការដុះស្លឹកកាលពីបុណ្យហែស្លឹកឆ្នាំមុន។ បន្ទាប់មកលោកក៏បានយកផេះទាំងនេះ មកគូសជាសញ្ញាឈើឆ្កាងលើគ្រីស្តបរិស័ទទាំងអស់ ដោយមានប្រសាសន៍៖ «សូមកែប្រែចិត្តគំនិត និងជឿលើដំណឹងល្អ»

យុវជន ថៃ ប្រុសពៅ ជាគ្រីស្តបរិស័ទនៅព្រះសហគមន៍អរិយក្សត្រនេះ បានឱ្យដឹងថា «ក្នុងរយៈពេល៤០ថ្ងៃនេះ ពួកខ្ញុំជាគ្រីស្តបរិស័ទនឹងរៀបចំចិត្តគំនិត និងមានអំណរសប្បាយដោយរួមជាមួយព្រះយេស៊ូ និងទទួលទុក្ខលំបាកដូចជាព្រះអម្ចាស់ដែរ» ប្រុសពៅ បន្ថែមថា រូបគេនឹងរៀបចំចិត្តគំនិតដើម្បីជួយអ្នកអត់ឃ្លាន និងអ្នកខ្វះខាតដែលនៅជុំវិញខ្លួន ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូគ្រីស្ត៕

# សន្តយ៉ូសែបជាគំរូនៃមេគ្រួសារដើម្បីថែរក្សាគ្រួសារនិងសង្គមជាតិ

*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*

ក្នុងពិធីថ្វាយអភិបូជាអបអរសាទរចូលឆ្នាំថ្មីប្រពៃណីចិន-វៀតណាម លោកអភិបាលអូលីវីយេ ឆ្មឹតហាស្លេរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ថា ការយកចិត្តទុកដាក់លើកិច្ចការប្រចាំថ្ងៃ អំពីតួនាទីរបស់ខ្លួនម្នាក់ៗគឺសំខាន់។

លោកមានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទនៅព្រះសហគមន៍ចំប៉ា កាលពីថ្ងៃទី១២ កុម្ភៈ ទៀតថា ក្នុងថ្ងៃនេះ យើងជួបជុំគ្នា ដើម្បីអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះជាម្ចាស់ប្រទានពរឲ្យយើង ឲ្យឆ្នាំថ្មីនេះប្រកបដោយសេក្តីសុខ សេចក្តីស្រឡាញ់ និងប្រកបដោយព្រះពរដ៏ពិតប្រាកដដែលមកពីព្រះជាម្ចាស់។

លោកអភិបាលបានលើកឡើងអំពីសាររបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូក្នុងឆ្នាំនេះថា ជាឆ្នាំនៃការយកចិត្តទុកដាក់។ លោកអភិបាលបានលើកនូវចំនុចសំខាន់ៗ ដោយផ្តោតលើការយកចិត្តទុកដាក់របស់សន្តយ៉ូសែប និងការយកចិត្តទុកដាក់ថែរក្សាពិភពលោក។

«យកចិត្តទុកដាក់យកគំរូតាមសន្តយ៉ូសែប។ សន្តយ៉ូសែបបានយកចិត្តទុកដាក់ ជាមួយព្រះជាម្ចាស់។ ដូច្នេះ សម្រាប់ឆ្នាំនេះឲ្យយើងយកចិត្តទុកដាក់អធិដ្ឋាន យកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ យកចិត្តទុកដាក់តស៊ូនៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់»។ នេះជាសម្តីរបស់លោកអភិបាលដែលបានក្រើនរំលឹកដល់គ្រីស្តបរិស័ទ។

ជាមួយគ្នានេះដែរ លោកអភិបាលបានកោតសរសើរចំពោះគ្រីស្តបរិស័ទ ក្នុងអំឡុងពេលកូវីដ-១៩ ដែលមិនអាចធ្វើពិធីជួបជុំក្នុងព្រះវិហារបាន តែបានយកចិត្តទុកដាក់អធិដ្ឋានតាមផ្ទះ។ លោកអភិបាល «តាមផ្ទះយើងបានទទួលព្រះពរពីព្រះកាយ តាមផ្ទះយើងបានយកចិត្តទុកដាក់ដោយដឹងថា ព្រះជាម្ចាស់គង់នៅជាមួយយើងជានិច្ច»។

លោកក៏បានលើកទឹកចិត្តដល់គ្រីស្តបរិស័ទ យកចិត្តទុកដាក់នឹងគ្រួសាររបស់ខ្លួនបន្ថែមទៀត ឲ្យដូចគំរូរបស់សន្តយ៉ូសែប។ លោកមានប្រសាសន៍ថា សន្តយ៉ូសែបបានយកចិត្តទុកដាក់ ថែរក្សា ការពារ និងនៅជាមួយព្រះនាងម៉ារី និងព្រះយេស៊ូដោយសេចក្តីស្រឡាញ់ និងធ្វើយ៉ាងណាដើម្បីឲ្យគ្រួសារមានសុភមង្គល។ លោកអភិបាលអូលីវីយេ បន្ថែមថា «ឲ្យឪពុកម្តាយចេះជួយគ្នាទៅវិញទៅមកនៅក្នុងសេចក្តីស្រឡាញ់ ឲ្យកូនៗយកចិត្តទុកដាក់ស្រឡាញ់ឪពុកម្តាយនិងលោកតាលោកយាយ ឲ្យលោកតាលោកយាយយកចិត្តទុកដាក់ជាមួយកូនចៅ ដើម្បីឲ្យគ្រួសារនីមួយៗ ពោរពេញដោយសេចក្តីសុខតាមរបៀបរបស់សន្តយ៉ូសែប ជាមួយព្រះនាងម៉ារី និងព្រះយេស៊ូ»។



> នៅពេលដែលយើងចេះថែរក្សាទាំងសុខភាពផ្លូវកាយផ្លូវចិត្ត និងផ្លូវវិញ្ញាណខ្លួនផ្ទាល់ អាចថែរក្សាគ្រួសារ ព្រះសហគមន៍ និងសង្គមបរិស្ថានបាន ណែនាំឲ្យបញ្ហាក្នុងឆ្នាំ២០២១នេះ នឹងអាចដោះស្រាយបាន

ម្យ៉ាងវិញទៀត ការទទួលខុសត្រូវតាមតួនាទីរៀងៗខ្លួនក៏មានសារៈសំខាន់ខ្លាំងដែរ «គឺឲ្យក្មេងយកចិត្តទុកដាក់នូវកិច្ចការងាររបស់ខ្លួន គឺការសិក្សានៅសាលារៀន ហើយចំពោះលោកតាលោកយាយនិងពូមីង ត្រូវយកចិត្តទុកដាក់នឹងការងារផ្ទាល់ដូចសន្តយ៉ូសែបដែរ ដោយមិនគិតពីការនឿយហត់ ការពិបាក ដើម្បីចិញ្ចឹមគ្រួសារ ដើម្បីឲ្យមានសេចក្តីសុខ» លោកអភិបាលបញ្ជាក់។

ចុងបញ្ចប់នៃធម្មទេសនា លោកអភិបាលបានរំលឹកដល់គ្រីស្តបរិស័ទដើម្បីយកចិត្តទុកដាក់បន្ថែមទៀតលើស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលបានបង្កើតឡើងជាពិសេសគឺបរិស្ថាននៅជុំវិញ ដើម្បីរកឃើញសេចក្តីសុខនៅក្នុងគ្រួសារនីមួយ។ លោកបន្តថា នៅពេលដែលយើងចេះថែរក្សា ទាំងសុខភាពផ្លូវកាយផ្លូវចិត្តនិងផ្លូវវិញ្ញាណខ្លួនផ្ទាល់ អាចថែរក្សាគ្រួសារ ព្រះសហគមន៍ និងសង្គមបរិស្ថានបាន ណែនាំឲ្យបញ្ហាក្នុងឆ្នាំ២០២១នេះ នឹងអាចដោះស្រាយបាន៕

# អភិបាលភូមិភាគភ្នំពេញណែនាំគ្រីស្តបរិស័ទឱ្យយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលព្រះជាម្ចាស់

*អត្ថបទ៖ ព្រះសហគមន៍កាតូលិកភ្នំពេញ*

នាថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅព្រះវិហារសន្តយ៉ូសែបផ្សារតូចនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រារព្ធកម្មវិធី «អធិដ្ឋានសម្រាប់ការត្រាស់ហៅពេញមួយយប់លើកទី៥៨» ក្រោមការដឹកនាំពីលោកអីលីវីយ៉េ ឆ្មឹតអឺស្លែរ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងមានការចូលរួមពីគ្រីស្តបរិស័ទផងដែរ។

លោកអភិបាល អូលីវីយ៉េ បានថ្លែងក្នុងឱកាសនោះថា នេះជាវេលាមួយដ៏ល្អដើម្បីសូមព្រះជាម្ចាស់បើកចិត្តគំនិតយុវជនយុវនារីឱ្យដើរតាមព្រះជាម្ចាស់និងឱ្យមើលឃើញពីការត្រាស់ហៅរបស់ព្រះអង្គ។

នៅក្នុងពិធីបុណ្យអភិបូជាបើកកម្មវិធីអធិដ្ឋាននេះ លោកអភិបាលបានណែនាំគ្រីស្តបរិស័ទទាំងអស់នៅក្នុងធម្មទេសនាឱ្យយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកបានមានប្រសាសន៍ថា៖ «ប្រសិនបើយើងផ្ទាល់ខ្លួនមិនស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើធ្វើដូចម្តេចនឹងអាចឆ្លើយតបបាន?»

លោកអភិបាលរូបនេះបានផ្តល់នូវអនុសាសន៍សំខាន់ចំនួន៤ដើម្បីដើរតាមព្រះជាម្ចាស់ គឺទី១ គ្រប់គ្នានៅជិតព្រះជាម្ចាស់ដែលមានឫទ្ធានុភាពសព្វប្រការ មិនវិនិច្ឆ័យធ្វើឱ្យធ្លាក់ទឹកចិត្ត និងអស់សង្ឃឹម។ តែផ្ទុយមកវិញ ដើម្បីណែនាំឱ្យចូលទៅក្នុងព្រះពន្លឺរបស់ព្រះអង្គ ដោយស្គាល់អ្វីល្អអ្វីអាក្រក់ និងប្រកាសដំណឹងល្អឱ្យគេកែប្រែចិត្តគំនិត។

លោកបន្តទៀតថា ចំណុចទី២គឺ វិញ្ញាណក្ខន្ធរបស់សន្តសន្តីដែលដើរតាមព្រះជាម្ចាស់ គឺជាគំរូពិសេសនៅក្នុងការយកចិត្តទុកដាក់ស្រឡាញ់ព្រះជាម្ចាស់ និងជាវិញ្ញាណក្ខន្ធអ្នកសុចរិត។ លោកអភិបាល អូលីវីយ៉េ លើកឡើងថា ៖ «ទី៣ នៅពេលយើងដើររកព្រះជាម្ចាស់ គឺយើងចូលមកស្ថាននៃសម្ព័ន្ធមេត្រីថ្មី ដោយមិននៅម្នាក់ឯង តែព្រះជាម្ចាស់បានចាប់កំណើតជាមនុស្ស ដើម្បីធ្វើដំណើរជាមួយយើងឆ្ពោះទៅរកព្រះបិតា»។ ឯអនុសាសន៍ទី៤គឺ ការយល់ពីរបៀបថ្មី ដោយចូលទៅក្នុងវប្បធម៌នៃការយកចិត្តទុដាក់ បង្កើតសមត្ថភាពនៅក្នុងភាតរភាពមានការសប្បាយ និងកសាងចិត្តគំនិតដើម្បីឱ្យមនុស្សយល់ថា [យើង]ជាមនុស្សពេញលក្ខណៈ។

លោកប្រាក់ ប៊ុនហុង បានឱ្យដឹងថា ការអធិដ្ឋានពេញមួយយប់ពិតជាជួយច្រើនសម្រាប់ជីវិតនៃការត្រាស់ហៅ។

លោកបានប្រាប់ថា៖ «ការអធិដ្ឋានបានជួយឱ្យយើងរិះគិតអំពីអ្វីដែលព្រះជាម្ចាស់ត្រាស់ហៅយើង។ ជាពេលវេលាដែលយើងអធិដ្ឋានសម្រាប់ព្រះសហគមន៍របស់យើងដែរ ដោយសារភាគច្រើនព្រះសហគមន៍របស់យើងមានបញ្ហាផ្សេងៗយើងមិនដឹង ប៉ុន្តែយើងនឹកគិតដល់ព្រះសហគមន៍ នឹកគិតដល់គ្រីស្តបរិស័ទរបស់យើងឱ្យពួកគេខិតខំតស៊ូក្នុងជីវិតទាំងក្នុងគ្រួសារ និងឧបសគ្គផ្សេងៗដែលគាត់ជួប»។

លោកប្រាក់ ប៊ុនហុង បន្ថែមថា លោកក៏អធិដ្ឋានសម្រាប់យុវជន-យុវនារី ដែលកំពុងតែរិះគិត និងជួនកាលពួកគេមិនទាន់រកផ្លូវច្បាស់លាស់នៅក្នុងជីវិត ដូចជាជាគូស្រករ ឬជាបុព្វជិតបុព្វជីតាជាដើម ដើម្បីសូមព្រះវិញ្ញាណបំភ្លឺពួកគេឱ្យមានសេចក្តីក្លាហានក្នុងការរិះគិត។

លោកបានបញ្ជាក់ថា ៖ «ខ្ញុំក៏រិះគិតអំពីខ្លួនឯងចំពោះការឆ្លើយតបទៅព្រះជាម្ចាស់ក្នុងជីវិតនៃការត្រាស់ហៅឱ្យបានសមរម្យ ដើម្បីបំពេញកិច្ចការរបស់ព្រះអង្គ»។

ជារៀងរាល់ថ្ងៃព្រហស្បតិ៍នៃដើមខែនីមួយៗ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ តែងតែប្រារព្ធកម្មវិធីអធិដ្ឋានសម្រាប់ការត្រាស់ហៅនេះ ដោយផ្លាស់ប្តូរទីតាំងវិលជុំទៅតាមមណ្ឌលសកម្មភាពទាំង៥របស់ព្រះសហគមន៍ភូមិភាគភ្នំពេញ៕

# បេក្ខជនបេក្ខនារីចំនួន៧៧នាក់ត្រូវបានស្វាគមន៍ចូលក្នុងព្រះសហគមន៍ក្នុងជំហានទី១

*អត្ថបទ៖ ដាលីស*

បេក្ខជនបេក្ខនារីចំនួន៧៧នាក់មកពីព្រះសហគមន៍កាតូលិកនានា នៃមណ្ឌលសកម្មភាពតាកែវ ត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្ដៅចូលក្នុងព្រះសហគមន៍កាតូលិកក្នុងជំហានទី១ ដើម្បីបន្តដំណើរឈ្វេងយល់អំពីព្រះបន្ទូល រហូតទទទួលអគ្គសញ្ញាជ្រមុជទឹក។

ពិធីទទួលប្រព្រឹត្តឡើងកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅព្រះវិហារសន្តី ម៉ារីញញឹម ភូមិចំការទៀង ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីអភិបាលភូមិភាគភ្នំពេញ លោកអូលីវីយេ ជ្មីតហាស្លេរ។



ក្នុងពិធីនេះ លោកអូលីវីយេ រួមជាបងប្អូនគ្រីស្តបរិស័ទ បានទទួលស្វាគមន៍បងប្អូនទាំង៧៧រូបនេះយ៉ាងកក់ក្ដៅ និងឱឡារិកបំផុត ក្រោយពេលបានដឹងអំពីគោលបំណងយ៉ាងច្បាស់លាស់របស់បងប្អូនដែលបានសុំចូលព្រះសហគមន៍។

មានប្រសាសន៍ទៅកាន់បងប្អូនជំហានទី១ទាំងនេះ លោកអភិបាលអូលីវីយេ បានថ្លែងថា៖ «ខ្ញុំរំភើបណាស់ដែលមានបងប្អូនច្រើនដូចនេះសុំចូលក្នុងព្រះសហគមន៍។ ខ្ញុំរំភើប ដែលចម្លើយរបស់បងប្អូនសុំចូលព្រះសហគមន៍គឺ ខ្ញុំសុំជំនឿ និងជំនឿនេះណែនាំឲ្យខ្ញុំទទួលជីវិតអស់កល្បជានិច្ច»។

លោកអភិបាលភូមិភ្នំពេញរូបនេះបានបន្តទៀតថា គ្រប់គ្នាមានគោលដៅជីវិត ដែលគោលដៅនៃជីវិតនេះមិនមែននៅលើផែនដីនេះទេ ប៉ុន្តែសម្រាប់ត្រៀមខ្លួនឲ្យបានទៅដល់ស្ថានបរមសុខ។

លោកបានបញ្ជាក់ថា៖ «នៅក្នុងព្រះយេស៊ូ យើងអាចរកឃើញផ្លូវនៃជីវិតអស់កល្បជានិច្ច។ ផ្លូវនេះចាប់ផ្ដើមពេលនេះ យើងសុខចិត្តដើរតាមព្រះយេស៊ូ»។

ដំណើរនេះនាំឲ្យមានការកែប្រែចិត្តគំនិត បន្តិចម្ដងៗដើម្បីចូលក្នុងជីវិតរបស់ព្រះយេស៊ូ ដើម្បីចូលក្នុងជីវិតព្រះសហគមន៍ ដើម្បីឲ្យព្រះបន្ទូលចូលក្នុងដួងចិត្តរបស់យើង ណែនាំឲ្យយើងរស់នៅតាមព្រះបន្ទូលដែលយើងបានស្ដាប់ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីទទួលអំណរសប្បាយ និងជីវិតថ្មី។ នេះបើតាមការលើកឡើងរបស់លោកអភិបាលអូលីវីយេ។

លោកក៏បានរំឭកឲ្យបងប្អូន ចេះចែករំលែកអំណរសប្បាយនិងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀត។ ជាពិសេសសូមឲ្យបេក្ខជនបេក្ខនារីចេះអធិដ្ឋាន ទូលអង្វរព្រះជាម្ចាស់ ដោយពោលពាក្យថា «ឱព្រះអម្ចាស់អើយ! សូមអាណិតអាសូរមកដល់ទូលបង្គំផង» ព្រះជាម្ចាស់ជាសេចក្ដីស្រលាញ់ព្រះអង្គស្ដាប់ពាក្យអង្វររបស់យើង។

លោកអូលីវីយេ ក៏បានរំឭកបងប្អូនត្រូវទទួលស្គាល់ភាពទន់ខ្សោយរបស់ខ្លួន ដោយសារព្រះជាម្ចាស់មានព្រះហឫទ័យអាណិតអាសូរ ព្រះអង្គនឹងណែនាំឲ្យបងប្អូនធ្វើដំណើរបន្តិចម្ដងៗក្នុងជីវិតថ្មីនៃធម៌របស់ព្រះជាម្ចាស់ លើទឹកដីកម្ពុជា។

បេក្ខជនបេក្ខនារីទាំង៧៧រូបនេះ ជាមនុស្សពេញវ័យមកពីព្រះសហគមន៍កាតូលិក ព្រះវិហារគ្រួសារដ៏វិសុទ្ធ ក្រុងដូនកែវ ព្រះវិហារសន្តប៉ូល អង្គគីរ ព្រះវិហារសន្តយ៉ូសែប ត្រពាំងក្រញ៉ូង ព្រះវិហារសន្តីម៉ារីកំពង់អំពិល និង ព្រះវិហារសន្តីម៉ារីញញឹមចំការទៀង។

បន្ទាប់ពីធម្មទេសនា បេក្ខជនបេក្ខនារីទាំងនេះបានប្រកាសនៅមុខឈើឆ្កាងថា៖ « ខ្ញុំសូមយកព្រះយេស៊ូជាទីពឹង ខ្ញុំសូមយកព្រះបន្ទូលជាទីពឹង ខ្ញុំសូមយកព្រះសហគមន៍ជាទីពឹង»។

យុវជន រ៉ុ ឧត្តម បេក្ខជនដែលបានទទួលជំហានទី១ បាននិយាយថា លោកបានសម្រេចចិត្តដើរតាមព្រះយេស៊ូដោយទទួលអប់ជំនឿ ហើយលោកក៏ចង់ស្គាល់ច្បាស់ពីដំណើរជីវិតរបស់ព្រះជាម្ចាស់ ព្រះសហគមន៍ និងចូលបម្រើព្រះសហគមន៍ដូចបងប្អូនគ្រីស្តបរិស័ទផ្សេងទៀត។

យុវជនរូបនេះបានរំឭកឱ្យដឹងថា ដំបូងឡើយលោកគ្មានការចាប់អារម្មណ៍អ្វី ដោយលោកគ្រាន់តែចូលរួមច្រៀងចម្រៀងក្នុងព្រះវិហារ ស្ដាប់ព្រះបន្ទូល និងស្ដាប់ការពន្យល់ច្រើនរបស់លោកអភិបាល ដែលធ្វើឱ្យយុវជនរូបនេះជឿនិងចង់ក្លាយជាគ្រីស្តបរិស័ទ។ បើទោះបីជាលោកឧត្តមទទួលរងនូវការរិះគន់ពីអ្នកជិតខាងក្នុងភូមិររបស់លោក ថា «ចូលសាសនាដទៃ មិនល្អទេ» ប៉ុន្តែបែរជាគ្រួសាររបស់លោកមិនបានហាមគាត់ឬរិះគន់ទៅលើការចូលខ្លួនបំរើព្រះជាម្ចាស់ឡើយ ដោយឪពុកម្ដាយរបស់លោកបាននិយាយថា៖ «ឲ្យតែកូនសប្បាយចិត្ត សូមធ្វើចុះ»៕

# លោកអភិបាលអូលីវីយេ៖ «សូមយកព្រះយេស៊ូជាគំរូ សម្រាប់ជីវិតរបស់យើង»

*អត្ថបទ៖ ដាលីស*

«សូមយកព្រះយេស៊ូជាគំរូសម្រាប់ជីវិតរបស់យើង ព្រះយេស៊ូធ្វើយ៉ាងណា សូមធ្វើយ៉ាងហ្នឹងដែរ។ ព្រះយេស៊ូស្រលាញ់ សូមឲ្យយើងចេះស្រលាញ់ដែរ។ ព្រះយេស៊ូលើកលែងទោស សូមឲ្យយើងចេះលើកលែងទោសដែរ។ ព្រះយេស៊ូព្យាបាល សូមឲ្យយើងចេះយកចិត្តទុកដាក់..»។

នេះជាការថ្លែងឡើងរបស់អភិបាលភូមិភាគភ្នំពេញ លោកអភិបាលីវីយេ ជ្មីតអឺស្លែរ ទៅកាន់បេក្ខជនបេក្ខនារីចំនួន៤០នាក់ក្នុងពិធីទទួលអគ្គសញ្ញាលាបថ្ងាស នៅព្រះសហគមន៍ព្រះវិហារសន្តយ៉ូសែប ស្អាង ខេត្តកណ្ដាល នាព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១កន្លងមកនេះ។

លោកអភិបាលបានបន្តដោយសុំឲ្យគ្រីស្តបរិស័ទចេះទូលអង្វរព្រះជាម្ចាស់ដូចក្នុងគម្ពីរមនុស្សឃ្លង់ទូលអង្វរព្រះយេស៊ូសុំព្យាបាលគាត់ឲ្យជា។ ហេតុនេះ ត្រូវទូលអង្វព្រះជាម្ចាស់ សូមព្រះអង្គប្រទានជីវិតថ្មី ព្រះវិញ្ញាណថ្មី ខ្យល់ដង្ហើមថ្មី ដែលណែនាំឲ្យធ្វើជាមនុស្សថ្មីដែរ។

លោកលើកឡើងថា «សូមឲ្យយើងមានចិត្តស្មោះចំពោះព្រះអង្គ ចំពោះឪពុកម្ដាយ យកចិត្តទុកដាក់ក្នុងការងារ រួមទាំងការងារព្រះសហគមន៍។ សូមយើងទូលអង្វររាល់ថ្ងៃ អធិដ្ឋានរាល់ថ្ងៃ សូមព្រះអង្គអាណិតអាសូរដល់យើង។ យើងជាមនុស្សដែលពោរពេញដោយអំពើបាប យើងចង់មានជីវិតថ្មី»។



លោកអភិបាលរូបនេះក៏បានដាស់តឿនដល់បេក្ខជនបេក្ខនារីចំនួន៤០នាក់ ពេលទទួលជីវិតថ្មីត្រូវចេញទៅប្រកាសនិងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ជាពិសេសបេក្ខជនបេក្ខនារីទាំងនេះទទួលអគ្គសញ្ញាលាបថ្ងាស សូមឲ្យទទួលពន្លឺរបស់ព្រះជាម្ចាស់បំភ្លឺជីវិតជារៀងរហូតពេញមួយជីវិត។

បេក្ខជនបេក្ខនារីទាំង៤០នាក់នេះ ភាគច្រើនជាកូនចៅគ្រីស្តបរិស័ទដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកតាំងពីកុមារ។

បន្ទាប់ពីប្រារព្ធពិធីអគ្គសញ្ញាលាបថ្ងាសនិងពិធីអរព្រះគុណព្រះជាម្ចាស់រួច ដោយសារឆ្នាំនេះព្រះសហគមន៍កំណត់ជាឆ្នាំសន្តយ៉ូសែប លោកអភិបាលអូលីវីយេ បានប្រគល់រូបសំណាកសន្តយ៉ូសែប ដល់ព្រះសហគមន៍ ដើម្បីតម្កល់ទុកក្នុងព្រះសហគមន៍ស្អាងនេះសម្រាប់អធិដ្ឋាន។ ក្នុងនោះក៏មានពិធីជូនពរឆ្នាំថ្មី និងអបអរសាទរខួប ១២ឆ្នាំ ក្នុងមុខងារជាអភិបាលភូមិភាគភ្នំពេញរបស់លោកអភិបាលអូលីវីយេផងដែរ៕

# លោកអភិបាល អូលីវីយ៉េ៖ «កូវីដ១៩ ណែនាំឱ្យយើងចេះយកចិត្តទុកដាក់»

*អត្ថបទ៖ ព្រះសហគមន៍កាតូលិកភ្នំពេញ*

នៅក្នុងដំណើរទស្សនៈកិច្ចនិងសួរសុខទុក្ខបុគ្គលិកនិងសិស្សានុសិស្សនៃសាលាឡាវ៉ាឡា កាលពីព្រឹកថ្ងៃចន្ទ ទី២២ ខែកុម្ភៈ ឆ្នាំ២០២១ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកអភិបាល អូលីវីយ៉េ បានលើកឡើងថា ជំងឺកូវីដ-១៩ ជួយណែនាំឱ្យគ្រប់គ្នាចេះយកចិត្តទុកដាក់។

លោកបានបន្តថា លោកព្រួយបារម្ភខ្លាចមិនបានមកទីនេះដោយសារជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាតក្នុងសហគមន៍សារជាថ្មី ប៉ុន្តែដោយសារកូវីដ-១៩ បានបង្រៀនមនុស្សឱ្យចេះយកចិត្តទុកដាក់លើវិធានអនាម័យ ការសិក្សា ការធ្វើទំនាក់ទំនង ការយកចិត្តទុកដាក់លើជីវិតខាងផ្លូវវិញ្ញាណ និងចំណុចជាច្រើនទៀត។

លោកអភិបាល អូលីវីយ៉េបានបញ្ជាក់បន្ថែមថា៖ «កូវីដ-១៩បានបង្រៀនឱ្យយើងចេះយកចិត្តទុកដាក់លើអនាម័យ ដែលពីមុនយើងមិនសូវរវីរវល់លាងដៃ ពាក់ម៉ាស់ឡើយ ប៉ុន្តសព្វថ្ងៃមិនថានៅកន្លែងណាយើងមានទម្លាប់លាងដៃនិងពាក់ម៉ាស់ ដែលណែនាំឱ្យយើងកែប្រែរបៀបនៃការរស់នៅរបស់យើង»។

លោកបន្តថា ការយកចិត្តទុកដាក់លើការសិក្សាពេលគ្រប់គ្នាសម្រាកនៅផ្ទះមួយរយៈដោយសារជំងឺកូវីដ-១៩ បានណែនាំឱ្យ [យើង] យល់ថាការសិក្សាសំខាន់ណាស់ [យើង] បានយល់អំពីតម្លៃការសិក្សាពេលមិនមានសាលា។

លោកអភិបាលដដែលរូបនេះបានមានប្រសាសន៍ថា៖ «យើងបានយកចិត្តទុកដាក់លើមិត្តសម្លាញ់របស់យើង យកចិត្តទុកដាក់លើទំនាក់ទំនង យើងបានមករៀននៅទីនេះណែនាំឲ្យយើងមានមិត្តភ័ក្តិច្រើន បង្កើតទំនាក់ទំនង-មិត្តភាព។ ការយកចិត្តទុកដាក់លើបរិស្ថានធម្មជាតិ សាលារបស់យើងមានសួនច្បារស្អាតណាស់ មានផ្កា មានស្មៅ មានដើមឈើមានសត្វ... ពេលយើងយកចិត្តទុកដាក់លើធម្មជាតិធ្វើឱ្យយើងមានសេចក្តីសុខនិងសុខដុមរមនា»។

ចំណុចសំខាន់មួយទៀតដែលលោកអភិបាល អូលីវីយ៉េ បានលើកឡើងក្នុងឱកាសនោះដែរ គឺការយកចិត្តទុកដាក់គោរពចាស់ទុំ។ ការគោរពលោកគ្រូអ្នកគ្រូ បងប្រុស ពូ មីង និងមនុស្សចាស់ទុំផ្សេងៗទៀត ធ្វើឱ្យការសិក្សារបស់ពួកគេទៅមុខរហូតទទួលបានជោគជ័យនៅក្នុងជីវិត។

អភិបាល អូលីវីយ៉េ បានមានប្រសាសន៍ថា៖ «ការយកចិត្តទុកដាក់លើជីវិតខាងផ្លូវវិញ្ញាណ ទោះបីយើងកាន់សាសនាអ្វីក៏ដោយ យើងមានផ្លូវវិញ្ញាណដែរ។ ផ្លូវវិញ្ញាណសំខាន់ណាស់ដែលណែនាំឱ្យយើងនឹកឃើញថា យើងជាមនុស្សដែលកើតពីព្រះជាម្ចាស់ ណែនាំឲ្យយើងទាំងអស់គ្នាស្រលាញ់គ្នាដូចជាបងប្អូន»។

នាពេលនោះផងដែរ លោកអភិបាលក៏បានរំលឹកដល់បងប្រុស ធៀរី ដែលជាស្ថាបនិកសាលាឡាវ៉ាឡានេះថា បងប្រុសជាមនុស្សម្នាក់ដែលស្រឡាញ់ធម្មជាតិ គាត់ចង់ឱ្យកន្លែងនេះទៅជា



កន្លែងកក់ក្តៅសម្រាប់មនុស្សទាំងអស់ ជាពិសេសសម្រាប់កុមារមានពិការភាព។ លោកថា ប្រហែលពេលនេះបងប្រុស ធៀរី នៅឋានលើដើម្បីជួយមើលនិងតាមថែរក្សាទាំងអស់គ្នា។

កុមារី នី ចន្ថា ជាតំណាងសិស្សសាលាឡាវ៉ាឡា បានថ្លែងពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនថា នៅក្នុងភូមិមិនសូវមិនគេរាប់រកគាត់ទេ ដោយសារតែពិការភាពរបស់គាត់ ហើយពេលដែលកុមារីរូបនេះមករៀននៅទីនេះដំបូង គាត់មានអារម្មណ៍ថាភ័យខ្លាច។

កុមារីចន្ថាបានប្រាប់ថា៖ «ដំបូងភ័យខ្លាច ប៉ុន្តែនៅមិនបានយូរប៉ុន្មានផងធ្វើឲ្យខ្ញុំមានអារម្មណ៍សប្បាយចិត្ត ដោយសារមានមិត្តភ័ក្តច្រើន មានលោកគ្រូអ្នកគ្រូដ៏សែនល្អ»។

កុមារីដដែលរូបនេះបានបន្តថា គាត់ចង់រៀនឱ្យបានខ្ពស់ជាពិសេសលើមុខវិជ្ជាគណិតវិទ្យា និងភាសាអង់គ្លេស ដើម្បីបំពេញបំណងធ្វើការងារជាគណនី។

គួរបញ្ជាក់ផងដែរថា សាលាឡាវ៉ាឡា បង្កើតឡើងដោយក្រុមគ្រួសារបងប្រុសម៉ារីស្សនៅឆ្នាំ ១៩៩៨ ដើម្បីផ្តត់ផ្គង់ដល់កុមារនិងយុវជនដែលមានពិការភាពរាងកាយ។ សាលានេះមានទីតាំងស្ថិតនៅភូមិព្រែករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល៕

# កិច្ចប្រជុំសហសម្ពន្ធគ្រូមត្តេយ្យភូមិភាគកំពង់ចាម

*អត្ថបទ៖ ឆាក លាំង*

អ្នកគ្រូមត្តេយ្យសាលាបង្គោលទាំង៣នាក់ ដែលបម្រើការងារនៅព្រះសហគមន៍កាតូលិកកំពង់ចាមទាំងមូល បានចូលរួមប្រជុំដើម្បីរិះគិតរួមគ្នាអំពីបញ្ហាផ្សេងៗពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០២១ នៅទីតាំងនៅព្រះវិហារកំពង់ចាមក្រុង។

តាមការផ្សព្វផ្សាយនៅលើបណ្តាញសង្គមផ្លូវការរបស់ព្រះសហគមន៍កំពង់ចាមក្រុងបានសរសេរថា កិច្ចប្រជុំសហម្ពន្ធគ្រូមត្តេយ្យនេះ ធ្វើឡើងក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់លោក ប្រ៊ុយណូ កូសម៍

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមផ្ទាល់លោកហេង វ៉ារី ប្រធានបុគ្គលិកព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម និងលោកគ្រូអ្នកគ្រូសាលាមត្តេយ្យមួយចំនួនទៀត។

បណ្តាញសង្គមខាងលើបានបន្តរៀបរាប់ថា គោលដៅនៅក្នុងកិច្ចប្រជុំសហសម្ពន្ធគ្រូមត្តេយ្យសាលាក្នុងថ្ងៃនេះ គឺដើម្បីរិះគិតរួមគ្នាអំពីបញ្ហាផ្សេងៗ ស្វែងរកដំណោះស្រាយ ការចែករំលែកអំពីការងារតាមកន្លែងផ្សេងៗរកគន្លឹះធ្វើយ៉ាងដើម្បីដើម្បីឲ្យប្រព័ន្ធអប់រំកុមារនៅតាមសហគមន៍កាន់តែមានភាពរីកចម្រើនឡើង។

នៅក្នុងឱកាសនោះដែរលោក ប្រ៊ុយណូ កូសម៍ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគ



កំពង់ចាមផ្ទាល់បានមានប្រសាសន៍៣ចំណុចសំខាន់ៗ ទី១ លោកចង់កែសម្រួលរចនាសម្ព័ន្ធខ្លះៗ ដើម្បីឲ្យការងារបណ្តុះបណ្តាលកាន់តែទទួលបានប្រសិទ្ធភាព ទី២ អ្នកគ្រូបង្គោលទាំង៣នាក់របស់ព្រះសហគមន៍ភូមិភាគកំពង់ចាមត្រូវមានចំណេះជំនាញយ៉ាងពិតប្រាកដ ដែលទទួលបានការបណ្តុះបណ្តាល និងទទួលស្គាល់ដោយក្រសួងអប់រំយុវជននិងកីឡា ទី៣ ពួកគាត់ត្រូវចុះជួយបណ្តុះបណ្តាលអ្នកគ្រូសាលាមត្តេយ្យព្រះសហគមន៍ដទៃទៀតតាមមូលដ្ឋាន និងបង្កើតទំនាក់ទំនងឲ្យកាន់តែជិតស្និទ្ធ ដើម្បីចូលរួមដោះស្រាយបញ្ហាបានទាន់ពេលវេលា។

លោកហេងវ៉ារីប្រធានបុគ្គលិកព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមបានផ្តល់បទសម្ភាសន៍តាមសារអេឡិត្រូនិត ប្រាប់ក្រុមការងារវិទ្យុវេរីតាសអាសុី ថា សម្រាប់លោកគ្រូអ្នកគ្រូដែលបានបំរើការងារក្នុងភូមិភាគកំពង់ចាមកន្លងមកក៏មានជួបនឹងបញ្ហាខ្លះៗ តែយើងបានជួបពិភាក្សានិងដោះស្រាយរួចអស់ហើយដែរ។ លោក វ៉ារី បានបន្តថា«ក្នុងឆ្នាំកន្លងទៅ បុគ្គលិកយើងមួយចំនួនបំពេញការងារមិនបានពេញលេញ ព្រោះការបែងចែកការងារមិនទាន់បានច្បាស់លាស់។ ម្យ៉ាងទៀតលោកបូជាចារ្យ បងប្រុស បងស្រីជាប់រវល់និងការងារប្រកាសដំណឹងល្អ មិនសូវបានទាក់ទង និងទៅដល់ទីតាំងមួយចំនួន ដែលជាហេតុនាំឲ្យបុគ្គលិកមួយខ្លះបាក់ទឹកចិត្តក្នុងការបំពេញការងារ»។

ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ជាភូមិភាគមួយក្នុងចំណោមភូមិភាគទាំង៣ របស់ព្រះសហគមន៍កាតូលិក នៅក្នុងប្រទេសកម្ពុជា ដែលបានយកចិត្តទុកដាក់ជួយបណ្តុះបណ្តាលកូនអ្នកក្រីក្រនៅតាមជនបទ តាំងពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សា៕

# បេក្ខជន បេក្ខនារី ចំនួន១០៤នាក់ទទួល ត្រាស់ហៅយ៉ាងឱឡារិក ពីលោក អូលីវីយេ

*អត្ថបទ៖ ដាលីស*

អូលីវីយេ ជ្មីតហាស្លេរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានត្រាស់ហៅ បេក្ខជន បេក្ខនារី ចំនួន១០៤នាក់ យ៉ាងឱឡារិក ដើម្បីរៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកនារាត្រីបុណ្យចម្លងខាងមុខ។ ពិធីប្រារព្ធ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី កាលពីល្ងាចថ្ងៃទី២០ កុម្ភៈ ២០២១ ដោយមានការចូលរួមដោយអស់លោកបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពនីមួយៗនៃព្រះសហគមន៍ភូមិភាគភ្នំពេញ។

តាមប្រសាសន៍របស់លោកអភិបាលអូលីវីយេ បានថ្លែងថា ៖ «ថ្ងៃនេះព្រះសហគមន៍បានត្រាស់ហៅបងប្អូន១០៤នាក់ឱ្យធ្វើជំហានទី២នៃអគ្គសញ្ញាជ្រមុជទឹក ជាពេលវេលាមួយដែលព្រះសហគមន៍ណែនាំបងប្អូនឱ្យមានការកែប្រែចិត្តគំនិតដើម្បីធ្វើជាមនុស្សថ្មី»។

លោកបន្ថែមថា ព្រះសហគមន៍អញ្ជើញបងប្អូននៅក្នុងការអប់រំពិសេសដោយមាន៤០ថ្ងៃជាពេលវេលា ដើម្បីត្រៀមរៀបចំចិត្តគំនិត ហើយទាំងអស់គ្នាត្រូវកែប្រែចិត្តគំនិតជារៀងរាល់ថ្ងៃ ដោយដឹងថាគ្រប់គ្នាមានព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅជាមួយ មានព្រះយេស៊ូជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត ដែលនាំឱ្យមានការកែប្រែចិត្តគំនិតបាន។

លើសពីនេះទៅទៀត លោកអភិបាលព្រះសហគមន៍ក៏បានរំឭកផងដែរពីពេលវេលាកូវីដ១៩ ជាពេលវេលាដើម្បីគិតពិចារណាពីតម្លៃជីវិត និងគោលដៅជីវិតរបស់យើង។

លោកអូលីវីយេ៖ «ស្នើសូមគ្រីស្តបរិស័ទទាំងអស់កែប្រែចិត្តគំនិតជារៀងរាល់ថ្ងៃ ដោយរិះគិតថា តើយើងកែអ្វីនៅក្នុងជីវិតរបស់យើង? តើយើងទៅជាមនុស្សថ្មីយ៉ាងដូចម្ដេច? លោកអភិបាលរំឭកផងដែរថា ពិធីជ្រមុជទឹកប្ដូរអ្វីដែលមាននៅខាងក្នុងខ្លួនយើង ដោយមានមនសិកាល្អ គំនិតល្អ ដោយអនុវត្តតាមវិន័យរបស់ព្រះយេស៊ូ ដោយលើកលែងទោស និងយកចិត្តទុកដាក់ចំពោះបងប្អូនឯទៀត»។



ក្នុងនាមព្រះសហគមន៍ភូមិភាគភ្នំពេញ លោកអភិបាលបានអញ្ជើញបេក្ខជនទាំងនោះម្នាក់ម្ដងៗ ដោយមានគូសសញ្ញាឈើឆ្កាងលើបេក្ខជន និងប្រគល់កន្សែងពណ៌ស្វាយ ជានិមិត្តសញ្ញានៃការកែប្រែចិត្តគំនិតដល់បេក្ខជនដើម្បីត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកនាថ្ងៃបុណ្យចម្លងខាងមុខ។

ក្រោយពីទទួលការត្រាស់ហៅពីលោកអភិបាលព្រះសហគមន៍ បេក្ខជន បេក្ខនារី ទាំង១០៤នាក់ ដែលមកពីគ្រប់មណ្ឌលសកម្មភាពទាំង៩នៃព្រះសហគមន៍កាតូលិកភូមិភាគ នឹងរៀបចំខ្លួន ដោយទទួលពិធីនានា តាមក្បួនអប់រំជំនឿព្រះសហគមន៍កាតូលិក ហើយគេត្រូវចូលរួមគ្រប់ពិធីទាំងឡាយនោះរហូតដល់ថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងឱកាសបុណ្យចម្លងខាងមុខ។

បេក្ខនារី ស៊ុន ផល្លា មកពីព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន និយាយថា ជំហានទី២នេះជាកម្មវិធីមួយដ៏ពិសេសសម្រាប់នាងផ្ទាល់ ដោយទទួលបាននូវអារម្មណ៍មួយដ៏ជិតស្និទ្ធដែលជាភាពកក់ក្ដៅ។

នាងថា៖ «អ្វីដែលខ្ញុំចាប់អារម្មណ៍លើព្រះសហគមន៍ព្រោះនេះជាសហគមន៍និងគ្រួសារតែមួយដែលមិនឱ្យខ្ញុំឯកា ព្រោះជាសេចក្ដីស្រឡាញ់»។

បេក្ខនារីបន្តទៀតថា ដើម្បីត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកខាងមុខនេះ នាងត្រូវបើកចិត្តគំនិតដោយចែករំលែកសេចក្ដីស្រឡាញ់ទៅឱ្យមនុស្សជុំវិញខ្លួន ចេះលើកលែងទោស ដោយដើរតាមព្រះជាម្ចាស់ និងកែប្រែខ្លួនរស់នៅជាគ្រីស្តបរិស័ទល្អម្នាក់។

បេក្ខជន កែវ សុខហ៊ីង មកពីព្រះសហគមន៍សែនសុខ និយាយថា ជំហានទី២នេះធ្វើឱ្យលោកបានស្គាល់បងប្អូនមកពីច្រើនកន្លែងផ្សេងៗគ្នានិងបានទទួលមេរៀនសម្រាប់លោកទៅថ្ងៃក្រោយ។

លោកសុខហ៊ីងបន្តថា ៖ «ជំហានទី២នេះព្រះសហគមន៍បង្រៀនខ្ញុំច្រើនពីរបៀបរស់នៅល្អៗដែលខុសកាលពីមុនដែលខ្ញុំមិនដែលបានស្គាល់ព្រះសហគមន៍ទោះបីជាយាយរបស់ខ្ញុំបង្ខំខ្ញុំឱ្យចូលវិហារយ៉ាងណាក៏ដោយក៏ខ្ញុំមិនចូល និងមិនដែលស្ដាប់ម៉ាក់ប៉ា»។

លោកប្រាប់ទៀតថា «ប៉ុន្តែនៅពេលខ្ញុំឈឺជិតស្លាប់ ខ្ញុំបានឃើញគ្រីស្តបរិស័ទរួមជាមួយយាយរបស់ខ្ញុំទៅអធិដ្ឋានដល់ព្រះជាម្ចាស់ឱ្យជួយខ្ញុំដែលហាក់បីដូចជាការអស្ចារ្យសម្រាប់ជីវិតខ្ញុំ។ ខ្ញុំបានឃើញការបង្រៀនរបស់ព្រះសហគមន៍គឺនៅពេលខ្ញុំស្គាល់ព្រះគ្រីស្ត ដែលបង្រៀនឱ្យខ្ញុំចេះស្រឡាញ់អ្នកដទៃផងដែរ»៕

# លោកអភិបាលភូមិភាគបាត់ដំបងទទួលវ៉ាក់សាំង

*អត្ថបទ៖ អរិយបុត្រ*

លោក អេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងកាលពីថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២១ បានទទួលវ៉ាក់សាំងប្រឆាំងមេរោគកូវីដ១៩ ដូសទីមួយ ហើយកំពុងតែរង់ចាំការចាក់ដូសទីពីរបន្តទៀត។

ក្រោយពេលដែលរាជរដ្ឋាភិបាលបានស្វែងរកវ៉ាក់សាំងបានប្រមាណជាជិតមួយលានដូសសម្រាប់ចាក់ជូនប្រជាពលរដ្ឋ និងក្រុមអទិភាពដែលប្រឈមមុខខ្លាំងនឹងមេរោគដ៏កាចសាហាវមួយនេះ។

នៅក្រោយពេលដែលទទួលវ៉ាក់សាំងដូសទីមួយនេះបានរួចរាល់លោកអភិបាល បានថ្លែងពីចំណាប់អារម្មណ៍របស់លោកប្រាប់អ្នកនាំសារថា៖ "សូមឱ្យបងប្អូនដឹង ហើយកុំភ័យ កុំព្រួយ យើងត្រូវទទួលវ៉ាក់សាំងដើម្បី ការពារថែរក្សាសុខភាពយើង និងសុខភាពអ្នកនៅសង្គមនៅក្នុងភូមិសម្រាប់យើងទាំងអស់គ្នា"។

តាមការគ្រោងទុក លោកអភិបាល នឹង



ទទួលវ៉ាក់សាំងដូសទីពីរ នៅថ្ងៃទី ០៩ ខែមេសា មុនចូលឆ្នាំប្រពៃណីជាតិខ្មែរខាងមុខ ហើយនៅក្នុងអំឡុងពេលចាប់ពីការចាក់ដូសទីមួយមកដល់ពេលនេះលោកបានឲ្យដឹងថា សុខភាពរបស់លោកនៅតែធម្មតា។

លោកអភិបាលបានបញ្ជាក់ថា៖ "ខ្ញុំនៅសុខភាពល្អ អាចហាត់ប្រាណបានធម្មតា ញុំាបាយស្រួល គេងស្រួល ជីវិតធម្មតាអត់មានអីដែលប្លែកបណ្ដាលឱ្យខ្ញុំឈឺ។ ខ្ញុំអត់មានសង្ស័យថាកើត ឈឺទៀត នៅល្អទាំងអស់ ខ្ញុំ ខ្ញុំសង្ឃឹមថ្ងៃទី០៩ ខែ ០៤ មុនចូលឆ្នាំ ខ្ញុំទទួលលើកទី០២"។

លោកអភិបាលបានបង្ហាញនូវក្ដីសង្ឃឹមថា នៅពេលដែលកម្ពុជាមានវ៉ាក់សាំងគ្រប់គ្រាន់ សូមនាំគ្នាមកចាក់ឲ្យបានគ្រប់គ្នា ហើយនៅក្នុងអំឡុងពេលនេះ សូមគ្រីស្តបរិស័ទ និងបងប្អូនប្រជាពលរដ្ឋទាំងអស់នៅឲ្យឆ្ងាយពីមេរោគកូវីដ ១៩។

លោកអភិបាលបានថ្លែងបន្តថា សូមបងប្អូនការពារថែរក្សាសុខភាពនិងសុវត្ថិភាពពីមេរោគតាមការណែនាំរបស់ក្រសួងសុខាភិបាល ដោយពេលទៅណាមកណាសូមប្រើម៉ាស់រហូតទោះបីជាមិនសូវមានទំលាប់នៅក្នុងការប្រើវាក៏ដោយ ហើយទន្ទឹមនឹងនោះ ម្នាក់ៗត្រូវមានអាល់កុលរហូត ហើយត្រូវលាងដៃក្នុងមួយថ្ងៃយ៉ាងតិច៥ដង នៅក្នុងករណីគ្មានអាល់កុលឬជែល សូមប្រើសាប៊ូ។ លោកអភិបានបានបន្តទៀតថា សូមការពារខ្លួនកុំទៅកន្លែងអ៊ូអរ ហើយករណីចេញទៅក្រៅ សូមឱ្យរកកន្លែងណាដែលទូលាយ កុំចូលចិត្តនៅគៀកៗគ្នា រក្សាគម្លាត ពោលគឺធ្វើយ៉ាងណា ថែរក្សាសុវត្ថិភាពយើងនិង ក្រុមគ្រួសារ ក៏ដូចជាការពារថែរក្សាសង្គម និង សហគមន៍យើងផងដែរ។

នាឱកាសនោះ លោកអភិបាលក៏បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចនានា ដែលបានចំណាយពេលវេលា និង កម្លាំង លះបង់ពេលវេលានៅក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគកូវីដ១៩ ក៏ដូចជាខិតខំស្វែងរកនូវវ៉ាក់សាំងសម្រាប់ចាក់ជូនប្រជាពលរដ្ឋ ជាបន្តបន្ទាប់រហូតមកដល់ពេលនេះ៕

# ព្រះសហគមន៍កាតូលិកមណ្ឌលគិរីទទួលអ្នកឈ្វេងយល់ជំនឿ៤៨នាក់ជាជនជាតិព្នង



*អត្ថបទ៖ កែវ កញ្ញា*

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ប្រ៊ុយណូ កូសម៍ បានត្រាស់ហៅបេក្ខជនចំនួន៤៨នាក់ឲ្យត្រៀមខ្លួនដើម្បីទទួលពិធីបុណ្យជ្រមុជទឹកនៅក្នុងឱកាសបុណ្យចម្លងខាងមុខនេះ កាលពីថ្ងៃអាទិត្យទី២១ ខែកុម្ភៈកន្លងទៅ នៅព្រះសហគមន៍ប៊ូស្រានៃខេត្តមណ្ឌលគិរី។

លោកអភិបាលបានមានប្រសាសន៍ថា កម្មវិធីថ្ងៃនេះ យើងមិនមែនសម្តែង មិនមែនដើម្បីឲ្យយើងពេញចិត្ត គឺឲ្យយើងយល់ពីព្រះយេស៊ូដែលកំពុងធ្វើដំណើរជាមួយយើង និងអ្វីដែលយើងបានឃើញនៅថ្ងៃនេះ គឺបងប្អូនមួយចំនួនចាប់អារម្មណ៍និងកំពុងត្រៀមពីមួយសប្តាហ៍ទៅមួយសប្តាហ៍ គេស្គាល់ព្រះយេស៊ូកាន់តែច្បាស់ ហើយព្រះយេស៊ូកំពុងធ្វើការនៅក្នុងចិត្តរបស់គេ។

លោកហ្វើក សារៈ អាយុ៥៤ឆ្នាំ មកពីព្រះសហគមន៍កែវ សីមា ឲ្យដឹងថា ជំនឿលើព្រះយេស៊ូគឺឃើញថាមានប្រសិទ្ធភាពនិងមានភាពកក់ក្តៅ។ លោកបន្តថា ៖ «យើងរស់នៅជាក្រុមគ្រួសារ គឺតាមបែបជាសហគមន៍ «យើងឃើញថា អ្នកដែលពឹងលើព្រះយេស៊ូមានភាពសុខសប្បាយ»។

លោកឲ្យដឹងទៀតថា ក្រោយពេលដែលទទួលពិធីជ្រមុជទឹក លោកនឹងខិតខំអនុវត្តជំនឿរបស់ខ្លួន ដោយផ្សព្វផ្សាយដល់បងប្អូនក្រីក្រ និងអ្នកដែលមិនទាន់ជឿ តាមរយៈការសួរសុខទុក្ខ។

អ្នកស្រី ជូន ចិន្តា បេក្ខជនទទួលពិធីត្រាស់ហៅ និងជាគ្រូសាលាមត្តេយ្យបាននិយាយថា ៖ «សម្រាប់ខ្ញុំក្រោយពេលចូលជាគ្រីស្តបរិស័ទឃើញថា ជីវិតរបស់ខ្ញុំរីកចម្រើនឡើង ដោយសារខ្ញុំបានផ្លាស់ប្តូរជំនឿ ផ្លាស់ប្តូរជីវិតថ្មី។ ពេលឈឺតែងតែបន់ ប្រើមាន់ប្រើអី តែពេលឥឡូវអត់ទេ ចាស ចំណាយថវិកាច្រើន»។

លោកបូជាចារ្យផាន បូរី ទទួលខុសត្រូវព្រះសហគមន៍កែវ សីមាននិងដាក់ដាំបានប្រាប់ថា លោកបានមើលឃើញថា អ្នកឈ្វេងយល់ជំនឿមានចិត្តខ្នះខ្នែង «ខ្ញុំបានអប់រំពួកគេអស់រយៈពេលពីរបីឆ្នាំដែរ។ ខ្ញុំឃើញថាបងប្អូនជនជាតិ មានជំនឿ»។

លោកបូជាចារ្យបានប្រាប់អំពីវប្បធម៌ប្រពៃណីដែលបងប្អូនជនជាតិបានធ្វើពីមុន គឺសាសនារបស់គេចំណាយប្រាក់ច្រើននៅពេលឈឺ ព្រោះគេត្រូវសែនព្រេន ដោយកាប់គោកាប់ក្របីមាន់ទា គឺអស់ប្រាក់ច្រើនរាប់ពាន់ដុល្លារ។ តែនៅពេលគេចាប់ផ្តើមលះបង់ជំនឿចាស់ហើយចូលក្នុងគ្រីស្តសាសនា ឬគេចូលចិត្តប្រើពាក្យសាសនាព្រះយេស៊ូនាំឲ្យគេផ្លាស់ប្តូរយ៉ាងច្រើន មានន័យថា គេយកព្រះគ្រីស្តជាទីពឹង ព្រះបន្ទូលជាទីពឹង ព្រះសហគមន៍ជាទីពឹង ហើយគេលះបង់អ្វីដែលមានពីមុនដែលធ្វើឲ្យគេខាតបង់យ៉ាងច្រើន។

លោកបូជាចារ្យបន្ថែម ៖ «តែពេលគេដើរតាមព្រះយេស៊ូធ្វើឲ្យគេមានក្តីសង្ឃឹមថ្មី។ ហើយព្រះសហគមន៍បានឲ្យតម្លៃពួកគេ ទោះបីពួកគេជាជនជាតិព្នង ពួកគេនៅព្រៃ ឬពួកគេមិនសូវជាចេះខ្មែរ ប៉ុន្តែព្រះសហគមន៍ឲ្យតម្លៃគាត់នឹងនាំឲ្យគាត់មានក្តីសង្ឃឹម ជិតស្និទ្ធជាមួយព្រះសហគមន៍»។

ព្រះសហគមន៍ដាក់ដាំកកើតនៅឆ្នាំ១៩៨៦ មានគ្រីស្តបរិស័ទ៤០ អ្នកឈ្វេងយល់ជំនឿ៥០ ត្រៀមជ្រមុជទឹក២១ ព្រះសហគមន៍កែវសីមាកកើតនៅឆ្នាំ២០១១ មានគ្រីស្ត៣៥នាក់ អ្នកឈ្វេងយល់ជំនឿ៥០នាក់ ត្រៀមជ្រមុជទឹក ២៧។

លោកបូជាចារ្យមានប្រសាសន៍ទៀតថា ៖ «ខ្ញុំមានស្ទើរតែរាល់ខែ ដែលបងប្អូនមកជួបខ្ញុំនិងសុំចូលព្រះសហគមន៍»។ លោកបញ្ជាក់ថា អ្នកខ្លះមានជំនឿជ្រៅជាមួយប្រពៃណីនិងវប្បធម៌របស់គេ តែគេឲ្យយើងទៅអធិដ្ឋាននៅផ្ទះរបស់គេ ហើយយកគ្រឿងអារុក្ខអារក្សអ្នកតារបស់គេដែលតាំងនៅក្នុងផ្ទះ មានទាំងខ្សែដៃនិងខ្សែគាថា យកមកដុតចោល ហើយគេឲ្យយើងអធិដ្ឋាននៅលើផ្ទះគេ ប្រោះទឹកព្រះពរ ដើម្បីឲ្យគេមានក្តីសង្ឃឹមថ្មីជាមួយព្រះយេស៊ូ៕

# ត្រីទិវា



***ព្រហស្បតិ៍ពិសិដ្ឋ** ថ្ងៃទី១ ខែមេសា ឆ្នាំ២០២១៖
-ម៉ោង ៦៖០០ល្ងាច **«ជប់លៀងចុងក្រោយ»**
*(លោកអភិបាល អូលីវីយេ ពីចំការទៀង)*

***សុក្រពិសិដ្ឋ** ថ្ងៃទី២ ខែមេសា ឆ្នាំ២០២១៖
-ម៉ោង ៣៖០០រសៀល **«ដើរផ្លូវឈើឆ្កាង»**
(បូជាចារ្យរឿងឆ័ត្រសិរីនៅផ្សារតូច)
-ម៉ោង ៦៖០០ល្ងាច **«ព្រះយេស៊ូរងទុក្ខលំបាក»**
*(លោកអភិបាល អូលីវីយេ ពីចំការទៀង)*



***សៅរ៍ពិសិដ្ឋ** ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២១៖
-ម៉ោង ៦៖០០ល្ងាច **រាត្រីបុណ្យចម្លង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង**
(លោកអភិបាលអូលីវីយេ ពីចំការទៀង)

***ថ្ងៃអាទិត្យ** ទី៤ ខែមេសា ឆ្នាំ២០២១៖
**ថ្ងៃបុណ្យចម្លង** (លោកពុក សួន ហង្សលី នៅភ្នំពេញថ្មី)

បងប្អូនអាចតាមដាននៅតាមអនឡាញ លើគេហទំព័រ៖
FB: RVAKhmer, FB: CatholicChurchInCambodia,
FB: CatholicPhnomPenh, Youtube: CatholicPhnomPenh

# អភិបូជាតាមព្រះសហគមន៍នានា
# ជូនវិញ្ញាណក្ខន្ធលោកអភិបាល អ៊ីវ រ៉ាមូស

## អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ (១៩៦២-១៩៧៦ និង ១៩៩២-២០០១)

សូមបងប្អូនបន្តអធិដ្ឋាន និងអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានអ្នកបម្រើដ៏ឧត្តមរបស់ព្រះអង្គ ឱ្យមកបម្រើព្រះសហគមន៍កាតូលិករបស់យើងនៅប្រទេសកម្ពុជា ដែលពោរពេញដោយភាពលះបង់ព្យាយាម និងចិត្តស្រលាញ់យ៉ាងខ្លាំងបំផុត។

